ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ធនាគារជាតិ នៃ កម្ពុជា
NATIONAL BANK OF CAMBODIA

# របាយការណ៍ប្រចាំឆមាសទី ១

# និង

# ទិសដៅការងារឆមាសទី២

# ឆ្នាំ២០០៨

# មាតិកា


ទំព័រ

ក. របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០០៨ ១

សេចក្តីផ្តើម ២

I. ការវិវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ៣

១. ស្ថានភាពតម្លៃប្រាក់រៀល ៣

១.១. ការវិវត្តសន្ទស្សន៍ថ្លៃទំនិញ និងសេវា (CPI) ៣

១.២. ស្ថានភាពអត្រាប្តូរប្រាក់ ៤

១.២.១. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ៤

១.២.២. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗ ៦

២. ការវិវត្តរូបិយវត្ថុ ៦

២.១. ការផ្គត់ផ្គង់រូបិយវត្ថុ ៧

២.២. កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ ៩

២.២.១. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ៩

២.២.២. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ ១០

២.៣. អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើ របស់ធនាគារពាណិជ្ជ ១០

៣. ជញ្ជីងទូទាត់ ១១

៣.១. គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) ១១

៣.២. គណនីដើមទុន និងហិរញ្ញវត្ថុ ១៣

៤. ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ១៤

៤.១. ការវិនិយោគទុនបម្រុងអន្តរជាតិ ១៤

៤.២. អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ១៥

៤.៣. ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់ ១៥

៥. សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៦

៥.១. ការត្រួតពិនិត្យធនាគារពាណិជ្ជ ១៦

៥.១.១. ការត្រួតពិនិត្យលើឯកសារ ១៦

៥.១.២. ការត្រួតពិនិត្យដល់ទីកន្លែង ១៧

៥.២. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ១៧

៥.៣. ការងាររៀបចំបទបញ្ញា ១៨

៥.៤. អាជ្ញាប័ណ្ណ និងចុះបញ្ជី ១៨

៥.៥. ការជម្រះបញ្ជីធនាគារ ១៩

៥.៦. ចំណូលពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងស្ទួងការគណនី ១៩

៥.៧. ការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ១៩

៦. ការផ្គត់ផ្គង់សេវាធនាគារកណ្តាល ២០

៦.១. សេវាផ្នែកគណនី ២០

៦.១.១. សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ ២០

៦.១.២. សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ២០

៦.២. សេវាផាត់ទាត់ ២០

៦.២.១. ការផាត់ទាត់មូលប្បទានបត្រចរាចរជាប្រាក់រៀល ២១

៦.២.២. ការផាត់ទាត់មូលប្បទានបត្រចរាចរជាប្រាក់ដុល្លារអាមេរិក ២១

៦.៣. ការងារឥណទាន ២១

៦.៤. ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរដ្ឋាភិបាល ២២

៦.៤.១. ហិរញ្ញប្បទាន និងកម្ចីរបស់រាជរដ្ឋាភិបាលជប៉ុន ២២

៧. ការគ្រប់គ្រងចរាចរណ៍ធនបត្រ ២៤

៨. ការអភិវឌ្ឍប្រព័ន្ធទូទាត់ជាតិ ២៥

II. ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ២៥

១. សកម្មភាពក្រុមប្រឹក្សាភិបាល ២៥

២. ការអភិវឌ្ឍធនធានមនុស្ស ២៦

២.១. ស្ថិតិមន្ត្រី-បុគ្គលិក ២៦

២.២. ការងារបណ្តុះបណ្តាល ២៦

៣. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ២៨

៤. ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា ២៩

៥. ការងារគណនេយ្យធនាគារជាតិនៃកម្ពុជា ២៩

III. ទំនាក់ទំនងអន្តរជាតិ ៣១

១. ទំនាក់ទំនងពហុភាគី ៣១

១.១. ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ ៣១

១.២. ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ៣២

១.៣. ទំនាក់ទំនងជាមួយអាស៊ាន ៣៣

១.៤. ទំនាក់ទំនងជាមួយ SEACEN ៣៤

១.៥. ទំនាក់ទំនងជាមួយក្រុមអាស៊ីប៉ាស៊ីហ្វិក (APG) ៣៥

១.៦. ទំនាក់ទំនងជាមួយសមាគមឥណទានកសិកម្ម និងឥណទានជនបទតំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA) ៣៥

២. ទំនាក់ទំនងទ្វេភាគី ៣៦

សន្និដ្ឋាន ៣៧

ខ. ទិសដៅការងារឆមាសទី២ ឆ្នាំ២០០៨ ៣៨

ទិសដៅការងារឆមាសទី២ ឆ្នាំ២០០៨ ៣៩

១. ការងាររូបិយវត្ថុ ៣៩

២. ការងារប្តូរប្រាក់ ៣៩

៣. ការងារអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ ៤០

៤. ការងារត្រួតពិនិត្យ ៤០

៥. ការងារប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ៤១

៦. ការងារគណនេយ្យ ៤១

៧. ការងារប្រតិបត្តិការ ៤១

៨. ការងារបោះផ្សាយ និងឃ្លាំងបេឡា ៤២

៩. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ៤២

១០. ការបណ្តុះបណ្តាល ៤២

ឧបសម្ព័ន្ធ ៤៣

ឧបសម្ព័ន្ធ ១ : សន្ទស្សន៍ថ្លៃទំនិញ និងសេវា ឆ្នាំ២០០៥-ឆមាសទី១ ឆ្នាំ២០០៨ ៤៤

ឧបសម្ព័ន្ធ ២ : ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ ៤៥

ឧបសម្ព័ន្ធ ៣ : ស្ថានភាពរូបិយវត្ថុ (គិតជាពាន់លានរៀល) ៤៦

ឧបសម្ព័ន្ធ ៤ : ស្ថានភាពរូបិយវត្ថុ (បម្រែបម្រួលប្រចាំខែជាភាគរយ) ៤៧

ឧបសម្ព័ន្ធ ៥ : តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា ៤៨

ឧបសម្ព័ន្ធ ៦ : តារាងគណនីវិភាគធនាគារពាណិជ្ជ ៤៩

ឧបសម្ព័ន្ធ ៧ : ឥណទានចំណាត់ថ្នាក់តាមមុខរបរ និងសរុបប្រតិបត្តិការប្រាក់បញ្ញើធនាគារពាណិជ្ជ ៥០

ឧបសម្ព័ន្ធ ៨ : ជញ្ជីងទូទាត់ប្រទេសកម្ពុជា ឆ្នាំ២០០៥ — ឆមាសទី១ ឆ្នាំ២០០៨ ៥១

# អារម្ភកថា

នៅឆមាសទី ១ ឆ្នាំ២០០៨ ត្រូវបានកត់សម្គាល់ដោយបញ្ហាប្រឈមចម្បងៗមួយចំនួន ខណៈដែលសភាពការណ៍សេដ្ឋកិច្ចពិភពលោកមានសភាពស្រអាប់មួយកម្រិត បណ្តាលមកពីបញ្ហាគួបផ្សំមួយចំនួនដូចជា ភាពរង្គោះរង្គើនៃទីផ្សារហិរញ្ញវត្ថុនិងទីផ្សារឥណទានរបស់បណ្តាប្រទេសឧស្សាហកម្ម ព្រមទាំងការបន្តកើនឡើងដ៏ខ្ពស់នៃថ្លៃប្រេងឥន្ធនៈ និងថ្លៃម្ហូបអាហារជាសកល ជាពិសេសការកើនឡើងថ្លៃអង្ករជាដើម ។ ប៉ុន្តែ អាស្រ័យដោយប្រទេសជាច្រើនមានមូលដ្ឋានគ្រឹះរឹងមាំជាងមុន វិបត្តិហិរញ្ញវត្ថុមិនត្រូវបានរំពឹងទុកថា មានឥទ្ធិពលធ្ងន់ធ្ងរជាទូទៅឡើយ ។ យោងតាមការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ កំណើនសេដ្ឋកិច្ចពិភពលោកអាចនឹងមាន ការធ្លាក់ចុះពី ៥% ក្នុងឆ្នាំ២០០៧ មក ៤,១% ក្នុងឆ្នាំ២០០៨ ។ សេដ្ឋកិច្ចអាមេរិកត្រូវបានប៉ាន់ស្មានថា អាចមានកំណើនត្រឹមប្រមាណ ១,៣% ឯតំបន់អឺរ៉ុប ១,៧% និងប្រទេសជប៉ុនអាចសម្រេចបាន ១,៥% ក្នុងឆ្នាំ២០០៨ ។ ជា មួយគ្នានេះដែរ កំណើនសេដ្ឋកិច្ចក្នុងបណ្តាប្រទេសអាស៊ានត្រូវបានព្យាករថា នឹងមានកំណើន ៥,៧% នៅឆ្នាំ ២០០៨ ធ្លាក់ចុះបន្តិច ធៀបនឹង ៦,៥% នៅឆ្នាំ២០០៧ ។ ដោយឡែកកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិនត្រូវរំពឹងទុកថាមាន ៩,៧% និងឥណ្ឌា ៨% ក្នុងឆ្នាំ២០០៨ ។

ស្ថិតក្នុងស្ថានភាពតឹងតែងនៃសេដ្ឋកិច្ចពិភពលោក និងការបន្តកើនឡើងជាបន្តបន្ទាប់នៃថ្លៃប្រេងឥន្ធនៈ ជាសកល ប្រទេសកម្ពុជាក៏ទទួលរងនូវផលប៉ះពាល់ជាសត្យានុម័តដែរ ។ នៅឆ្នាំ២០០៨ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថា មានកំណើនប្រមាណ ៧,២% ធៀបនឹង ១០,១% នាឆ្នាំកន្លងទៅ ដោយផ្អែកលើការរំពឹងទុកថា វិស័យទេសចរ សេវាកម្ម និងកសិកម្មមានដំណើរការប្រព្រឹត្តទៅក្នុងកំណើនល្អជាមធ្យម ចំណែកឯវិស័យកាត់ដេរ ព្រមទាំងសំណង់ អាចមានកំណើនក្នុងល្បឿនមួយយឺតជាងមុនបន្តិច ។

ផលប៉ះពាល់ពីក្រៅជាកង្វល់ចម្បង គឺអតិផរណាដែលបានបន្តនិន្នាការកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងឆមាសទី ១ ឆ្នាំ២០០៨ នេះ ដោយមានអត្រាឆ្នាំលើឆ្នាំស្មើនឹង ៣៧,២% ។ កិច្ចប្រឹងប្រែងនិងវិធានការជាកញ្ចប់របស់រាជរដ្ឋាភិបាលត្រូវបានអនុវត្តជាបន្ទាន់ សំដៅរក្សាលំនឹងជីវភាពប្រជាពលរដ្ឋ ។ ក្នុងស្មារតីនេះដែរ ធនាគារជាតិនៃកម្ពុជាបានបំពេញតួនាទីរបស់ខ្លួន ក្នុងការទប់ស្កាត់កំណើននៃការផ្គត់ផ្គង់រូបិយវត្ថុ និងឥណទាន រួមមានជាអាទិ៍ តាមរយៈការបង្កើនអត្រាប្រាក់បម្រុងកាតព្វកិច្ច និងការណែនាំដល់បណ្តាធនាគារឱ្យមានគោលនយោបាយឥណទានសមស្របជាដើម ។ ជាលទ្ធផល ប្រាក់រៀលមានស្ថិរភាពគួរឱ្យកត់សម្គាល់ដោយបានប្រែប្រួលក្នុងរង្វង់ ៤.០០១រៀល ទៅ ៤.១២៤រៀល ក្នុង ១ ដុល្លារអាមេរិក ក្នុងអំឡុងឆមាសទី ១ ឆ្នាំ២០០៨ នេះ ។ ស្ថិរភាពនៃតម្លៃប្រាក់រៀល បានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងទំនុកចិត្តរបស់សាធារណជន អាជីវករ និងវិនិយោគិនមកលើទស្សនវិស័យ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា តាមរយៈការកាត់បន្ថយហានិភ័យផ្សេងៗ ។ ទន្ទឹមនេះដែរ ធនាគារជាតិនៃកម្ពុជាបានបន្តខិតខំថែមទៀត ក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល និងសម្រួលដល់ការទូទាត់ប្រតិបត្តិការជារូបិយវត្ថុជាតិ ដោយបានចេញផ្សាយក្រដាសប្រាក់ ២០ ០០០រៀល គំរូថ្មី ទៅក្នុងចរាចរណ៍ ។ ទុនបម្រុងអន្តរជាតិដុល[១]

[១] *ទុនបម្រុងអន្តរជាតិដុល ស្មើនឹងទ្រព្យសកម្មបរទេសរបស់ធនាគារជាតិនៃកម្ពុជាមិនគិតបញ្ចូលប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ*

បានបន្តកើនឡើងពី ១,៦ពាន់លានដុល្លារ នាដំណាច់ឆ្នាំ២០០៧ ដល់ ២ពាន់លានដុល្លារ នៅដំណាច់ឆមាសទី១ ឆ្នាំ ២០០៨ ដែលធានាបាននូវការនាំចូលប្រមាណបីខែ ។

ចំពោះស្ថានភាពវិស័យធនាគារនិងហិរញ្ញវត្ថុក៏បានបង្ហាញពីសញ្ញាវិជ្ជមានផងដែរ ។ ប្រតិបត្តិការធនាគារមានការរីកចម្រើនជាបន្តបន្ទាប់ ខណៈដែលអន្តរការិយកម្មហិរញ្ញវត្ថុបានកើនឡើងដែលឆ្លុះបញ្ចាំងឱ្យឃើញពីស្ថិរភាពហិរញ្ញវត្ថុនិងជំនឿទុកចិត្តពីសំណាក់សាធារណជនមកលើប្រព័ន្ធធនាគារ ។ រូបិយវត្ថុទូទៅ M2 ធៀបទៅនឹង ផ.ស.ស បានកើនឡើង ៤% រវាងខែធ្នូ ឆ្នាំ២០០៧ និងខែមិថុនា ឆ្នាំ២០០៨ ។ ក្នុងគ្រាជាមួយគ្នានេះដែរ ឥណទានចំពោះវិស័យឯកជនបានកើនឡើង ៤៤% ដែលធ្វើឱ្យអនុបាតឥណទានធៀបនឹងប្រាក់បញ្ញើសរុបបានកើនឡើងពី ៦៨,៥% នាខែធ្នូ ឆ្នាំ២០០៧ ដល់ ៨៨,៩% នាខែមិថុនា ឆ្នាំ២០០៨ ។

ក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅបន្តកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រទេសកម្ពុជា ធនាគារជាតិនៃកម្ពុជាបានចូលរួមយ៉ាងសកម្ម និងបន្តជំរុញបន្ថែមនូវកំណែទម្រង់រចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុនិងធនាគារឱ្យកាន់តែមានភាពរឹងមាំ ។ ក្នុងបរិបទនេះ ធនាគារជាតិនៃកម្ពុជាបានបន្តតាមដានប្រព័ន្ធហិរញ្ញវត្ថុក្នុងស្រុកដោយប្រុងប្រយ័ត្ន សំដៅកែលំអ ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ។ ជាពិសេសនៅចំពោះមុខកំណើនដ៏លឿននៃឥណទានចំពោះវិស័យឯកជន ធនាគារជាតិនៃកម្ពុជាយល់យ៉ាងច្បាស់ចំពោះការផ្តោតការយកចិត្តទុកដាក់ខ្លាំងក្លាថែមទៀតទៅលើការពង្រឹងការងារត្រួតពិនិត្យធនាគារពាណិជ្ជ រួមទាំងការអនុវត្តបទប្បញ្ញត្តិប្រុងប្រយ័ត្ននានាផងដែរ ។ ក្នុងស្មារតីនេះ ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំកែលំអចំណាត់ថ្នាក់ឥណទានតាមវិស័យ និងតាមកម្រិតហានិភ័យ ព្រមទាំងត្រៀមអនុវត្តការវាយតម្លៃលើភតិសន្យា និងការដាក់កម្រិតកំណត់លើឥណទានចំពោះវិស័យអចលនទ្រព្យទៀតផង ។

ភាពចាំបាច់ក្នុងការលើកកម្ពស់ក្របខ័ណ្ឌគតិយុត្តិនៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ក៏ត្រូវបានទទួលការយកចិត្តទុកដាក់ជាច្រើនផងដែរ ក្នុងពេលកន្លងមកនេះ ។ ស្តង់ដារបទប្បញ្ញត្តិត្រូវបានកែលំអ ហើយបទប្បញ្ញត្តិធនាគារថ្មីៗបន្ថែមទៀតក៏ត្រូវបានដាក់ឱ្យប្រើប្រាស់ ដើម្បីធ្វើឱ្យសេវាធនាគារកាន់តែមានតម្លាភាព រឹងមាំ និងប្រកបដោយប្រសិទ្ធភាពថែមទៀត ។ បន្ទាប់ពីច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មបានចូលជាធរមាន រាជរដ្ឋាភិបាលបានបង្កើតយន្តការមួយនៅធនាគារជាតិនៃកម្ពុជា ដោយមានការបង្កើតក្រុមប្រឹក្សាភិបាល និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។ លើសពីនេះទៀតសេចក្តីព្រាងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុក៏បានទទួលការយល់ព្រមពីអង្គប្រជុំអន្តរក្រសួង និងត្រៀមដាក់ជូនគណៈរដ្ឋមន្ត្រីនាពេលខាងមុខ ។

ដោយឡែក ការអភិវឌ្ឍប្រព័ន្ធទូទាត់កំពុងស្ថិតក្នុងដំណាក់កាលរៀបចំយុទ្ធសាស្ត្រ និងក្របខ័ណ្ឌស្ថាប័នចាំបាច់ផ្សេងៗ រួមទាំងការពិភាក្សាជាមួយធនាគារពាណិជ្ជ និងមជ្ឈដ្ឋានពាក់ព័ន្ធទាំងឡាយផងដែរ ដើម្បីធានាភាពរលូនក្នុងការបង្កើតប្រព័ន្ធទូទាត់ដុលដោយស្វ័យប្រវត្តិមួយនាអនាគតខាងមុខ ។

ចំពោះការពង្រឹងវិស័យមីក្រូហិរញ្ញវត្ថុវិញ ឆមាសទី ១ ឆ្នាំ២០០៨ នេះ បានបង្ហាញពីការរីកលូតលាស់ថែមទៀតនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ទាំងចំនួនស្ថាប័ន អតិថិជន និងទាំងទំហំប្រតិបត្តិការ ។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាខិតខំជំរុញជាបន្តនូវចីរភាពនៃវិស័យនេះ ហើយបច្ចុប្បន្នកំពុងរៀបចំក្របខ័ណ្ឌចាំបាច់នានា សំដៅសម្រួលឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាចទទួលយកប្រាក់បញ្ញើបាន ។

ក្នុងសម្ព័ន្ធការជាមួយរាជរដ្ឋាភិបាល និងក្នុងក្របខ័ណ្ឌនៃការអនុវត្តកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ធនាគារជាតិនៃកម្ពុជាបានបំពេញមុខងារជាបេឡារបស់រាជរដ្ឋាភិបាល ដោយបន្តលើកកម្ពស់សេវាគ្រប់គ្រងគណនី និងការផ្ទេរប្រាក់បម្រើដល់ការងារថវិកាជាតិ ។ ដើម្បីបម្រើគោលដៅនេះដែរ រចនាសម្ព័ន្ធនិងមុខងាររបស់សាខាធនាគារជាតិនៃកម្ពុជាត្រូវបានពង្រឹង ។

ពាក់ព័ន្ធនឹងការរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុង ធនាគារជាតិនៃកម្ពុជាបានបន្តធ្វើកំណែទម្រង់ចាំបាច់នានា ជាពិសេសចំពោះការពង្រឹងសវនកម្មផ្ទៃក្នុង និងការលើកកម្ពស់ប្រព័ន្ធព័ត៌មានវិទ្យា ហើយការយកចិត្តទុកដាក់ក្នុងចំណុចនេះត្រូវបានផ្តោតជាដំបូងទៅលើប្រព័ន្ធប្រតិបត្តិការស្នូលរបស់ធនាគារជាតិនៃកម្ពុជា[២] ។

សមិទ្ធផលទាំងឡាយខាងលើនេះទទួលបានពីការខិតខំប្រឹងប្រែងរបស់មន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់របស់ធនាគារជាតិនៃកម្ពុជា និងកិច្ចសហប្រតិបត្តិការពីស្ថាប័នសាធារណៈពាក់ព័ន្ធ ព្រមទាំងមានការជួយគាំទ្រយ៉ាងរឹងមាំពីរាជរដ្ឋាភិបាលទាំងមូល ។ នៅមានការងារច្រើនទៀត ដែលធនាគារជាតិនៃកម្ពុជាត្រូវបំពេញ ក្នុងទិសដៅកសាងប្រព័ន្ធធនាគារមួយដែលមានសុខភាពល្អ និងមានទំនុកចិត្តពីសាធារណជន រក្សាស្ថិរភាព និងអំណាចទិញនៃប្រាក់រៀលដែលនាំមកនូវស្ថិរភាពថ្លៃ រួមចំណែកឱ្យមានកំណើនសេដ្ឋកិច្ចដ៏មានចីរភាព និងសម្រេចបានតាមផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច របស់រាជរដ្ឋាភិបាល ។

**ទេសាភិបាល**

[២] National Bank of Cambodia’s core operating system

# ក. របាយការណ៍ប្រចាំឆមាសទី១
# ឆ្នាំ២០០៨

# សេចក្តីផ្តើម

បន្ទាប់ពីមានកំណើនក្នុងអត្រាពីរខ្ទង់នារយៈពេល ៤ឆ្នាំបន្តបន្ទាប់មក សេដ្ឋកិច្ចកម្ពុជានាឆ្នាំ២០០៨ នេះ ត្រូវបានប៉ាន់ស្មានថា នឹងមានកំណើនក្នុងល្បឿនទាបជាងឆ្នាំកន្លងទៅ ដែលបណ្តាលជាពិសេសពីផលប៉ះពាល់ពីខាងក្រៅគួបផ្សំនឹងកត្តាផ្ទៃក្នុងមួយចំនួន ។ យោងតាមទិន្នន័យប៉ាន់ស្មានដំបូង កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០០៨ ត្រូវបានព្យាករថា នឹងមានកម្រិតប្រមាណ ៧,២% ធៀបនឹង ១០,១% នាឆ្នាំ២០០៧ ដូច្នេះ គឺនៅរក្សាកម្រិតមួយខ្ពស់សមរម្យនៅឡើយបើធៀបទៅនឹងអត្រាកំណើនប្រចាំឆ្នាំនៃប្រជាជនកម្ពុជា ។ ម៉្យាងទៀត អត្រានេះត្រូវបានរំពឹងថា នឹងជួយបន្ថយកំដៅសេដ្ឋកិច្ច ហើយរួមចំណែកកាត់បន្ថយសម្ពាធអតិផរណាផងដែរ ដែលបច្ចុប្បន្នបញ្ហាអតិផរណាបានក្លាយជាទិន្នាការសកលទៅហើយ ។

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ផ្អែកលើវិធីសាស្ត្រថ្មីនៃការគណនាដោយវិទ្យាស្ថានជាតិស្ថិតិ អតិផរណាឆ្នាំលើឆ្នាំបានកើនឡើងដល់ ៣៧,២% ដែលជាលទ្ធផលនៃការរងឥទ្ធិពលពីខាងក្រៅទៅលើថ្លៃម្ហូបអាហារក្នុងស្រុកក៏ដូចជាថ្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ ។ អត្រាអតិផរណាអាចនឹងមានកម្រិតខ្ពស់ជាងនេះ ថែមទៀតប្រសិនបើរាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជាពុំអនុវត្តវិធានការជាកញ្ចប់ឱ្យបានសមស្រប និងទាន់ពេលវេលាទេនោះ ។ ក្នុងអំឡុងពេល ៦ខែ ដើមឆ្នាំ២០០៨ តម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានស្ថិរភាពជាបង្គួរ ។ គួរកត់សម្គាល់ដែរថា ក្នុងគ្រាជាមួយគ្នានេះ ដើមទុនពីក្រៅប្រទេសបានបន្តហូរចូលបន្ថែមទៀត ដែលឆ្លុះបញ្ចាំងនូវទំនុកចិត្តរបស់វិនិយោគិនបរទេសមកលើទស្សនវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។ ការផ្គត់ផ្គង់រូបិយវត្ថុទូទៅ (M2) មានកំណើន ១២,៣% ដែលជាបឋមបណ្តាលមកពីកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណ ។ ជាលទ្ធផលទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារបានកើនឡើងក្នុងឆមាសទី ១ នេះ ដែលបង្ហាញមួយផ្នែកនៅក្នុងកំណើនទុនបម្រុងអន្តរជាតិចំនួន ២៦,៥% ។ ទន្ទឹមនោះដែរ ឥណទានចំពោះវិស័យឯកជនបានកើនឡើង ៣៣,៥% ក្នុងឆមាសទី១ ឆ្នាំ២០០៨ ធៀបនឹងកម្រិត ២៥% ក្នុងឆមាសទី១ ឆ្នាំ២០០៧ ។ ជាមួយនឹងការខិតខំរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សកម្មភាពរបស់ធនាគារជាតិនៃកម្ពុជាក៏បានផ្តោតផងដែរទៅលើការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និងការជំរុញអន្តរការិយកម្មធនាគារ ។ ការងារនិងសមត្ថភាពត្រួតពិនិត្យធនាគារក៏ត្រូវបានពង្រឹងថែមទៀត ក្នុងគោលដៅទប់ស្កាត់ហានិភ័យដែលបណ្តាលមកពីកំណើនឥណទានដ៏លឿន ។ កំណែទម្រង់និងការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងស្ថាប័ននានាមួយចំនួនទៀតកំពុងត្រូវបានអនុវត្តជាបន្តស្របទៅតាម "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥" ។

# I. ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា

## ១. ស្ថានភាពថ្លៃ និងតម្លៃប្រាក់រៀល

### ១.១. ការវិវត្តសន្ទស្សន៍ថ្លៃទំនិញ និងសេវា (CPI)

នៅដើមឆ្នាំ២០០៨ នេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការបានចងក្រងទិន្នន័យសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) ឡើងវិញ តាមបច្ចេកទេសថ្មី ដោយមានបន្ថែមមុខទំនិញច្រើនជាងមុន និងបានប្តូរគ្រាគោលចាស់ឆ្នាំ ២០០០ ហើយកំណត់យកគ្រាគោលថ្មីឆ្នាំ២០០៦ និងប្តូរមេគុណថ្មីពីឆ្នាំ១៩៩៩ មកឆ្នាំ២០០៤ ព្រមទាំងបានបញ្ចូលបន្ថែមការអង្កេតថ្លៃទំនិញតាមខេត្តសំខាន់ៗចំនួន ៥ ទៀត ។ តាមការសង្កេតឃើញថា ជាទូទៅសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គណនាតាមគំរូថ្មី មានកម្រិតកំណើនខ្ពស់ជាងការគណនាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តាមគំរូចាស់ ហើយជាលទ្ធផលក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ការវិវត្តសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់បង្ហាញឱ្យឃើញថា មានការកើនឡើងជាបន្តបន្ទាប់ចាប់តាំងពីខែមករា រហូតដល់ដំណាច់ឆមាសទី១ នេះ ។ បើប្រៀបធៀបទៅនឹងឆមាសទី១ និងឆមាសទី២ ឆ្នាំ២០០៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ មានការកើនឡើងខ្លាំងជាងគេ ដែលជាចម្បងការកើនឡើងនេះបណ្តាលមកពីកំណើនថ្លៃគ្រឿងឧបភោគបរិភោគ ប្រេងឥន្ធនៈ សម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់មួយចំនួនទៀត ហើយកត្តាដែលធ្វើឱ្យមានកំណើននេះ ជារួមគឺបានរងឥទ្ធិពលពីកត្តានៃកំណើនថ្លៃជាសកល ។

ក្រាហ្វស្ថិតិ ១ : ការវិវត្តសន្ទស្សន៍ថ្លៃទំនិញ និងសេវា



សន្ទស្សន៍ថ្លៃទំនិញបានកើនជាបណ្តើរៗចាប់តាំងពីខែមករាមក ដែលក្នុងនោះ អត្រាអតិផរណាប្រចាំឆមាស ស្មើនឹង ២៥,១០% ធៀបនឹងអត្រាអតិផរណា ៩,៧០% ក្នុងឆមាសទី២ ឆ្នាំ២០០៧ និង ៥,៩៨% ក្នុងឆមាស ទី១ ឆ្នាំ២០០៧ ។

ចលនានៃសន្ទស្សន៍ថ្លៃក្នុងឆមាសទី១ ឆ្នាំ២០០៨ ឆ្លុះបញ្ចាំងដោយកំណើនជាចម្បងនៃ សន្ទស្សន៍ក្រុមធំ ភោជនីយដ្ឋាន និងសណ្ឋាគារ បានកើនឡើងចំនួន ៣៦,៦៥% និងសន្ទស្សន៍ក្រុមធំអាហារ និងភេសជ្ជៈមិនមែន ជាតិស្រវឹងបានកើនឡើងចំនួន ៣៣,០៨% ដោយសារកំណើនថ្លៃអង្ករ ត្រី សាច់ជ្រូក សាច់មាន់ សាច់គោ បន្លែ និងផ្លែឈើ ។ បន្ទាប់មកគឺមាន សន្ទស្សន៍ក្រុមធំ ដឹកជញ្ជូនកើនឡើងចំនួន ១៧,៥១% សន្ទស្សន៍ក្រុមធំផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត កើនឡើងចំនួន ១៦,៧៤% សន្ទស្សន៍ក្រុមធំទំនិញនិងសេវាផ្សេងៗកើន ឡើងចំនួន ១៣,១៨% សន្ទស្សន៍ក្រុមធំភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់កើនឡើងចំនួន ៩,៦២% សន្ទស្សន៍ក្រុមធំ ការថែទាំសុខភាពកើនឡើងចំនួន ៨,៥៧% សន្ទស្សន៍ក្រុមធំសម្លៀកបំពាក់ និងស្បែកជើងកើនឡើងចំនួន ៨,១៦% សន្ទស្សន៍ក្រុមធំគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់គ្រួសារ និងការថែទាំផ្ទះជាប្រចាំកើនឡើងចំនួន ៥,៨៥% សន្ទស្សន៍ ក្រុមធំការសិក្សាកើនឡើងចំនួន ៥,២៩% សន្ទស្សន៍ក្រុមធំការកំសាន្តនិងវប្បធម៌កើនឡើងចំនួន ៤,២១% ខណៈ ដែលសន្ទស្សន៍ក្រុមធំគមនាគមន៍បានថយចុះចំនួន ៣,១៨% ។

អត្រាអតិផរណាមធ្យមប្រចាំខែក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះមានកម្រិត ៣,៨៥% ធៀបនឹង ១,៥៦% ក្នុងឆមាសទី២ ឆ្នាំ២០០៧ និង ០,៩៨% ក្នុងឆមាសទី១ ឆ្នាំ២០០៧ ។

## ១.២. ស្ថានភាពអត្រាប្តូរប្រាក់

### ១.២.១. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ តម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកនៅតែរក្សាបានស្ថិរភាពជា បង្គួរ ហើយថែមទាំងបានបង្ហាញនូវភាពរឹងមាំជាងប្រាក់ដុល្លារអាមេរិកខ្លះផង ។ ក្នុងរយៈពេល ៤ខែដើមឆ្នាំ២០០៨ នេះ ប្រាក់រៀលបានឡើងថ្លៃប្រហែល ០,១% ពោលគឺអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានថយចុះ ពី ៤.០០១រៀល ក្នុង ១ដុល្លារអាមេរិក នៅខែធ្នូ ឆ្នាំ២០០៧ មក ៣.៩៩៧រៀល ក្នុង ១ដុល្លារអាមេរិក នៅខែមេសា ឆ្នាំ២០០៨ បន្ទាប់មកក៏បានកើនឡើងដល់ ៤.១២៤រៀល ក្នុង ១ដុល្លារអាមេរិក នៅខែមិថុនា ឆ្នាំ២០០៨ នេះ ។ ការ ឡើងថ្លៃនៃប្រាក់រៀលនៅដើមឆមាសនេះ គឺបណ្តាលមកពីការធ្លាក់ថ្លៃជាសកលនៃប្រាក់ដុល្លារអាមេរិក គួបផ្សំនឹង កត្តារដូវកាលនៅក្នុងប្រទេសដែលប្រជាជនកម្ពុជាមានតម្រូវការប្រាក់រៀលសម្រាប់ការងារប្រមូលកសិផល និងតម្រូវ ការចាយវាយក្នុងពិធីបុណ្យចូលឆ្នាំចិន និងចូលឆ្នាំខ្មែរ ។ ចំណែកឯការធ្លាក់ថ្លៃនៃប្រាក់រៀលនៅក្នុងអំឡុង ២ខែ ចុង ឆមាសទី១ នេះ គឺដោយសារប្រាក់ដុល្លារអាមេរិកបានឡើងថ្លៃជាបណ្តើរៗមកវិញ ហើយតម្រូវការប្រាក់រៀលសម្រាប់ ប្រើប្រាស់របស់ប្រជាជនក៏បានថមថយមកវិញ បន្ទាប់ពីរដូវប្រមូលផលបានកន្លងផុត ។ បើពិនិត្យលើអត្រាមធ្យម ប្រចាំខែក្នុងឆមាសឃើញថា ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ មានកម្រិត ៤០២៨រៀល ក្នុង១ដុល្លារអាមេរិក គឺទាប ជាងកម្រិត ៤០៥៣រៀល ក្នុង១ដុល្លារអាមេរិក ក្នុងឆមាសទី២ ឆ្នាំ២០០៧ ពោលគឺប្រាក់រៀលបានឡើងថ្លៃប្រមាណ ០,៦% ។

## ក្រាហ្វិកស្ថិតិ ២ :  ការវិវត្តនៃអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក

(ឆ្នាំ២០០៥-ឆ្នាំ២០០៨)




## តារាងអត្រាប្តូរប្រាក់រៀល  ធៀបនឹងប្រាក់ដុល្លារអាមេរិក

(រៀលក្នុងមួយដុល្លារអាមេរិក)

| | អត្រាប្តូរប្រាក់ប្រចាំខែ  ( ចុងខែ) | | | | | |
|---|---|---|---|---|---|---|
| | អត្រាទីផ្សារ | | | អត្រាផ្លូវការ | | |
| | ទិញ | លក់ | មធ្យម | ទិញ | លក់ | មធ្យម |
| មិថុនា-០៧ | ៤.០៨៩ | ៤.០៩៩ | ៤.០៩៤ | ៤.០៧៨ | ៤.០៨៦ | ៤.០៨២ |
| ធ្នូ-០៧ | ៤.០០១ | ៤.០០៩ | ៤.០០៥ | ៣.៩៩៩ | ៤.០០៧ | ៤.០០៣ |
| មករា-០៨ | ៣.៩៩៥ | ៤.០០៣ | ៣.៩៩៩ | ៣.៩៩៣ | ៤.០០១ | ៣.៩៩៧ |
| កុម្ភៈ-០៨ | ៣.៩៩២ | ៤.០០១ | ៣.៩៩៧ | ៣.៩៩០ | ៣.៩៩៨ | ៣.៩៩៤ |
| មីនា-០៨ | ៣.៩៩២ | ៤.០០១ | ៣.៩៩៧ | ៣.៩៩១ | ៣.៩៩៩ | ៣.៩៩៥ |
| មេសា-០៨ | ៣.៩៩៧ | ៤.០០៧ | ៤.០០២ | ៣.៩៩៦ | ៤.០០៤ | ៤.០០០ |
| ឧសភា-០៨ | ៤.០៧២ | ៤.០៩៣ | ៤.០៨៣ | ៤.០២២ | ៤.០៣០ | ៤.០២៦ |
| មិថុនា-០៨ | ៤.១២៤ | ៤.១៣៨ | ៤.១៣១ | ៤.១០២ | ៤.១១០ | ៤.១០៦ |

### ១.២.២. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗ

ការប្រៀបធៀបអត្រាប្តូរប្រាក់រៀលជាមួយរូបិយប័ណ្ណផ្សេងៗមួយចំនួន ជាពិសេសរូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា ដោយផ្អែកលើអត្រាប្តូរប្រាក់ខ្វែងបានបង្ហាញឱ្យឃើញថា ក្នុងឆមាសទី១ ឆ្នាំ២០០៨ ប្រាក់រៀលបានចុះថ្លៃជាងប្រាក់វ៉ុនកូរ៉េ ៨,០៨% ប្រាក់យ៉េនជប៉ុន ៣,៨១% ប្រាក់អឺរ៉ូ ១,១៩% ប្រាក់បាតថៃ ០,៧៩% ប្រាក់ប៉េសូហ្វីលីពីន ០,៧២% ។ ទន្ទឹមនឹងនេះដែរ ប្រាក់រៀលបានឡើងថ្លៃធៀបនឹងប្រាក់រីងហ្គិតម៉ាឡេស៊ី ១,២០% ដុល្លារសិង្ហបុរី ១,៥២% ប្រាក់យ៉ន់ចិន ០,៣៥% ។ គួរកត់សម្គាល់ដែរថា ក្នុងអំឡុងពេលដូចគ្នានេះ ប្រាក់ដុល្លារអាមេរិកបានរងសម្ពាធចុះថ្លៃបង្គួរដែរ ក្នុងនោះមានជាអាទិ៍ ការចុះថ្លៃធៀបនឹងប្រាក់បាតថៃ ប្រាក់ដុល្លារអូស្ត្រាលី ប្រាក់ដុល្លារសិង្ហបុរី និងប្រាក់ដុល្លារហុងកុង ។

ក្រាហ្វិកទី ៣ : ការវិវត្តនៃតម្លៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន




* ខ្សែគំនូសឡើងលើបង្ហាញអំពីការចុះថ្លៃនៃប្រាក់រៀល

## ២. ការវិវត្តរូបិយវត្ថុ

ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៨ នេះ ទោះបីជាព្រឹត្តិការណ៍បោះឆ្នោតសកលដ៏សំខាន់នឹងឈានចូលមកដល់ក្តី ក៏ស្ថិរភាពនយោបាយនិងសន្តិសុខសង្គម គួបផ្សំនឹងនយោបាយរូបិយវត្ថុ និងសារពើពន្ធដ៏សមស្របបានបង្កលក្ខណៈល្អប្រសើរដល់ការវិវត្តនៃចលនាអត្រាប្តូរប្រាក់ ។ ទន្ទឹមនោះ កត្តាទាំងនេះក៏បាននាំមកនូវស្ថានភា រូបិយវត្ថុមួយដ៏ប្រសើរ ដែលឆ្លុះបញ្ចាំងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល ព្រមទាំងប្រព័ន្ធធនាគារទាំងមូល ។ អន្តរការិយកម្មធនាគារបន្តភាពប្រសើរឡើង ទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងខ្ពស់ជាងកំណើនកាលពីឆមាសទី១ ឆ្នាំមុន ខណៈដែលរូបិយវត្ថុទូទៅរបស់ប្រព័ន្ធធនាគារបានបន្តកើនឡើងក្នុងអត្រាកំណើនទាបជាង

ឆមាសទី១ ឆ្នាំមុន ហើយទ្រព្យសកម្មបរទេសសុទ្ធក៏បានបន្តកើនឡើងក្នុងអត្រាកំណើនទាបជាងឆមាសទី១ ឆ្នាំ ២០០៧ ផងដែរ ។ ការកើនឡើងនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធនេះ គឺបណ្តាលមកពីការកើនឡើងនៃឥណទាន ចំពោះផ្នែកឯកជន ខណៈដែលឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលមានការថយចុះ ។

ក្រាហ្វិកទី ៤ : ស្ថានភាពរូបិយវត្ថុ




## ២.១. ការផ្គត់ផ្គង់រូបិយវត្ថុ

រូបិយវត្ថុទូទៅរបស់ប្រព័ន្ធធនាគារក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៨ នេះ បានកើនឡើងចំនួន ១.៣៨៧,២ ពាន់លានរៀល (១២,៣%) ពោលគឺកើនពី ១១.៣១០,៧ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៧ ទៅ ១២.៦៩៧,៩ ពាន់លានរៀល ក្នុងខែមិថុនា ឆ្នាំ២០០៨ ។ ការកើនឡើងនៃរូបិយវត្ថុទូទៅ ជាចម្បងបណ្តាលមកពីកំណើននៃប្រាក់បញ្ញើជារូបិយប័ណ្ណរបស់និវាសជនចំនួន ៩៤៣,៧ពាន់លានរៀល (១០,៣%) គួបផ្សំជាមួយនឹងការកើនឡើងនៃរូបិយវត្ថុក្នុងចរាចរណ៍ចំនួន ៣៥៩ពាន់លានរៀល (១៨%) ប្រាក់បញ្ញើចរន្តចំនួន ៥៥,៩ពាន់លានរៀល (៨៩,៧%) និងប្រាក់បញ្ញើមានកាលកំណត់និងសន្សំចំនួន ២៨,៦ពាន់លានរៀល (២៣,៧%) ។ កំណើននៃប្រាក់បញ្ញើជារូបិយប័ណ្ណបានឆ្លុះបញ្ចាំងនូវការកើនឡើងនៃប្រាក់បញ្ញើចរន្តចំនួន ៣៣១,៧ពាន់លានរៀល (១៤,៣%) ប្រាក់បញ្ញើមានកាលកំណត់ចំនួន ៧៣១,៦ពាន់លានរៀល (២៦,៥%) ខណៈដែលប្រាក់បញ្ញើសន្សំបានថយចុះចំនួន ១១៩,៩ ពាន់លានរៀល (២,៧%) និងប្រាក់បញ្ញើផ្សេងៗបានថយចុះចំនួន ២,២ពាន់លានរៀល (២,៥%) ។ ប្រាក់បញ្ញើជារូបិយប័ណ្ណបានកើនឡើងជារៀងរាល់ខែក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៨ នេះ លើកលែងតែខែមីនា និងខែមិថុនា ដែលមានការថយចុះបន្តិចបន្តួច ។

## ក្រាហ្វិក ៥ :  សមាសធាតុនៃការផ្គត់ផ្គង់រូបិយវត្ថុ




## តារាងបម្រែបម្រួលជាភាគរយនៃស្ថិតិរូបិយវត្ថុសំខាន់ៗ និងសន្ទស្សន៍ថ្លៃទំនិញនិងសេវា

### (បម្រែបម្រួលប្រចាំខែជាភាគរយ)

| | ធ្នូ_០៧ | មករា_០៨ | កុម្ភៈ_០៨ | មីនា_០៨ | មេសា_០៨ | ឧសភា_០៨ | មិថុនា_០៨ |
|---|---|---|---|---|---|---|---|
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | -០,៤% | -៧,៦% | -៦,៧% | -១៥,២% | -៧,៤% | -៤,៩% | ១,០% |
| **ឥណទានចំពោះផ្នែកឯកជន** | ៨,២% | ៩,៩% | ៧,២% | ៧,០% | ៤,៨% | ៣,៧% | ៥,១% |
| **រូបិយវត្ថុទូទៅ (M2)** | ៥,៥% | ៤,២% | ៣,០% | -០,៨% | ៣,៩% | ២,៥% | ១,១% |
| **រូបិយវត្ថុក្នុងចរាចរណ៍** | ៨,២% | ៤,៦% | ៣,៧% | ៧,៧% | ៥,៣% | -៣,៥% | -០,៦% |
| **អតិផរណាប្រចាំខែ** | ១៦,២៦% | ១៨,៧% | ១៩,៤៤% | ៣២,២២% | ៣៧,២៥% | ៣៩,៩៤% | ៣៧,២៣% |

## ២.២. កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ

ក្នុងឆមាសទី១ ឆ្នាំ២០០៨ រូបិយវត្ថុទូទៅមានកំណើន ១២,៣% ធៀបនឹងកំណើន ២៧,៩% នៃឆមាសទី១ ឆ្នាំមុន ។ ការកើនឡើងនៃរូបិយវត្ថុទូទៅនេះ គឺដោយសារកំណើននៃកត្តាគួបផ្សំទាំងពីរ គឺទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងចំនួន ៦១៧,៩ពាន់លានរៀល (៥,៨%) និងទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន ៧៦៩,៣ពាន់លានរៀល (១៣៣,៦%) ។ កំណើននៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ បណ្តាលមកពីការកើនឡើងនៃឥណទានចំពោះផ្នែកឯកជនចំនួន ២.៨២០,៣ពាន់លានរៀល (៤៤,២%) ។ កត្តាសំខាន់ៗនៃកំណើនឥណទានចំពោះផ្នែកឯកជនគឺកំណើនឥណទានចំពោះវិស័យលក់ដុំនិងលក់រាយចំនួន ៨៣៥,៣ពាន់លានរៀល (៦០,៩%) វិស័យសេវាកម្មចំនួន ៨១៤,៣ពាន់លានរៀល (៤៥,២%) វិស័យកសិកម្មចំនួន ២៣០,៦ពាន់លានរៀល (៧៥,៥%) វិស័យកម្មន្តសាលចំនួន ១៧៣,២ពាន់លានរៀល(២៧,៧%) វិស័យអចលនទ្រព្យនិងការប្រើប្រាស់សាធារណៈចំនួន ១៤០,៦ពាន់លានរៀល (២៨,៤%) វិស័យនាំចូលចំនួន ១១៣,២ពាន់លានរៀល (៤៩,៣%) វិស័យហិរញ្ញវត្ថុចំនួន ១៣,៨ពាន់លានរៀល (៣៧,៨%) វិស័យនាំចេញចំនួន ៧,២ពាន់លានរៀល (៥២,៧%) ខណៈដែលវិស័យសំណង់បានថយចុះចំនួន ១០,៨ពាន់លានរៀល (១,៧%) ។

### ២.២.១. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា

ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៨ បានថយចុះចំនួន ១.១៤៥,៦ពាន់លានរៀល (៣២,២%) ពោលគឺថយចុះពី -៣.៥៦០,៩ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៧ មក -៤.៧០៦,៥ពាន់លានរៀល ក្នុងខែមិថុនា ឆ្នាំ២០០៨ នេះ បន្ទាប់ពីបានថយចុះចំនួន ៤៣៣,៣ពាន់លានរៀល (១៨,៥%) ក្នុងឆមាសទី១ ឆ្នាំ២០០៧ ។ ការថយចុះនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ គឺបណ្តាលមកពីការថយចុះនៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលចំនួន ៨០២,៦ពាន់លានរៀល (៤៩,២%) ការថយចុះនៃផ្នែកផ្សេងៗសុទ្ធចំនួន ៣២២,៧ពាន់លានរៀល (១៨,១%) និងការថយចុះនៃឥណទេយ្យសុទ្ធពីបណ្តាធនាគារពាណិជ្ជចំនួន ២០,៣ពាន់លានរៀល (១៣,៤%) ។ ការថយចុះនៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល គឺបណ្តាលមកពីការកើនឡើងនៃប្រាក់បញ្ញើរាជរដ្ឋាភិបាលចំនួន ៧៧៦,១ពាន់លានរៀល (៤០,២%) រួមទាំងការថយចុះនៃឥណទានចំពោះរាជរដ្ឋាភិបាលចំនួន ២៦,៥ពាន់លានរៀល (៨,៩%) ។

ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៨ នេះដែរ ទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងចំនួន ២.២០៣,៤ពាន់លានរៀល (២៥,៧%) ។ កំណើនទាំងអស់នេះបណ្តាលមកពីការកើនឡើងទាំងស្រុងនៃទ្រព្យសកម្មបរទេសចំនួន ២.២០៣,៤ពាន់លានរៀល (២៥,៧%) ខណៈដែលទ្រព្យអកម្មបរទេសពុំមានការប្រែប្រួល ។ គួរកត់សម្គាល់ថា ថ្លៃមាសដែលជាធាតុផ្សំមួយនៃទ្រព្យសកម្មបរទេសនៅតែបន្តកើនយ៉ាងលឿនក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ។

### ២.២.២. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ

ក្នុងឆមាសទី១ ឆ្នាំ២០០៨ ទ្រព្យសកម្មសរុបរបស់បណ្តាធនាគារពាណិជ្ជបានកើនឡើងចំនួន ២.៧០៧,៦ពាន់លានរៀល (២០%) ក្នុងខណៈទ្រព្យអកម្មក្នុងស្រុកក្នុងរូបភាពជាប្រាក់បញ្ញើបានកើនឡើងចំនួន ១.០១០,៣ពាន់លានរៀល (១០,៩%) ។

ទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន ២.០១០,៤ពាន់លានរៀល (៥០%) ។ ការកើនឡើងនេះជាចម្បងបណ្តាលមកពីការកើនឡើងនៃឥណទានចំពោះផ្នែកឯកជនចំនួន ២.៨២០,៣ពាន់លានរៀល (៤៤,២%) ចំណែកខ្ទង់ផ្សេងៗសុទ្ធបានថយចុះចំនួន ៧៤១,៤ពាន់លានរៀល (៣៤,៦%) និងឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលបានថយចុះចំនួន ៥៩,៩ពាន់លានរៀល (៣២,៦%) ។ ការថយចុះនៃខ្ទង់ផ្សេងៗសុទ្ធឆ្លុះបញ្ចាំងនូវកំណើននៃដើមទុនរបស់ធនាគារពាណិជ្ជមួយចំនួន រួមទាំងដើមទុនរបស់ធនាគារទើបបើកថ្មីខ្លះទៀត សរុបកើនឡើងចំនួន ៨០០,១ពាន់លានរៀល (៣៧,៦%) ព្រមទាំងការកើនឡើងនៃទ្រព្យអកម្មផ្សេងៗចំនួន ២៤៦,៧ពាន់លានរៀល (៣៥,៥%) ខណៈដែលទ្រព្យសកម្មផ្សេងៗកើនឡើងចំនួន ២៩៩,៣ពាន់លានរៀល (៤១,៩%) និងប្រាក់បញ្ញើធានាលើដើមទុនថយចុះចំនួន ៦,២ពាន់លានរៀល (១៩,៩%) ។ ទន្ទឹមនេះដែរ ប្រាក់បញ្ញើរបស់បណ្តាធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជាដែលជាធាតុផ្សំនៃទុនបម្រុងអន្តរជាតិបានកើនឡើងចំនួន ៥៦៥,២ពាន់លានរៀល (១៨,៣%) ។

ទ្រព្យសកម្មបរទេសសុទ្ធរបស់បណ្តាធនាគារពាណិជ្ជបានថយចុះចំនួន ១.៥៨៥,៥ពាន់លានរៀល (៧៣,៦%) ពោលគឺថយចុះពី ២.១៥៥,៦ពាន់លានរៀល នៅខែធ្នូ ឆ្នាំ២០០៧ មក ៥៧០,១ពាន់លានរៀល ក្នុងខែមិថុនា ឆ្នាំ២០០៨ ។ ការថយចុះនេះបណ្តាលមកពីការថយចុះនៃទ្រព្យសកម្មបរទេសចំនួន ៩៩៦,៩ពាន់លានរៀល (៣០,១%) និងការកើនឡើងនៃទ្រព្យអកម្មបរទេសចំនួន ៥៨៨,៦ពាន់លានរៀល (៥០,៩%) ។

ប្រាក់បញ្ញើជារូបិយប័ណ្ណរបស់និវាសជន ដែលជាធាតុផ្សំចម្បងនៃទ្រព្យអកម្មក្នុងស្រុកបានកើនឡើងចំនួន ៩៤៣,៧ពាន់លានរៀល (១០,៣%) រួមជាមួយនិងប្រាក់បញ្ញើចរន្តបានកើនឡើងចំនួន ៣៨ពាន់លានរៀល (៧៦,៨%) និងប្រាក់បញ្ញើមានកាលកំណត់និងសន្សំបានកើនឡើងចំនួន ២៨,៦ពាន់លានរៀល (២៣,៧%) ។

### ២.៣. អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ

ផ្អែកលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ ធនាគារជាតិនៃកម្ពុជាបន្តអនុវត្តសេរីភាវូបនីយកម្មទៅលើអត្រាការប្រាក់ចំពោះប្រតិបត្តិការរបស់ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ នាឆមាសទី១ នេះ ក្នុងគោលដៅសម្រាលសម្ពាធអតិផរណា ធនាគារជាតិនៃកម្ពុជាបានសម្រេចកាត់បន្ថយបរិមាណរូបិយវត្ថុនៅលើទីផ្សារតាមរយៈការតម្លើងអត្រាប្រាក់បម្រុងកាតព្វកិច្ចពី ៨% ទៅ ១៦% ដែលសកម្មភាពនេះអាចរឹតត្បិតបរិមាណឥណទាន និងមានឥទ្ធិពលទៅលើអត្រាការប្រាក់របស់ប្រព័ន្ធធនាគារទាំងមូល ។ ជាទូទៅ គ្រឹះស្ថានធនាគារទាំងឡាយបន្តមានសេរីភាពពេញលេញក្នុងការកំណត់អត្រាការប្រាក់របស់ខ្លួនដដែល ។

ក្នុងកំឡុង ៦ខែដើមឆ្នាំ២០០៨ នេះ អត្រាការប្រាក់ឥណទាននិងប្រាក់បញ្ញើជារូបិយវត្ថុក្នុងស្រុក និងជាប្រាក់ដុល្លារអាមេរិក ដែលវាស់ដោយកម្រិតមធ្យមថ្លឹងតាមទំហំនៃប្រតិបត្តិការធនាគារសម្រាប់រយៈពេល៦ខែ មិនមានការប្រែប្រួលគួរឱ្យកត់សម្គាល់នោះទេ ។ អត្រាការប្រាក់កម្ចីជាប្រាក់រៀលបានប្រែប្រួលពី ១៨,៩៩% ដល់ ១៩% រីឯអត្រាការប្រាក់កម្ចីជាប្រាក់ដុល្លារអាមេរិកវិញបានប្រែប្រួលពី ១៦,៦៩% មក ១៦,៤៥% ។ ទន្ទឹមគ្នានោះដែរ អត្រា ការប្រាក់បញ្ញើជារៀលនិងជាដុល្លារអាមេរិកបានប្រែប្រួលពី ៦,០៥% ដល់ ៦,៣៦% និងពី ៤,២២% ដល់ ៤,៣៣% រៀងគ្នា ។

**តារាងអត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើ**

**(អត្រាមធ្យម ៦ខែ)**

| | ធ្នូ_០៧ | មករា_០៨ | កុម្ភៈ_០៨ | មីនា_០៨ | មេសា_០៨ | ឧសភា_០៨ | មិថុនា_០៨ |
|---|---|---|---|---|---|---|---|
| អត្រាការប្រាក់កម្ចីជារៀល | ១៩,០១% | ១៨,៩៩% | ១៩,១២% | ១៩,១២% | ១៩,២០% | ១៩,០៦% | ១៩,០០% |
| អត្រាការប្រាក់កម្ចីជាដុល្លារ | ១៦,៧៧% | ១៦,៦៩% | ១៦,៥២% | ១៦,៥២% | ១៦,៤២% | ១៦,៣៥% | ១៦,៤៥% |
| អត្រាការប្រាក់បញ្ញើជារៀល | ៦,០០% | ៦,០៥% | ៦,០៣% | ៦,២៨% | ៦,២៨% | ៦,៣១% | ៦,៣៦% |
| អត្រាការប្រាក់បញ្ញើជាដុល្លារ | ៤,២៣% | ៤,២២% | ៤,២៧% | ៤,២៧% | ៤,៣០% | ៤,២៩% | ៤,៣៣% |

## ៣_ ជញ្ជីងទូទាត់

ការប៉ាន់ស្មានដំបូងលើប្រតិបត្តិការស្ថិតិជញ្ជីងទូទាត់របស់ប្រទេសកម្ពុជា សម្រាប់ឆមាសទី១ ឆ្នាំ២០០៨ នេះបានបង្ហាញថា សមតុល្យរួមមានអតិរេកចំនួន ២៥៣,២លានដុល្លារអាមេរិក គឺបានកើនឡើង ១០២,៤លានដុល្លារអាមេរិក (៦៧,៩%) ធៀបនឹងឆមាសដូចគ្នានៃឆ្នាំ២០០៧ ។ ការកើនឡើងសមតុល្យរួមនេះ គឺបណ្តាលមកពីការកើនឡើងសមតុល្យគណនីដើមទុន និងហិរញ្ញវត្ថុចំនួន ៥៥,៦% ស្របពេលដែលឱនភាពគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្ទេរការ) មានកំណើនដល់ ៦៦% ។ ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ផលធៀបនៃឱនភាពគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្ទេរការ) និងផលិតផលក្នុងស្រុកសរុបមានកម្រិត ១០% ធៀបនឹងកម្រិតប្រហាក់ប្រហែលគ្នា នៅឆមាសទី១ ឆ្នាំ២០០៧ ប្រមាណ ៩,៤% ។

### ៣.១_ គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្ទេរការ)

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ សមតុល្យគណនីចរន្តមានឱនភាពចំនួនប្រមាណ ៣០៩,៧លានដុល្លារអាមេរិក គឺបានកើនឡើង ១២៣,១លានដុល្លារអាមេរិក (៦៦%) ធៀបនឹងឆមាសទី១ ឆ្នាំ២០០៧ ។ មូលហេតុដែលធ្វើឱ្យមានការកើនឡើងឱនភាពសមតុល្យគណនីចរន្តនេះ គឺដោយសារមានកំណើនឱនភាពជញ្ជីងពាណិជ្ជកម្មប្រមាណ ២៣,១% និងឱនភាពគណនីប្រាក់ចំណូលសុទ្ធប្រមាណ ៣៣,៥% ស្របពេលដែលអតិរេកនៃគណនីសេវាសុទ្ធបានកើនឡើងប្រមាណ ២៧,៦% ក្នុងខណៈដែលគណនីបង្វែរឯកជនសុទ្ធបានថយចុះប្រមាណ ១៥,៨% ។

តម្លៃនៃការនាំចេញផលិតផលក្នុងស្រុកក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ មានចំនួនប្រមាណ ២,៤ពាន់លានដុល្លារអាមេរិក គឺបានកើនឡើង ៤៤៨,៤លានដុល្លាអាមេរិក (២២,៨%) ធៀបនឹងឆមាសទី១ នៃឆ្នាំកន្លងទៅ ។ កត្តារួមចំណែកយ៉ាងសំខាន់ក្នុងកំណើននេះ គឺការកើនឡើងនៃការនាំចេញសម្លៀកបំពាក់និងផលិតផលវាយនភ័ណ្ឌប្រមាណ ១៨៣,៣លានដុល្លារអាមេរិក និងការនាំចេញផលិតផលក្នុងស្រុកផ្សេងទៀតប្រមាណ ២៦៥,២លានដុល្លារអាមេរិក ។ ការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ មានកំណើនប្រមាណ ១៣,៤% ធៀបនឹងឆមាសដូចគ្នានៃឆ្នាំ២០០៧ ដែលមានកំណើនប្រមាណ ១៣% ។ ទាំងនេះគឺដោយសារនយោបាយរបស់សហរដ្ឋអាមេរិកនិងអឺរ៉ុប នៅមិនទាន់បើកទូលាយចំពោះការនាំចូលផលិតផលវាយនភ័ណ្ឌពីប្រទេសចិននៅឡើយ ។ ដូច្នេះការនាំចេញផ្នែកនេះរបស់ប្រទេសកម្ពុជានៅតែមានប្រៀបក្នុងការប្រកួតប្រជែងជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត ។ ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ការនាំចេញសម្លៀកបំពាក់និងផលិតផលវាយនភ័ណ្ឌមានសមាមាត្រ ៦៥,៩% នៃការនាំចេញផលិតផលក្នុងស្រុក ។ ទន្ទឹមនឹងនេះ ការនាំចេញផលិតផលក្នុងស្រុកផ្សេងទៀត ជាពិសេសការនាំចេញផលិតផលកសិកម្មបានកើនឡើងប្រមាណ ៤៤,៧% ក្នុងនោះ ការនាំចេញស្រូវ ៦៧,៦% កៅស៊ូ ២២,៩% ត្រី ២០,៤% គ្រឿងសង្ហារឹម ៥,៩% និងផលិតផលផ្សេងៗ ១៤,២% ។



ក្រាហ្វិក ៦ : ជញ្ជីងពាណិជ្ជកម្ម

ទិន្នន័យបាន់ស្មាន

តម្លៃនៃការនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកមានចំនួនប្រមាណ ៣,១ពាន់លានដុល្លារអាមេរិក គឺបានកើនឡើង ៥៨៣,៩លានដុល្លារអាមេរិក (២៣,១%) ធៀបនឹងឆមាសដូចគ្នានៃឆ្នាំកន្លងទៅ ។ កត្តាចម្បងរួមចំណែកក្នុងកំណើននេះ គឺការកើនឡើងនៃការនាំចូលប្រេងឥន្ធនៈ ២៣៤,២លានដុល្លារអាមេរិក (៣៣,៥%) ។ តម្លៃនៃការនាំចូលប្រេងឥន្ធនៈមានសមាមាត្រ ៣០,១% នៃការនាំចូលទំនិញប្រើប្រាស់ក្នុងស្រុក ។ ចំណែកការនាំចូលទំនិញប្រើប្រាស់ក្នុងស្រុកផ្សេងទៀត ដូចជា ការនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់មានកំណើន ១៣% និងការនាំចូលទំនិញផ្សេងៗមានកំណើន ២២,៦% ។

ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៨ នេះ អតិរេកនៃគណនីសេវាសុទ្ធមានចំនួនប្រមាណ ៤០៦,១លានដុល្លារអាមេរិក ពោលគឺបានកើនឡើង ៨៧,៨លានដុល្លារអាមេរិក (២៧,៦%) ធៀបនឹងឆមាសទី១ ឆ្នាំ២០០៧ ។ ការកើនឡើងនៃអតិរេកនេះ ជាលទ្ធផលនៃកំណើនប្រាក់ចំណូលពីផ្នែកសេវាប្រមាណ ១៤៧,៤លានដុល្លារអាមេរិក ស្របពេលដែលចំណាយទូទាត់សេវាទៅឱ្យអនិវាសជនបានកើនឡើង ៥៩,៦លានដុល្លារអាមេរិក ។ ចំណូលពីសេវាធ្វើដំណើរ និងសេវាដឹកជញ្ជូន បានរួមចំណែកយ៉ាងសំខាន់ក្នុងកំណើននៃប្រាក់ចំណូលនេះ ។ ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយអនុញ្ញាតឱ្យមានការហោះហើរត្រង់មកខេត្តសៀមរាបពីបណ្តាប្រទេសមួយចំនួនបន្ថែមទៀត ដូចជា ប្រទេសចិន កូរ៉េ និងជប៉ុន ដែលបានធ្វើឱ្យចំនួនភ្ញៀវបរទេសចូលមកទស្សនាប្រទេសកម្ពុជាក្នុងឆមាសទី១ ឆ្នាំ ២០០៨ នេះ មានការកើនឡើងដល់ ១.០៩៨.២៣៦នាក់ ដែលចំនួននេះមានត្រឹមតែ ៩៧៥.៣៤៩នាក់ ក្នុងឆមាសទី១ ឆ្នាំ២០០៧ ។ ក្នុងនោះភ្ញៀវទេសចរមកពីប្រទេសកូរ៉េមានសមាមាត្រខ្ពស់ជាងគេ ១៥,២% និងភ្ញៀវមកពីប្រទេស វៀតណាម ៩% ជប៉ុន ៧,៣% អាមេរិក ៧,២% និងចិន ៦,៤%។ ចំពោះគណនីប្រាក់ចំណូលសុទ្ធមានឱនភាពចំនួនប្រមាណ ២១១,៧លានដុល្លារអាមេរិក គឺបានកើនឡើងចំនួន ៥៣,២លានដុល្លារអាមេរិក(៣៣,៥%) ធៀបនឹង ៦ខែ ដើមឆ្នាំ២០០៧ ។ ការកើនឡើងនៃឱនភាពនេះ គឺដោយសារការកើនឡើងការផ្ទេរចេញនូវប្រាក់ចំណូលទៅឱ្យអនិវាសជន ។ ចំណែកគណនីបង្វែរឯកជនសុទ្ធ ក្នុងឆមាសទី១ ឆ្នាំ២០០៨ មានអតិរេកចំនួនប្រមាណ ១៦៨,៧លាន ដុល្លារអាមេរិក គឺបានថយចុះ ៣១,៧លានដុល្លារអាមេរិក (១៥,៨%) ធៀបនឹងឆមាសដូចគ្នាក្នុងឆ្នាំ២០០៧ ។ ការថយចុះអតិរេកគណនីនេះ គឺដោយសារមានការថយចុះការផ្ទេរប្រាក់របស់ជនជាតិកម្ពុជាពីក្រៅប្រទេស ដែលបណ្តាលមកពីការកើនឡើងយឺតនៃសេដ្ឋកិច្ចសកល ។

### ៣.២_ គណនីដើមទុន និងហិរញ្ញវត្ថុ

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ សមតុល្យគណនីចរន្តនិងបង្វែរដើមទុនមានឱនភាព ៩៤លានដុល្លារអាមេរិក ខណៈដែលសមតុល្យនេះមានអតិរេក ២១,៤លានដុល្លារអាមេរិក ក្នុងឆមាសដូចគ្នានៃឆ្នាំ២០០៧ ។ គណនីបង្វែរផ្លូវការសុទ្ធមានលំហូរចូលប្រមាណ ២១៥,៧លានដុល្លារអាមេរិក គឺបានកើនឡើង ៧,៧លានដុល្លារអាមេរិក (៣,៧%) ធៀបនឹងលំហូរចូលក្នុងឆមាសទី១ ឆ្នាំ២០០៧ ។ គណនីនេះបង្ហាញពីលំហូរហិរញ្ញប្បទានសហប្រតិបត្តិការ ដែលរាជរដ្ឋាភិបាលកម្ពុជាទទួលបានពីសហគមន៍អន្តរជាតិទាំងពហុនិងទ្វេភាគី ក្នុងនោះរួមមាន ហិរញ្ញប្បទានសម្រាប់ទ្រទ្រង់ថវិកា ១២,៨លានដុល្លារអាមេរិក ហិរញ្ញប្បទានសម្រាប់ស្បៀងអាហារ ១៥,៧លានដុល្លារអាមេរិក ហិរញ្ញប្បទានសម្រាប់គម្រោង ៩៧,៦លានដុល្លារអាមេរិក និងហិរញ្ញប្បទានសម្រាប់ជំនួយបច្ចេកទេស ៨៩,៨លានដុល្លារអាមេរិក ។ ទន្ទឹមនឹងនេះ លំហូរហិរញ្ញប្បទានជាប្រាក់កម្ចីផ្លូវការសុទ្ធ (មិនរាប់បញ្ចូលប្រាក់កម្ចីពីមូលនិធិរូបិយវត្ថុអន្តរជាតិ) មានចំនួនប្រមាណ ៨២,២លានដុល្លារអាមេរិក គឺបានកើនឡើង ២៣,៤% ធៀបនឹងឆមាសដូចគ្នានៃឆ្នាំកន្លងទៅ ។ ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ លំហូរវិនិយោគផ្ទាល់បរទេសសុទ្ធមានចំនួនប្រមាណ ៣៩៦លានដុល្លារអាមេរិក គឺបានកើនឡើង ៤,៨% ធៀបនឹងឆមាសទី១ ឆ្នាំ២០០៧ ។ កត្តាចម្បងនៃការកើនឡើងនេះ ដោយសារមានលំហូរចូលនៃការវិនិយោគផ្ទាល់បរទេសផ្នែកធនាគារប្រមាណ ១៤៩,៨លានដុល្លារអាមេរិក និងផ្នែកសហគ្រាសប្រមាណ ២៤៦,២លានដុល្លារអាមេរិក ។



ទិន្នន័យបឋម

ការកើនឡើងនៃគណនីដើមទុននិងហិរញ្ញវត្ថុ បានបង្ហាញពីលទ្ធភាពទ្រទ្រង់បានដើម្បីផាត់ទាត់ឱ្យឱនភាពគណនីចរន្តទាំងស្រុង ។ ជាលទ្ធផលនៃប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ សមតុល្យរួមមានអតិរេក ២៥៣,២លានដុល្លារអាមេរិក ។ គិតដល់ចុងខែមិថុនា ឆ្នាំ២០០៨ ទុនបម្រុងបរទេសដុលអាចធានាឱ្យការទូទាត់ទំនិញនិងសេវានាំចូលបានប្រមាណ ៣ខែ ។

## ៤_ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

### ៤_១_ការងារវិនិយោគទុនបម្រុងអន្តរជាតិ

គិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០០៨ ទុនបម្រុងវិនិយោគ[២] គិតជាប្រាក់ដុល្លារអាមេរិក ដោយមិនគិតបញ្ចូលមាស និង SDR ចំនួន ៤៩.០៥២SDR មានចំនួនសរុប ២.១៩៧លានដុល្លារអាមេរិក ពោលគឺកើនឡើង ២៤% បើប្រៀបធៀបនឹងចុងខែធ្នូ ឆ្នាំ២០០៧ ដែលមានចំនួន ១.៧៦៦,៥លានដុល្លារអាមេរិក និងកើនឡើង ៦២% បើធៀបចុងឆមាសទី១ ឆ្នាំ២០០៧ ។

ធនាគារជាតិនៃកម្ពុជាវិនិយោគទុនបម្រុងទាំងនេះក្រោមរូបភាពជា Overnight ជាការទិញប័ណ្ណរតនាគារអាមេរិក ជាប្រាក់បញ្ញើរយៈកាលខ្លី ជាឧបករណ៍រយៈកាលមធ្យម (MTI) និងជាសញ្ញាប័ណ្ណរយៈកាលវែងនៅប្រទេសបារាំង លុចហ្សំបួរ ស្វីស សហរដ្ឋអាមេរិក ហុងកុង សិង្ហបុរី និងជប៉ុន ។ ដោយឡែក ប្រតិបត្តិការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាមានកាតព្វកិច្ចតែលើការចំណាយសង Net charge SDR និង Assessment SDR ដែលមានចំនួន ២៤៣.៦៤៩ SDR ប៉ុណ្ណោះ ហើយកាតព្វកិច្ចនេះត្រូវបានផ្ទេរសងគ្រប់ចំនួនតាមផែនការគ្រោង ។

[២] *ទុនបម្រុងវិនិយោគ រួមមាន ទុនបម្រុងអន្តរជាតិ ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារ និងកម្ចីពីបរទេសរបស់រាជរដ្ឋាភិបាល*

នៅក្នុងឆមាសទី១ ឆ្នាំ២០០៨ បញ្ហា (Sub-prime mortgage) នៅអាមេរិកនៅតែបន្តជះឥទ្ធិពលមកលើសេដ្ឋកិច្ចអាមេរិក និងតំបន់អឺរ៉ុប ។ ប្រការនេះបានធ្វើឱ្យអត្រាការប្រាក់ដុល្លារអាមេរិកត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ ដោយបានថយចុះពី ៣% មកនៅត្រឹម ២% ។ អត្រាការប្រាក់អឺរ៉ូត្រូវបានរក្សានៅកម្រិត ៤% ដដែល ហើយអត្រាការប្រាក់ផោនស្ទែរលីងត្រូវបានកាត់បន្ថយចំនួន ៥០ ពិន្ទុ គឺពី ៥,៥០% មកត្រឹម ៥% ។ ដោយឡែក អត្រាការប្រាក់ដុល្លារអូស្ត្រាលីបានកើនពី ៧% ទៅ ៧,២៥% ។ ការកាត់បន្ថយអត្រាការប្រាក់គោលប្រាក់ដុល្លារបណ្តាលឱ្យអត្រាការប្រាក់ Overnight ប្រែប្រួលក្នុងរង្វង់ ៤,១៥% ទៅ ០,៣២% អត្រាការប្រាក់ប័ណ្ណរតនាគារអាមេរិកប្រែប្រួលក្នុងរង្វង់ ២,៩៨៧% ទៅ ១,៣៣៧% អត្រាការប្រាក់បញ្ញើរយៈកាលខ្លីប្រែប្រួលក្នុងរង្វង់ ៤,៤៥% ទៅ ១,៨២% ។ រីឯអត្រាការប្រាក់ជាប្រាក់អឺរ៉ូប្រែប្រួលក្នុងរង្វង់ ៤,៦៣% ទៅ ៣,៨១% ជាប្រាក់ដុល្លារអូស្ត្រាលីប្រែប្រួលពី ៦,៧៥% ទៅ ៧,៧៥% និងជាប្រាក់ផោនស្ទែរលីងបានទទួលអត្រាការប្រាក់ ៥,៨១% ។ ដោយសារមានការត្រៀមលក្ខណៈជាមុនដើម្បីទប់ទល់នឹងនិន្នាការធ្លាក់ចុះនៃអត្រាការប្រាក់ដុល្លារ ចំណូលពីការវិនិយោគនៅក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ នៅតែទទួលបានលទ្ធផលល្អប្រសើរបើធៀបនឹងរយៈពេលដូចគ្នានៃឆមាសទី១ ឆ្នាំ២០០៧ ដោយទទួលបានចំណូល ៣៤,៩លានដុល្លារអាមេរិក ពោលគឺបានកើនឡើងប្រមាណ ១៣% បើធៀបនឹងឆមាសទី១ ឆ្នាំ២០០៧ ។ គិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០០៨ ទុនបម្រុងវិនិយោគសរុបមានចំនួន ២,២ពាន់លានដុល្លារអាមេរិក ។

## ៤.២. អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់

ដើម្បីបំពេញតម្រូវការនៅលើទីផ្សារ ជាមួយនឹងគោលដៅរក្សាស្ថិរភាពតម្លៃប្រាក់រៀល នៅក្នុងឆមាសទី១ ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកចំនួន ៧៨លើក ដែលមានទឹកប្រាក់សរុបចំនួន ២៣២,២៨ លានដុល្លារអាមេរិក និងបានចំណាយប្រាក់រៀលអស់ចំនួន ៩២៩,៣ពាន់លានរៀល ដែលធ្វើឱ្យបរិមាណទុនបម្រុងជារូបិយប័ណ្ណបានកើនឡើងមួយកម្រិតថែមទៀត ។ ការទិញប្រាក់ដុល្លារនៅក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ មានកម្រិតខ្ពស់ជាខ្លាំង ពោលគឺស្មើនឹង ២,៤៦ដង បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំកន្លងមក ។

នៅក្នុងឆមាសទី១ ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានលក់ប្រាក់ដុល្លារអាមេរិកចំនួន ៨លើក ដែលមានទឹកប្រាក់ចំនួន ៣,៦លានដុល្លារ ដោយបានស្រូបយកសាច់ប្រាក់រៀលពីទីផ្សារចំនួន ១៤.៧៨៩,៧លានរៀល ។

## ៤.៣. ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់

ក្នុងឆមាសទី១ ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានផ្តល់លិខិតអនុញ្ញាតដល់អាជីវករលក់មាស និងប្តូរប្រាក់នៅរាជធានីភ្នំពេញសរុបចំនួន ២៧១ច្បាប់ ក្នុងនោះ អាជីវករលក់មាសចំនួន ២៥០ច្បាប់ អាជីវករប្តូរប្រាក់ចំនួន ២១ច្បាប់ ។ ការផ្តល់លិខិតអនុញ្ញាតក្នុងឆមាសទី១ នេះ មានការកើនឡើងចំនួន ១៤០ច្បាប់ បើធៀបទៅនឹងឆមាសទី១ ឆ្នាំ២០០៧ ។ ចំណែកអាជីវករនៅតាមបណ្តាខេត្ត-ក្រុងចំនួន១៧ សាខាធនាគារជាតិនៃកម្ពុជាបានផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មលក់មាសចំនួន ២.៦៨៤ច្បាប់ អាជីវកម្មប្តូរប្រាក់ចំនួន ៦១៥ច្បាប់ សរុបចំនួន ៣.២៩៩ ច្បាប់ ។

## ៥. សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

### ៥.១. ការត្រួតពិនិត្យធនាគារពាណិជ្ជ និងធនាគារឯកទេស

ធនាគារជាតិនៃកម្ពុជានៅតែបន្តការបណ្តុះបណ្តាល កសាង និងអភិវឌ្ឍសមត្ថភាពដល់មន្ត្រីបុគ្គលិក ដើម្បីបង្កើនធនធានមនុស្សនិងការងារឱ្យមានប្រសិទ្ធភាពនិងតម្លាភាពទាំងការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងពិនិត្យតាមដានការអនុវត្តប្រកាស បទបញ្ជា សារាចរណែនាំដែលបានចេញផ្សាយផងដែរ ។

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ការផ្តល់ឥណទានសរុបបានកើនឡើងចំនួន ៨៣% បើធៀបនឹងឆមាសទី១ ឆ្នាំ២០០៧ និងកើនឡើងចំនួន ៥២% បើធៀបនឹងឆមាសទី២ ឆ្នាំ២០០៧ ។ ចំណែកឯប្រាក់បញ្ញើរបស់អតិថិជនបានកើនឡើង ២៦% បើធៀបនឹងឆមាសទី១ ឆ្នាំ២០០៧ និងបានកើនឡើង ១២% បើធៀបនឹងឆមាសទី២ ឆ្នាំ២០០៧ ។ ចំណែកឯប្រាក់បញ្ញើអតិថិជនមានចំនួន ៤៥៦.០២៦គណនី នៅឆ្នាំ២០០៧ បានកើនឡើងដល់ចំនួន ៦៣៩.៥២២ គណនី និងម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) មានចំនួន ២៣១គ្រឿង គិតត្រឹមត្រីមាសទី១ ឆ្នាំ២០០៨ ។

#### ៥.១.១. ការត្រួតពិនិត្យលើឯកសារ

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ សកម្មភាពអាជីវកម្មរបស់គ្រឹះស្ថានធនាគារមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយធនាគារទាំងអស់កំពុងធ្វើប្រតិបត្តិការដោយការប្រកួតប្រជែង ដែលឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈការបើកសាខាថ្មីចំនួន ៨ នៅតាមបណ្តាខេត្ត-ក្រុងសំខាន់ៗ ការបញ្ចុះអត្រាការប្រាក់ និងការបង្កើនដើមទុនជាដើម ។

តាមរយៈការវិភាគលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០០៧ តាមប្រព័ន្ធ COBRA បានបង្ហាញថាស្ថានភាពរបស់ធនាគារមួយចំនួនធំមានស្ថានភាពល្អ និងមួយចំនួនតូចមានស្ថានភាពមធ្យមត្រូវកែលំអ ដូចជាបញ្ហាឱនភាពមូលនិធិផ្ទាល់សុទ្ធ ការផ្តល់ឥណទានដោយផ្អែកយ៉ាងខ្លាំងលើអចលនទ្រព្យធ្វើជាវត្ថុធានាបំណុល សវិធានធនមានកម្រិតទាបខណៈដែលឥណទានបានកើនឡើងយ៉ាងលឿន និងធនាគារមួយភាគតូចបានផ្តល់ឥណទានលើសកម្រិត ២០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួនជាដើម ។ ក្រៅពីការវិភាគលើស្ថានភាពរបស់ធនាគារ របាយការណ៍ស្តីពីការត្រួតពិនិត្យគ្រឹះស្ថានធនាគារលើកទី៣ត្រូវបានរៀបចំ និងបានផ្សព្វផ្សាយជាសាធារណៈ ។

#### ៥.១.២. ការត្រួតពិនិត្យដល់ទីកន្លែង

នៅក្នុងឆមាសទី១ ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានសម្រេចដាក់ចេញនូវផែនការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជ និងធនាគារឯកទេស ព្រមទាំងសាខាធនាគារដែលស្ថិតនៅតាមបណ្តាខេត្ត ដែលក្នុងនោះមានសាខាធនាគារបរទេសផងដែរ ។

ក្នុងឆមាសទី១ ឆ្នាំ២០០៨នេះ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ការត្រួតពិនិត្យដល់ទីកន្លែងតាមវិសាលភាពពេញលេញលើធនាគារពាណិជ្ជចំនួន ៥ ក្នុងនោះសាខាបរទេសចំនួន ១ ។ ការត្រួតពិនិត្យដល់ទីកន្លែងនេះមានទិសដៅ និងគោលបំណងធ្វើការតាមដាននិងពិនិត្យពីស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ប្រតិបត្តិការអាជីវកម្ម ព្រមទាំងការវាយតម្លៃពីភាពពិតប្រាកដ និងភាពត្រឹមត្រូវជាក់លាក់នៃព័ត៌មានហិរញ្ញវត្ថុរបស់ធនាគារទាំងនោះ ។ ទន្ទឹមនោះ ការត្រួតពិនិត្យដល់ទីកន្លែងនេះបានយកចិត្តទុកដាក់ពិនិត្យលើការអនុវត្តរបស់គ្រឹះស្ថានទាំងនោះទៅតាមប្រកាស សារាចរណែនាំ បទប្បញ្ញត្តិប្រុងប្រយ័ត្ន និងច្បាប់នានា ដើម្បីគ្រប់គ្រងនិងការពារហានិភ័យ ។ រាល់បណ្តាចំណុចខ្វះខាត និងកំហុសឆ្គងដែលបានរកឃើញក្នុងអំឡុងពេលត្រួតពិនិត្យ នឹងត្រូវផ្តល់ជាអនុសាសន៍ និងដាក់ចេញជាវិធានការចាំបាច់ និងកំណត់ពេលវេលា ដើម្បីឱ្យសាមីធនាគារធ្វើការកែតម្រូវជាបន្តបន្ទាប់ ។

## ៥.២_ ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

វិស័យហិរញ្ញវត្ថុជនបទនៅកម្ពុជាមានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស ទាំងវិសាលភាព និងទំហំប្រតិបត្តិការ ។ ឥណទានរបស់វិស័យមីក្រូហិរញ្ញវត្ថុមានកំណើនគួរឱ្យកត់សម្គាល់ ដែលរួមចំណែកគាំទ្រដល់ការអភិវឌ្ឍអាជីវកម្មធុនតូច មធ្យម និងវិស័យកសិកម្មនៅកម្ពុជា ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទបានផ្តល់ឥណទានសរុបប្រមាណ ៨៥១ពាន់លានរៀល ដល់អ្នកខ្ចីប្រាក់ចំនួន ៦៧២.៧២៥នាក់ កើនឡើងចំនួន ៧៣% និង ២៥% រៀងគ្នា បើធៀបនឹងឆមាសទី១ ឆ្នាំ២០០៧ ។ ចំពោះប្រាក់បញ្ញើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ ប្រមូលប្រាក់សន្សំបានប្រមាណ ២៣ពាន់លានរៀល ពីអ្នកផ្ញើប្រាក់ចំនួន ១៦៦.៥៨៨នាក់ កើនឡើងចំនួន ៣១% និង ១៧ % រៀងគ្នា បើប្រៀបធៀបនឹងគ្រាដូចគ្នានាឆ្នាំ២០០៧ ។

ផ្អែកលើការត្រួតពិនិត្យជាទូទៅបានបង្ហាញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានដំណើរការអាជីវកម្ម និងស្ថានភាពហិរញ្ញវត្ថុល្អប្រសើរ ។ ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ក្រៅពីការអនុវត្តការត្រួតពិនិត្យលើឯកសារជាប្រចាំ ដើម្បីតាមដានប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងវិភាគរបាយការណ៍ ធនាគារជាតិនៃកម្ពុជាបានធ្វើការចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៧ និងប្រតិបត្តិករឥណទានជនបទចំនួន៤ សំដៅពិនិត្យមើលសកម្មភាពអាជីវកម្ម និងជាការត្រួតពិនិត្យជាប្រចាំផងដែរ ដើម្បីធានាថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទដែលបានចុះបញ្ជី អនុវត្តតាមច្បាប់ និងបទបញ្ញានានារបស់ធនាគារជាតិនៃកម្ពុជា ។

ដើម្បីរក្សាបានស្ថិរភាពនៃកំណើន និងនិរន្តរភាពចំពោះវិស័យមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជានៅតែបន្តត្រួតពិនិត្យតាមដាននិងដាក់ចេញបទបញ្ញានានា ដែលអនុលោមតាមស្តង់ដារ និងការអនុវត្តជាអន្តរជាតិ ដើម្បីឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានមូលដ្ឋានច្បាស់លាស់ក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅក្នុងទីផ្សារប្រកួតប្រជែងស្មើភាព ។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបន្តពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យ និងបន្តធ្វើកិច្ចសហប្រតិបត្តិការជាមួយភ្នាក់ងារជាតិនិងអន្តរជាតិនានា ដើម្បីក្បៀងគរការវិនិយោគ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុជនបទឱ្យកាន់

តែទូលំទូលាយ និងរួមចំណែកលើកកម្ពស់កម្រិតជីវភាពប្រជាជន និងកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនេះដែរ ការពង្រឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បីអាចទទួលប្រាក់បញ្ញើពីសាធារណជន កំពុងតែប្រព្រឹត្តិទៅដោយការខិតខំរបស់គ្រឹះស្ថានផ្ទាល់ និងមានការជួយជ្រោមជ្រែងពីធនាគារជាតិនៃកម្ពុជា និងការគាំទ្រផ្នែកបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី ។

## ៥.៣. ការងាររៀបចំបទបញ្ញា

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ក្រុមការងារច្បាប់បានពិនិត្យឡើងវិញនូវប្រកាស បទប្បញ្ញត្តិ បទបញ្ជា និងសារាចរណែនាំដែលបានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត ក្នុងគោលបំណងពិនិត្យឡើងវិញនូវប្រកាស និងបទប្បញ្ញត្តិទាំងឡាយណាដែលហួសសម័យ និងរៀបចំជាថ្មី ដើម្បីជំនួសឱ្យប្រកាសនិងបទប្បញ្ញត្តិទាំងនោះ ។ ជាលទ្ធផលប្រកាសមួយចំនួនត្រូវបានធ្វើវិសោធនកម្មរួមមាន :

- ប្រកាសស្តីពីការតម្កល់ប្រាក់បំរុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ
- ប្រកាសស្តីពី ភតិសន្យាហិរញ្ញវត្ថុ
- ប្រកាសស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

## ៥.៤. អាជ្ញាប័ណ្ណ និងចុះបញ្ជី

ធនាគារជាតិនៃកម្ពុជាមានភារកិច្ចទទួលខុសត្រូវលើការផ្តល់ព័ត៌មាន និងរាល់ឯកសារដែលពាក់ព័ន្ធក្នុងការស្នើសុំបើកធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយទទួលពិនិត្យនិងសិក្សាលើសំណុំឯកសារ ។ នៅក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចផ្តល់អាជ្ញាប័ណ្ណជូនធនាគារពាណិជ្ជថ្មីមួយគឺ ធនាគារ វី អាយ ភី និងធនាគារឯកទេសចំនួន ២ ទៀត ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចប្រែក្លាយទៅជាធនាគារពាណិជ្ជ គឺធនាគារ វិនិយោគរុងរឿង ភីអ៊ិលស៊ី និងម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអ៊ិលស៊ី ដែលបានប្រែខ្លួនពីធនាគារឯកទេសកសិកម្ម ឧស្សាហកម្ម កម្ពុជា ។

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ធនាគារពាណិជ្ជដែលកំពុងធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជាមានចំនួន២០ និងធនាគារឯកទេសមានចំនួន៥ មីក្រូហិរញ្ញវត្ថុមានចំនួន១៧ និងប្រតិបត្តិករឥណទានជនបទចំនួន ២៦ ។

## ៥.៥. ការជម្រះបញ្ជីធនាគារ

នៅក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាជម្រះបញ្ជី និងទូទាត់សងបំណុលអតិថិជនបានគ្រប់ចំនួន ។

## ៥.៦. ការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ

បន្ទាប់ពីច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ចូលជាធរមាន រាជរដ្ឋាភិបាលបានតែងតាំងក្រុមប្រឹក្សាភិបាលរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ដោយមានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ។ បន្ទាប់មក ការប្រជុំលើកទីមួយរបស់ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបានប្រព្រឹត្តិទៅកាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៨ ។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានចេញប្រកាសស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការជាថ្មីកាលពីថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០៨ ។

# ៦. ការផ្គត់ផ្គង់សេវាធនាគារកណ្តាល

## ៦.១. សេវាផ្នែកគណនី

ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងគណនីស្ថាប័នរដ្ឋ អង្គភាពរដ្ឋបាលកណ្តាល គណនីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្ម និងគណនីគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ។ សរុបគណនីទាំងអស់មានចំនួន ១.២៣០គណនី ជារូបិយវត្ថុជាតិ និងប្រាក់ដុល្លារអាមេរិក ។ ប្រតិបត្តិការសរុបក្នុងឆមាសទី១ ឆ្នាំ២០០៨ មានចំនួន ១០៤.៣៤៦ប្រតិបត្តិការ ពោលគឺមានការកើន ១១% ធៀបទៅនឹងឆមាសទី១ ឆ្នាំ២០០៧ ដែលមានចំនួន ៩៤.៨០០ប្រតិបត្តិការ ។

### ៦.១.១. សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ

ធនាគារជាតិនៃកម្ពុជាក៏បានរួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនប្រសិទ្ធភាពកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយទទួលបើកគណនីជូនស្ថាប័នរដ្ឋបាលកណ្តាលគ្រប់គ្រង និងចាត់សម្រួលសាច់ប្រាក់តាមរយៈការបង្វែរប្រាក់រតនាគារជាតិ និងបើកប្រាក់បៀវត្សជូនមន្ទីរ-ក្រសួង និងកងកម្លាំងប្រដាប់អាវុធ ។

ការបង់ពន្ធដារនិងពន្ធគយដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជាពីសំណាក់អ្នកជាប់ពន្ធបានប្រព្រឹត្តទៅដោយរលូនមានបរិមាណ ១.៦៨៩ពាន់លានរៀល (គិតទាំងចំណូលជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក) ។

### ៦.១.២. សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

គណនីដែលធនាគារពាណិជ្ជបានបើកនៅធនាគារជាតិនៃកម្ពុជារួមមាន គណនីចរន្ត គណនីប្រាក់បញ្ញើមានកាលកំណត់ គណនីប្រាក់បញ្ញើធានាលើដើមទុន និងគណនីប្រាក់បម្រុងកាតព្វកិច្ច ។ សមតុល្យប្រាក់បញ្ញើមានកាលកំណត់រយៈពេល ១ខែ ៣ខែ ៦ខែ មានចំនួនសរុប ៣៧៨,១លានដុល្លារអាមេរិក គិតត្រឹមឆមាសទី១ ឆ្នាំ២០០៨ ។

## ៦.២. សេវាផាត់ទាត់

ប្រតិបត្តិការទូទាត់តាមរយៈសភាផាត់ទាត់បានដំណើរការប្រកបដោយប្រសិទ្ធភាព និងមានប្រតិបត្តិការជារៀងរាល់ថ្ងៃធ្វើការទាំងការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀលនិងជាប្រាក់ដុល្លារអាមេរិក ។

ការប្រើប្រាស់មូលប្បទានប័ត្រមាននិន្នាការរីកចម្រើនជាបណ្តើរៗជាពិសេសក្នុងមជ្ឈដ្ឋានធនាគារពាណិជ្ជ និងអង្គភាពរដ្ឋ ។ ការកំណត់ឱ្យប្រើមូលប្បទានប័ត្រដើម្បីបង់ពន្ធគ្រប់ប្រភេទបានធ្វើឱ្យចំនួននៃការប្រើប្រាស់មូលប្បទានប័ត្រមានការកើនឡើង ។

### ៦.២.១. ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល

សភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់រៀលមានសមាជិកចំនួន ២០ ដែលរួមមាន ធនាគារពាណិជ្ជចំនួន ១៧ រតនាគារជាតិ ធនាគារឯកទេស ១ និងធនាគារជាតិនៃកម្ពុជា ។

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀលបានដំណើរការចំនួន ១១៦ថ្ងៃ ។ សកម្មភាពផាត់ទាត់ក្នុងឆមាសនេះមានការកើនឡើងទាំងចំនួនមូលប្បទានប័ត្រ និងចំនួនទឹកប្រាក់ បើធៀបទៅ នឹងការផាត់ទាត់ឆមាសទី២ ឆ្នាំ២០០៧ គឺមូលប្បទានប័ត្រកើនពី ១២.៧៦៧សន្លឹក ទៅ ១៥.១៦៨សន្លឹក (១៩%) និងចំនួនទឹកប្រាក់កើនពី ៤៦៧,៦២ពាន់លានរៀល ទៅ ៦៤២ពាន់លានរៀល (៣៧%) ។

### ៦.២.២. ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារអាមេរិក

សភាផាត់ទាត់មូល្បទានប័ត្រជាប្រាក់ដុល្លារអាមេរិកមានសមាជិកចំនួន ២៣ ដែលជាធនាគារពាណិជ្ជ ១៩ ធនាគារឯកទេស ៣ និងធនាគារជាតិនៃកម្ពុជា ។

សកម្មភាពនៃការផាត់ទាត់ក្នុងឆមាសទី១ ឆ្នាំ២០០៨ បានដំណើរការចំនួន ១១៦ថ្ងៃ ។ សកម្មភាពផាត់ទាត់មានការកើនឡើងទាំងចំនួនមូលប្បទានប័ត្រ និងចំនួនប្រាក់បើធៀបទៅនឹងការផាត់ទាត់ឆមាសទី២ ឆ្នាំ២០០៧ ពោលគឺ ចំនួនមូលប្បទានប័ត្រកើនពី ១៧៩.៤៥៦សន្លឹក ទៅ ១៩៩.០០១សន្លឹក (១១%) និងចំនួនប្រាក់កើនពី ២.៩១៣លានដុល្លារអាមេរិក ទៅ ៣.៧៩៩លានដុល្លារអាមេរិក (៣០%) ។

## ៦.៣. ការខារឥណទាន

ក្នុងឆមាសទី១ ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានផ្តល់ឥណទាន និងប្រមូលបំណុលដូចខាងក្រោម :

- គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ : សមតុល្យដើមគ្រា ៧១.៨០០លានរៀល ឱ្យខ្ចីក្នុងគ្រា ៨៦.២០០លានរៀល ប្រមូលបំណុល ៧១.៨០០លានរៀល សមតុល្យនៅសល់ ៨៦.២០០លានរៀល ។

- ឥណទានចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់សងបំណុល ODA ( Official Development Assistance ) ជប៉ុន បានទូទាត់ចប់សព្វគ្រប់នៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ ។

## ៦.៤. ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរដ្ឋាភិបាល

### ហិរញ្ញប្បទាន និងកម្ចីរបស់រាជរដ្ឋាភិបាលជប៉ុន

### ក. ហិរញ្ញប្បទានឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន

#### ក.១. ហិរញ្ញប្បទានឥតសំណងក្នុងគម្រោង

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ រដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងដល់រាជរដ្ឋាភិបាលកម្ពុជា ចំនួន ២ គម្រោងបន្ថែមទៀត ហើយដើម្បីសម្រួលដល់ការទូទាត់សាច់ប្រាក់ក្នុងការអនុវត្តគម្រោងនេះ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខា Banking Arrangement ជាមួយធនាគារ Bank of Tokyo-Mitsubishi UFJ, Ltd., រួចហើយ ក្នុងនោះមានគម្រោងអភិវឌ្ឍន៍មន្ទីរពេទ្យខេត្តកំពង់ចាម (HOSPITAL 0810) មានទឹកប្រាក់ ១.០៣៩លានយ៉េន និងគម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស (SCHOLARSHIP 0811) មានទឹកប្រាក់ ៣៦៤លានយ៉េន ។ ចំពោះគម្រោងដែលបានទទួលហិរញ្ញប្បទានតាំងពីឆ្នាំមុនៗ ហើយបានអនុវត្តមិនទាន់ចប់នៅឡើយមាន :

១- គម្រោងពង្រីកផ្លូវជាតិលេខ១ មានទឹកប្រាក់ ៤,៧៤៦លានយ៉េន សម្រាប់អនុវត្តរហូតដល់ឆ្នាំ ២០០៩

២- គម្រោងវារីអគ្គិសនីភាវូបនីយកម្មខ្នាតតូចនៅតំបន់ដាច់ស្រយាលខេត្តមណ្ឌលគិរី មានទឹកប្រាក់ចំនួន ១.០៦៦ លានយ៉េន សម្រាប់អនុវត្តរហូតដល់ខែវិច្ឆិកា ឆ្នាំ២០០៨

៣- គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស (SCHOLARSHIP 0710) មានទឹកប្រាក់ ៣៦៤លានយ៉េន សម្រាប់អនុវត្តរហូតដល់ខែវិច្ឆិកា ឆ្នាំ២០១១

៤- គម្រោងការពារទឹកជំនន់ និងកែលំអប្រព័ន្ធប្រឡាយលូក្នុងរាជធានីភ្នំពេញ (FLOOD0709) មានទឹកប្រាក់ ២.៥៩៥លានយ៉េន សម្រាប់អនុវត្តរហូតដល់ឆ្នាំ២០១០

៥- គម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ឧបករណ៍បោសសំអាតមីនតំណាក់កាលទី ២ មានទឹកប្រាក់ ៤៨៤ លានយ៉េន សម្រាប់អនុវត្តរហូតដល់ឆ្នាំ២០០៩

៦- គម្រោងអភិវឌ្ឍន៍មន្ទីរពេទ្យខេត្តកំពង់ចាម (HOSPITAL 2007) មានទឹកប្រាក់ ៦០លានយ៉េន សម្រាប់ អនុវត្តរហូតដល់ខែធ្នូ ឆ្នាំ២០០៨ ។

រីឯគម្រោងដែលបានបញ្ចប់មាន : គម្រោងការពារទឹកជំនន់ និងកែលំអប្រព័ន្ធប្រឡាយលូក្នុងរាជធានីភ្នំពេញ មានទឹកប្រាក់ ៤៩លានយ៉េន ( សម្រាប់ផ្នែកគំនូរនិងប្លង់លំអិត) គម្រោងផ្គត់ផ្គង់ទឹកស្អាតតំបន់ដាច់ស្រយាល

ខេត្តកំពង់ចាមមានទឹកប្រាក់ ៤៣១លានយ៉េន គម្រោងកែលំអបរិក្ខារសន្តិសុខ និងសម្ភារៈសម្រាប់កំពង់ផែអន្តរជាតិសំខាន់ៗ មានទឹកប្រាក់ ៩២៧លានយ៉េន និងគម្រោងស្ដារស្ពានសំខាន់ៗ មានទឹកប្រាក់ចំនួន ៨៤៤លានយ៉េន ។

### គ.២. ហិរញ្ញប្បទានឥតសំណងក្រៅគម្រោង

ក្នុងឆមាសទី១ ឆ្នាំ២០០៨ រដ្ឋាភិបាលជប៉ុនបានផ្ដល់ហិរញ្ញប្បទានឥតសំណងក្រៅគម្រោងដល់រដ្ឋាភិបាលកម្ពុជាចំនួន ២លើក លើកទី១ មានទឹកប្រាក់ ១.៤០០លានយ៉េន សម្រាប់ទ្រទ្រង់ឱនភាពថវិកាជាតិ (Non-Project Type Grant Capital Assistance) និងលើកទី២ មានទឹកប្រាក់ ២៧០លានយ៉េន សម្រាប់ប្រជាកសិករ (Underprivilleged farmers) ។

### គ.៣. កម្ចីសម្បទានពីរាជរដ្ឋាភិបាលជប៉ុន

នៅក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ រដ្ឋាភិបាលជប៉ុនបានផ្ដល់ប្រាក់កម្ចីសម្បទានដល់រាជរដ្ឋាភិបាលកម្ពុជាចំនួន ៣.៦៥១លានយ៉េន បន្ថែមទៀត សម្រាប់គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ។ ប៉ុន្តែគម្រោងនេះ ធនាគារជាតិនៃកម្ពុជាពុំទាន់ចុះហត្ថលេខាលើកិច្ចសម្របសម្រួលធនាគារ (Banking Arrangement) ជាមួយធនាគារ Bank of Tokyo-Mitsubishi UFJ, Ltd., ទេ ។ ចំពោះគម្រោងដែលកំពុងអនុវត្តជាបន្តបន្ទាប់មាន :

- គម្រោងកម្មវិធីកាត់បន្ថយភាពក្រីក្រ និងប្រតិបត្តិការដើម្បីកំណើនសេដ្ឋកិច្ច Poverty Reduction and Growth Operation (L/A No.CP-C1) មានទឹកប្រាក់ចំនួន ១.០០០លានយ៉េន (ចុះហត្ថលេខា ឆ្នាំ២០០៧)
- គម្រោងអភិវឌ្ឍន៍ខ្សែបណ្ដាញថាមពលអគ្គិសនីមហាអនុតំបន់ទន្លេមេគង្គ Greater Mekong Power Network Development (Loan No.CP-P7) មានទឹកប្រាក់ ចំនួន ២.៦៣២លានយ៉េន (គម្រោង នេះចុះហត្ថលេខា ឆ្នាំ២០០៧)
- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ SihanoukVille Port SEZ Deve- lopment Project (Loan No.CP-P6) មានទឹកប្រាក់ចំនួន ៣១៨លានយ៉េន (គម្រោងនេះចុះហត្ថលេខា ឆ្នាំ២០០៦)
- គម្រោងបង្កើតបណ្ដាញទូរគមនាគមន៍មហាអនុតំបន់ទន្លេមេគង្គ Greater Mekong Telecommu- nication Backbone Network Project (Loan No.CP-P5) មានទឹកប្រាក់ចំនួន ៣.០២៩លានយ៉េន (ចុះហត្ថលេខា ឆ្នាំ២០០៥)
- គម្រោងអភិវឌ្ឍន៍កំពង់ផែក្រុងព្រះសីហនុ Sihanoukville Port Urgent Expansion Project (Loan No.CP-P4) ដែលមានទឹកប្រាក់ចំនួន ៤.៣១៣លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៥) ។

## ៧. ការគ្រប់គ្រងចរាចរណ៍ធនបត្រ

បច្ចុប្បន្នចរន្តលំហូរចូល-ចេញនៃសាច់ប្រាក់រៀលតាមរយៈគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឆ្លងកាត់បេឡាប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជាមានការកើនឡើងជាលំដាប់ ។ ជាក់ស្តែងក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ចំណូលសាច់ប្រាក់សរុបមានចំនួន ២.១៧៤,៨៤ពាន់លានរៀល បើធៀបនឹងគ្រាដូចគ្នានៃឆ្នាំ២០០៧ មានការកើនឡើង ៣៦,១៥% ។ ក្នុងនោះ ចំណូលសាច់ប្រាក់បង់ពន្ធគ្រប់ប្រភេទបញ្ចូលក្នុងគណនីប្រាក់បញ្ញើចរន្តរបស់រតនាគារជាតិថយចុះ ៦,៦៣ពាន់លានរៀល (១,២១%) ចំណូលសាច់ប្រាក់ពីប្រាក់បញ្ញើចរន្តនានាកើនឡើង ៤១៦,៧៥ពាន់លានរៀល (៤៩,៣៤%) ចំណូលសាច់ប្រាក់បង់ថ្លៃអគ្គិសនីកម្ពុជាកើនឡើង ៤៦ពាន់លានរៀល (២២,៩២%) ចំណូលសាច់ប្រាក់ពីការលក់ប្រាក់ដុល្លារថយចុះចំនួន ២,៤៥ពាន់លានរៀល (១០០%) ចំណូលសាច់ប្រាក់ពីការប្រមូលបំណុលកើនឡើង ៦,៥០លានរៀល (៦៣,១១%) ចំណូលសាច់ប្រាក់ទទួលបានពីសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងកើនឡើង ១២៤,១៥ពាន់លានរៀល (៦៦%) និងចំណូលសាច់ប្រាក់ផ្សេងៗទៀតថយចុះ ៣៩៨,៣៨លានរៀល (៣៥,៨%) ។

ចំណែកឯសាច់ប្រាក់ចំណាយតាមបេឡាប្រតិបត្តិការសរុបវិញមានចំនួន ២.៦១១,១ពាន់លានរៀល បើធៀបនឹងគ្រាដូចគ្នានៃឆ្នាំ២០០៧ កើនឡើង ៥១,១% ។ ក្នុងនោះ សាច់ប្រាក់បើកឱ្យរតនាគារជាតិថយចុះ ៨៣,៦៣ពាន់លានរៀល (១៣%) ការដកប្រាក់បញ្ញើផ្សេងៗកើនឡើង ១៦១,៨៦ពាន់លានរៀល (៧៣,៥៧%) ការទិញរូបិយប័ណ្ណបរទេសកើនឡើង ៥៣៤ពាន់លានរៀល (១៣៧,៦៧%) បើកសាច់ប្រាក់ឱ្យសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងកើនឡើង ១៧៥,៨៦ពាន់លានរៀល (៦៤,៨៥%) និងសាច់ប្រាក់ចំណាយផ្សេងៗទៀតកើនឡើង ២,៤ពាន់លានរៀល (៣១,៨១%) ។

រីឯសកម្មភាពទទួលប្រាក់ដុល្លារអាមេរិកតាមបេឡាប្រតិបត្តិការវិញមានចំនួន ១.១៣៥,៦លានដុល្លារ បើធៀបនឹងគ្រាដូចគ្នានៃឆ្នាំ២០០៧ កើនឡើង ៧១% ។ ចំណែកឯចំណាយតាមរយៈបេឡាប្រតិបត្តិការវិញមានចំនួន ៧៤៥,២២លានដុល្លារអាមេរិក បើធៀបនឹងគ្រាដូចគ្នានៃឆ្នាំ២០០៧ កើនឡើង ១២០% ។

សកម្មភាពផ្គត់ផ្គង់ក្រដាសប្រាក់ថ្មីសម្រាប់ដូរយកក្រដាសប្រាក់ចាស់ៗខូចគុណភាពពីចរាចរណ៍មកវិញ បានធ្វើឱ្យក្រដាសប្រាក់ក្នុងចរាចរណ៍មានលក្ខណៈថ្មីស្អាតល្អ និងកាន់តែជំរុញឱ្យសាធារណជននិយមប្រើក្រដាសប្រាក់រៀលកាន់តែច្រើនឡើង ។ ក្រដាសប្រាក់ចាស់ៗដែលដូរបាន ធនាគារជាតិនៃកម្ពុជាបានធ្វើការរាប់-ស្រាស់ជ្រើសយ៉ាងហ្មត់ចត់ និងធ្វើការកាត់កម្ទេច និងដុតបំផ្លាញចោលតាមនីតិវិធីត្រឹមត្រូវ ។

ធនាគារជាតិនៃកម្ពុជាសហការជានិច្ចជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ការប្រើប្រាស់ក្រដាសប្រាក់ក្លែងក្លាយក្នុងចរាចរណ៍ ។

## ៨. ការអភិវឌ្ឍប្រព័ន្ធទូទាត់ជាតិ

ដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី នៅចុងឆ្នាំ២០០៧ ផែនទីមគ្គុទ្ទេសក៍ និងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ប្រព័ន្ធទូទាត់ជាតិត្រូវបានកសាងឡើង ដែលមានការគាំទ្រពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមរយៈការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ ។ អនុលោមតាមផែនទីមគ្គុទ្ទេសន៍នេះ ធនាគារជាតិនៃកម្ពុជាបានចងក្រងឯកសារស្តីពីដំណើរការរៀបចំអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ជាតិ (Functional Design Document) ដោយមានរួមបញ្ចូលទាំងដំណើរការអភិវឌ្ឍន៍បណ្តាញប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានុសាស្រ្តសម្រាប់ប្រព័ន្ធទូទាត់ផងដែរ ។

ជំហានដំបូងនៃការអភិវឌ្ឍន៍ប្រព័ន្ធទូទាត់គឺការរៀបចំកែលំអប្រព័ន្ធផាត់ទាត់ ដោយប្រើប្រព័ន្ធបម្លែងទិន្នន័យភាសាសម្ងាត់ (Encrypt) តាមរយៈការកំណត់ឱ្យប្រើមូលប្បទានប័ត្រស្តង់ដារដែលមានលេខកូដជាស្តង់ដារដូចជា លេខរៀងមូលប្បទានប័ត្រ លេខអត្តសញ្ញាណ ធនាគារនិងសាខាធនាគារ លេខគណនី និងចំនួនប្រាក់ជាដើម ដែលនឹងត្រូវអានដោយម៉ាស៊ីនអានលេខកូដ ដើម្បីធានាឱ្យដំណើរការផាត់ទាត់ប្រព្រឹត្តទៅកាន់តែមានប្រសិទ្ធភាព និងធានាបានសុវត្ថិភាពខ្ពស់ ។

ដើម្បីសម្រួលដល់ការអនុវត្ត ធនាគារជាតិនៃកម្ពុជាបានរៀបចំសេចក្តីព្រាងប្រកាសស្តីពីមូលប្បទានប័ត្រស្តង់ដារ ព្រមទាំងសេចក្តីណែនាំស្តីពីលក្ខណៈស្តង់ដារនៃមូលប្បទានប័ត្រដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ និងសេចក្តីព្រាងប្រកាសស្តីពីការកំណត់លេខអត្តសញ្ញាណនៃធនាគារជាតិនៃកម្ពុជានិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ហើយសេចក្តីព្រាងប្រកាសទាំងនេះត្រូវបានដាក់ប្រជុំពិភាក្សាជាមួយធនាគារពាណិជ្ជ និងនាយកដ្ឋានពាក់ព័ន្ធជាបន្តបន្ទាប់ ។

# II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

## ១. សកម្មភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្នមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| - ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ប្រធាន |
| - លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | សមាជិក |
| - ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | តំណាងប្រមុខរាជរដ្ឋាភិបាល | សមាជិក |
| - ឯកឧត្តម អ៊ីវ ថុង | តំណាងមជ្ឈដ្ឋានឧត្តមសិក្សា | សមាជិក |
| - ឯកឧត្តម ជូ គឹមឡេង | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - លោក ឡាយ ម៉េងស៊ុន | តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | សមាជិក |
| - លោកស្រី ម៉ៅ សុន | តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា | សមាជិក ។ |

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ក្រុមប្រឹក្សាភិបាលបានប្រជុំចំនួន ២លើក ដើម្បីពិភាក្សា និងអនុម័តលើការងារមួយចំនួនដូចខាងក្រោម :

- កិច្ចប្រជុំលើកទី ៦៦ នាថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០០៨ ពិនិត្យនិងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ការិយ បរិច្ឆេទ ឆ្នាំ២០០៧

- កិច្ចប្រជុំលើកទី ៦៧ នាថ្ងៃទី ៣ ខែមីនា ឆ្នាំ២០០៨ ពិនិត្យនិងអនុម័តលើសេចក្តីព្រាងរបាយការណ៍ ស្តីពីស្ថានភាពថវិកាឆ្នាំ២០០៧ និងផែនការឆ្នាំ២០០៨ របស់ធនាគារជាតិនៃកម្ពុជា ។

## ២. ការអភិវឌ្ឍធនធានមនុស្ស

### ២.១. ស្ថិតិមន្ត្រីបុគ្គលិក

- ក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជា (ទីស្នាក់ការកណ្តាល) ក្នុងឆមាសទី១ ឆ្នាំ២០០៨នេះ មានចំនួន ៧៧៣ រូប (ប្រុស ៤៤២រូប ស្រី ៣៣១រូប) ដោយឡែកមន្ត្រីបុគ្គលិកក្រៅក្របខ័ណ្ឌមានចំនួន ២០រូប (ប្រុស ១៦រូប ស្រី៤រូប)
- មន្ត្រីរក្សាក្របខ័ណ្ឌមានចំនួន ២រូប (ប្រុស ១រូប ស្រី ១រូប)
- ក្របខ័ណ្ឌសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង មានចំនួន ៣៥៨រូប (ប្រុស២០៥រូប ស្រី ១៥៣រូប) ។

ដូច្នេះសរុបក្របខ័ណ្ឌមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ មានចំនួន ១១៣៣រូប (ប្រុស ៦៤៨រូប ស្រី ៤៨៥រូប) បើប្រៀបធៀបជាមួយក្របខ័ណ្ឌចុងខែធ្នូ ឆ្នាំ២០០៧ ដែលមានចំនួន ១១២៧រូប (ប្រុស ៦៤១រូប ស្រី ៤៨៦រូប) គឺមានការប្រែប្រួលដូចតទៅ:

- ទីស្នាក់ការកណ្តាល កើនចំនួន១០រូប (ចូល២៣រូប ចេញ១៣រូប)
- សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង ថយចំនួន ៤រូប (ចូល ៤រូប ចេញ ៨រូប) ។

### ២.២. ការងារបណ្តុះបណ្តាល

ឈរលើស្មារតីលើកកំពស់ការកសាងសមត្ថភាពធនធានមនុស្ស នៅឆមាសទី១ ឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាបានបើកវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសចំនួន០៥ថ្នាក់ និងភាសាថៃចំនួន ១ថ្នាក់ នៅតាមសាខាធនាគារជាតិនៃកម្ពុជា (មានមន្ត្រីបុគ្គលិកចូលរួមចំនួន ៨១រូប) វគ្គណែនាំប្រតិបត្តិការចំពោះសាខាធនាគារជាតិនៃកម្ពុជាចំនួន ១លើក (មានមន្ត្រីបុគ្គលិកចូលរួមចំនួន ៣៤រូប) និងបានរៀបចំសិក្ខាសាលានិងវគ្គសិក្សាចំនួន ៤ លើក នៅធនាគារជាតិនៃកម្ពុជា (មានមន្ត្រីបុគ្គលិកចូលរួមចំនួន ១២១រូប)គឺ:

- ក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុនៃប្រព័ន្ធអឺរ៉ូ
- កិច្ចប្រជុំគណៈកម្មាធិការបេសកកម្ម
- អាហារូបករណ៍មូលនិធិរូបិយវត្ថុអន្តរជាតិ-ជប៉ុន
- ការស្វែងរកក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ

ធនាគារជាតិនៃកម្ពុជាក៏បានចាត់បញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមសិក្ខាសាលាចំនួន ៥លើក តាមការអញ្ជើញរបស់ក្រសួង-ស្ថាប័ននានា ( មានមន្ត្រីបុគ្គលិកចូលរួមចំនួន ២១រូប)គឺ :

- ការអភិវឌ្ឍជំនាញទីផ្សារមូលប័ត្រ
- ការចូលរួមរបស់គណនេយ្យករជំនាញនៅក្នុងទីផ្សារហ៊ុន (Contribution of Professional Accountants in Stock Market)
- ប្រសិទ្ធភាពនៃការគ្រប់គ្រងគម្រោងសម្រាប់ប្រសិទ្ធភាពការងារនៅគ្រឹះស្ថានសាធារណៈ
- ការរៀបចំសរសេរសំណើសម្រាប់ប្រទេសក្នុងតំបន់អាស៊ាន
- ការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវពីការងារសមាហរណកម្មសេវាកម្មកម្ពុជា
- វគ្គសិក្សាស្តីពីបច្ចេកទេសស៊ើបអង្កេតហិរញ្ញវត្ថុ ។

ម្យ៉ាងវិញទៀត ធនាគារជាតិនៃកម្ពុជាក៏បានចាត់បញ្ជូនមន្ត្រីចំនួន៤រូប ទៅចូលរួមវគ្គសិក្សារយៈពេលវែងដូចជា:

- ថ្នាក់បណ្ឌិតចំនួន ១រូប និងថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ចំនួន ១រូប នៅសាកលវិទ្យាល័យឯកទេសនៃកម្ពុជា
- វគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ចំនួន ១រូប និងមន្ត្រីមធ្យមចំនួន ១រូប នៅសាលាភូមិន្ទរដ្ឋបាល

និងបានចាត់បញ្ជូនមន្ត្រីបុគ្គលិកចំនួន ២៥រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសនៅមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការបណ្តុះបណ្តាល (ACE) ក្នុងនោះមាន:

- កម្មវិធីជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី (AUSAID) ចំនួន ១២រូប
- កម្មវិធីអភិវឌ្ឍអន្តរជាតិ(IDP) ចំនួន ១៣រូប ។

ចំពោះការងារបណ្តុះបណ្តាលនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ និស្សិតជាមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាកំពុងសិក្សាជំនាន់ទី១៦ (ឆ្នាំទី២ ឆមាសទី២) មានចំនួន ៦រូប និងជំនាន់ទី១៧ (ឆ្នាំទី១ ឆមាសទី២) មានចំនួន ១៥រូប ។

ទន្ទឹមនឹងការបណ្តុះបណ្តាលក្នុងប្រទេស ធនាគារជាតិនៃកម្ពុជាក៏បានបន្តបង្កើនសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួននៅក្រៅប្រទេស ដោយបានចាត់បញ្ជូនទៅចូលរួមវគ្គសិក្សា សិក្ខាសាលា ទស្សនកិច្ចសិក្សា កិច្ចប្រជុំ និងកម្មវិធីសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ តាមការអញ្ជើញនិងឧបត្ថម្ភរបស់ប្រទេសនិងស្ថាប័នអន្តរជាតិនានាដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ធនាគារពិភពលោក (World Bank) ធនាគារកណ្តាលអាល្លឺម៉ង់ (Deutsche Bundesbank) ធនាគារកណ្តាលកូរ៉េ (Bank of Korea) ធនាគារកណ្តាលថៃ (Bank of Thailand) មជ្ឈមណ្ឌល Asia-Pacific Finance and Development Center (AFDC) មជ្ឈមណ្ឌល AUSTRAC ក្រសួងហិរញ្ញវត្ថុចិន (MOF China) រដ្ឋាភិបាលចិន (Government of China) ធនាគារស្វីស (Gerzensee Bank) ក្រុមហ៊ុន JOHS RIECKERMANN ក្រុម ហ៊ុន Korea Securities Dealer Association ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកូរ៉េ

（MEF, Korea） ក្រុមហ៊ុន Securency Pty Ltd. អង្គការ United Nations Office on Drugs and Crime （UNODC） ទីភ្នាក់ងារ សហប្រតិបត្តិការអន្តរជាតិស៊ុយអែត（SIDA） ធនាគារ Citigroup អង្គការម្ហូបអាហារនិងកសិកម្ម（FAO） សមាគមអាស៊ាន មជ្ឈមណ្ឌល SEACEN ធនាគារ HSBC មជ្ឈមណ្ឌលពាណិជ្ជកម្មនិងហិរញ្ញវត្ថុអន្តរជាតិ （CICF） វិទ្យាស្ថានសិក្សាអភិវឌ្ឍន៍ （IDS） វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍ថៃ （TDRI） ធនាគារ Dexia Bank រដ្ឋាភិបាលកូរ៉េ（Government of Korea） សមាគមឥណទានជនបទនិងកសិកម្មអាស៊ីប៉ាស៊ីហ្វិក （APRACA） អាជ្ញាធរ រូបិយវត្ថុសិង្ហបុរី（MAS） ធនាគារ Bank International for Settlement（BIS） រដ្ឋាភិបាលឥណ្ឌា ។

ក្រៅពីវគ្គសិក្សារយៈពេលខ្លី ធនាគារជាតិនៃកម្ពុជាក៏បានបញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមវគ្គសិក្សារយៈពេលវែង（ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់） តាមកម្មវិធីអាហារូបករណ៍របស់ Japan-IMF, Australia-IMF, Ausaid និង JICA ។

## ៣. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការងារសវនកម្មផ្ទៃក្នុង និងការងារអធិការកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ដោយបានដាក់ចេញនូវប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារជាតិនៃកម្ពុជា និងប្រកាសស្តីពីក្រមសីលធម៌សម្រាប់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ព្រមទាំងបានរៀបចំប្រកាសចំនួនពីរទៀតរួមមាន ប្រកាសស្តីពីលក្ខន្តិកៈនៃគណកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យរបស់ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងប្រកាសស្តីពីមុខងារ-ភារកិច្ចរបស់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ព្រមទាំងធ្វើការចុះឆ្លក់ត្រួតពិនិត្យការងារនៅតាមសាខាធនាគារជាតិនៃកម្ពុជាជាប្រចាំទៀតផង ។

ទន្ទឹមនឹងនេះ ការងារបណ្តុះបណ្តាលក៏បានធ្វើឡើងដើម្បីបំពាក់បំប៉នសមត្ថភាព តាមរយៈការបណ្តុះបណ្តាលជាទ្រឹស្តី និងហ្វឹកហាត់ធ្វើការងារជាក់ស្តែងដល់ទីកន្លែងពីជំនាញការមូលនិធិរូបិយវត្ថុអន្តរជាតិ និងការបញ្ជូនទៅបណ្តុះបណ្តាលនៅក្រៅប្រទេស ។

ក្រោយពីទទួលបាននូវបទពិសោធន៍ពីការហ្វឹកហាត់ការងារធ្វើសវនកម្មនៅតាមនាយកដ្ឋាន និងសាខាមួយចំនួនរួចមក នៅឆមាសទី១ ឆ្នាំ២០០៨ នេះ មន្ត្រីនាយកដ្ឋានសវនកម្មផ្ទៃក្នុងបានចុះធ្វើសវនកម្មដោយខ្លួនឯងផ្ទាល់នៅនាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានគណនេយ្យ និងនៅតាមសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពតខេត្តកោះកុង និងខេត្តកំពង់ឆ្នាំង ។

បន្ទាប់ពីបានចុះធ្វើសវនកម្មនៅនាយកដ្ឋាន និងសាខាធនាគារជាតិនៃកម្ពុជាខាងលើរួចមក សៀវភៅនីតិវិធីសវនកម្មសម្រាប់នាយកដ្ឋាន និងសាខាធនាគារជាតិនៃកម្ពុជា ត្រូវបានរៀបចំកែសម្រួលជាបន្តបន្ទាប់ ដើម្បីធ្វើឱ្យនីតិវិធីទាំងនេះអាចតម្រូវតាមស្ថានភាពបច្ចុប្បន្ន និងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រតិបត្តិការរបស់នាយកដ្ឋាន និងអង្គភាពទាំងនោះ ដើម្បីឈានទៅដល់ការមានក្រឹត្យក្រមច្បាស់លាស់សម្រាប់ធ្វើសវនកម្ម ។

ចំពោះការងារអធិការកិច្ចវិញ បានចុះឆ្លក់ត្រួតពិនិត្យដោយមិនជូនដំណឹងមុនចំនួន ៤លើក លើសាខាធនាគារជាតិនៃកម្ពុជាចំនួន ១៦ ហើយការត្រួតពិនិត្យបានផ្តោតជាសំខាន់លើការងារធានាសុវត្ថិភាពឃ្លាំង និងការងារគ្រប់គ្រងសាច់ប្រាក់ ។ ឯការងារជំនាញនានាក៏ត្រូវបានត្រួតពិនិត្យ និងកែលំអ ដើម្បីពង្រឹងគុណវឌ្ឍិមន្ត្រីបុគ្គលិកនៅតាមសាខាឱ្យកាន់តែប្រសើរឡើង និងមានតម្លាភាព ។

## ៤. ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ទោះបីការបើកប្រាក់បៀវត្សជូនអង្គភាពសាធារណៈ កងកម្លាំងប្រដាប់អាវុធ និងក្រុមប្រឹក្សាឃុំ/សង្កាត់ នៅគ្រប់ខេត្ត-ក្រុង ក្នុងក្របខ័ណ្ឌនៃការរួមចំណែកអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល បានប្រព្រឹត្តិទៅយ៉ាងរលូនហើយក្តី ក៏ធនាគារជាតិនៃកម្ពុជានៅតែបានលើកកម្ពស់អភិបាលកិច្ចល្អ និងប្រសិទ្ធភាពសេវាក្នុងបណ្តាញសាខា តាមរយៈការចាត់តាំងធ្វើអធិការកិច្ច និងសវនកម្មផ្ទៃក្នុងការបំប៉នសមត្ថភាពជំនាញដល់មន្ត្រីបុគ្គលិក និងការផ្គត់ផ្គង់ធនធានមនុស្សបន្ថែម ដើម្បីត្រៀមលក្ខណៈសហការល្អជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការទទួលប្រាក់ចំណូលសារពើពន្ធនិងពន្ធគយដោយផ្ទាល់ពីអ្នកជាប់ពន្ធ ។

ទន្ទឹមនេះ ក្នុងកិច្ចសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីទទួលប្រាក់បញ្ញើអាណត្តិប្រៃសណីយ៍អន្តរជាតិ ក៏មានការបើកគណនីបម្រើអង្គភាពប្រៃសណីយ៍តាមខេត្ត/ក្រុងចំនួនប្រាំគឺ ខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប ក្រុងព្រះសីហនុ និងស្វាយរៀង ប៉ុន្តែការអនុវត្តជាក់ស្តែងទើបមាននៅសាខាខេត្តសៀមរាបតែប៉ុណ្ណោះ ។ ការយកចិត្តទុកដាក់ថ្មីៗក្នុងបណ្តាញសាខា គឺការបញ្ជាណែនាំឱ្យផ្សព្វផ្សាយអនុក្រឹត្យស្តីពីការចេញផ្សាយក្រដាសប្រាក់ប្រភេទ ២០០០០រៀល គំរូថ្មី ប្រកាសស្តីពីលក្ខណៈសម្គាល់ និងប័ណ្ណប្រកាសនៃក្រដាសប្រាក់នេះឱ្យបានជ្រួតជ្រាបដល់សាធារណជន ។

## ៥. ការងារគណនេយ្យធនាគារជាតិនៃកម្ពុជា

ក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ទ្រព្យសកម្មធនាគារជាតិនៃកម្ពុជាបានកើនឡើងជាង ៧.៤០១ពាន់លានរៀល គឺ ២៥,៧៥% ក្នុងនោះកំណើនដែលគួរឱ្យកត់សម្គាល់គឺ បរិមាណសាច់ប្រាក់ជារៀលនិងជារូបិយប័ណ្ណមានកំណើនសរុប ៤៨១ពាន់លានរៀល (១៦៣,១១%) និងប្រាក់បញ្ញើជារូបិយប័ណ្ណនៅស្ថាប័នហិរញ្ញវត្ថុនិងធនាគារបរទេសមានកំណើន ៤០៩ពាន់លានរៀល (៧,០៧%) ហើយទន្ទឹមនឹងនោះ ការវិនិយោគលើមូលប័ត្រក៏បានកើនឡើងចំនួន ១.២៧៦ពាន់លានរៀលផងដែរ ពោលគឺកើនឡើង ៩៦,៥៨% ។ ចំណែកផ្នែកទ្រព្យអកម្មវិញ រូបិយវត្ថុបានបោះផ្សាយមានកំណើន ៦៥០ពាន់លានរៀល ស្មើនឹង ២៩,៣៩% ហើយប្រាក់បញ្ញើរបស់រដ្ឋាភិបាលមានកំណើន ៨២០ពាន់លានរៀល គឺស្មើនឹង ៤២,៦៥% ។ ចំណែកប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជមានការកើនឡើងចំនួន ៦៧៤ពាន់លានរៀល គឺស្មើនឹង ២១,៥៩% ។

# តារាងតុល្យការធនាគារជាតិនៃកម្ពុជា

ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៨

## ទ្រព្យសកម្ម

(ឯកតាលានរៀល)

| អត្ថាធិប្បាយ | ចំនួនទឹកប្រាក់ ថ្ងៃ ៣១ ខែធ្នូ ឆ្នាំ២០០៧ | ចំនួនទឹកប្រាក់ ថ្ងៃ ៣០ ខែមិថុនា ឆ្នាំ២០០៨ |
|---|---|---|
| សាច់ប្រាក់ជារៀល និងជារូបិយប័ណ្ណ | ២៩៤.៦៦៦ | ៦៤១.៩៣៧ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ នៅធនាគារបរទេស | ៥.៧៩១.២២១ | ៦.៤០៧.២៨៨ |
| ប្រាក់ SDR នៅមូលនិធិរូបិយវត្ថុអន្តរជាតិ | ៨៩៣ | ៣២៧ |
| ប្រាក់រៀលបង់ចូលជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ | ៥៤២.២៦៦ | ៥៦៨.៤៦៦ |
| វិនិយោគលើមូលប័ត្របរទេស | ១.៣២០.៩៩០ | ២.៦៤១.៩២០ |
| លោហធាតុមានតម្លៃ ផ្ញើនៅបរទេស | ១.៣៤៨.៨៨២ | ១.៤១៨.៦៧១ |
| ឱ្យខ្ចី និងបុរេប្រទាន | | |
| - ចំពោះធនាគារពាណិជ្ជ | ៧១.៨០០ | ៨៦.២០០ |
| - ចំពោះរដ្ឋាភិបាល | ២៩៦.៥៨៧ | ២៧០.២៥៣ |
| អចលនទ្រព្យ | ៤៩១.១៣៦ | ៥៣០.៤៣៩ |
| ផ្សេង ៗ | ៣.០៤៩.០៤៧ | ៤.១៧៥.៨២៥ |
| **សរុប** | **១៣.២០៧.៤៨៨** | **១៦.៨៤១.២៩៦** |

## ទ្រព្យអកម្ម

(ឯកតាលានរៀល)

| អត្ថាធិប្បាយ | ចំនួនទឹកប្រាក់ | ចំនួនទឹកប្រាក់ |
|---|---|---|
| រូបិយវត្ថុបោះផ្សាយ | ២.២១១.៨៨៤ | ២.៨៤៩.៣១២ |
| ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ | ៣.១១៨.៩០៨ | ៣.៨៤៦.២៣០ |
| បំណុលចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ | ៦៤៦.៤៨៣ | ៦៧៧.៤៥៤ |
| ប្រាក់បញ្ញើរបស់រដ្ឋាភិបាល | ១.៩២១.៧៨៦ | ២.៦៩៥.១៨៣ |
| ដើមទុន | ១០០.០០០ | ១០០.០០០ |
| ទុនបម្រុង | ១.៧២៣.៩២៦ | ២.០៤៦.៦២០ |
| វិលស់បង្គរទុក | ៩៦.១៨៨ | ១០៦.៧៧៧ |
| សវិធានធន | ២០៩.៦៧៩ | ២៤៣.៤៣០ |
| ផ្សេង ៗ | ៣.១៧៨.៦៣៤ | ៤.២៧៦.១៩០ |
| **សរុប** | **១៣.២០៧.៤៨៨** | **១៦.៨៤១.១៩៦** |

## III. ទំនាក់ទំនងអន្តរជាតិ

### ១. ទំនាក់ទំនងពហុភាគី

#### ១.១. ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ

ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៨ នេះ ក្រុមបេសកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានមកបំពេញទស្សនកិច្ចការងារចំនួនពីរលើកនៅប្រទេសកម្ពុជា ដែលលើកទី១ ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ និងលើកទី២ ពីថ្ងៃទី២៨ ខែឧសភា ដល់ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៨ ។ បេសកកម្មទាំងពីរលើកនេះបានកោតសរសើរចំពោះការប្រព្រឹត្តិទៅនៃសេដ្ឋកិច្ចនៅឆ្នាំ២០០៧ ហើយបានប៉ាន់ស្មានថា កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០០៨ អាចនឹងមានកម្រិតប្រមាណ ៧% ព្រមទាំងបានគូសបញ្ជាក់ថា ការនាំចេញសំលៀកបំពាក់បានចាប់ផ្តើមកើនឡើងក្នុងល្បឿនយឺតជាងមុន ដោយសារតែតម្រូវការសហរដ្ឋអាមេរិកធ្លាក់ចុះ និងដោយសារការប្រកួតប្រជែងយ៉ាងខ្លាំងពីប្រទេសជិតខាងដូចជា ចិន និងវៀតណាម ។ ទន្ទឹមនោះ ក៏មានការចាប់អារម្មណ៍ដែរថា អន្តរការិយកម្មធនាគារបានកើនឡើងយ៉ាងលឿន ខណៈដែលទុនបម្រុងអន្តរជាតិក៏ត្រូវបានបង្កើនគួរឱ្យកត់សម្គាល់ ។ ប៉ុន្តែបញ្ហាសម្ពាធអតិផរណា គឺជាកត្តាប្រឈមចំពោះមុខដែលបង្កឡើងដោយឥទ្ធិពលពីខាងក្រៅ គួបផ្សំនឹងកត្តាខាងក្នុងខ្លះផងដែរ ។ បេសកកម្មស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធទាំងឡាយ ក្នុងការដាក់ចេញនូវវិធានការជាកញ្ចប់ដើម្បីបន្ធូរបន្ថយសម្ពាធអតិផរណា ។

ដោយឡែក នៅចំពោះមុខការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យធនាគារ បេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តល់អនុសាសន៍មួយចំនួនដើម្បីពង្រឹងការត្រួតពិនិត្យធនាគារ ប្រមទាំងការវាយតម្លៃឡើងវិញនូវវត្ថុបញ្ចាំ និងការធ្វើចំណាត់ថ្នាក់ឥណទានរបស់ធនាគារឱ្យបានប្រសើរឡើង សំដៅទប់ស្កាត់ហានិភ័យជាយថាហេតុនៅក្នុងប្រព័ន្ធធនាគារ ។

ដូចបណ្តាឆ្នាំមុនៗដែរ មូលនិធិរូបិយវត្ថុអន្តរជាតិនៅតែបន្តផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជាដើម្បីពង្រឹងសវនកម្មផ្ទៃក្នុង និងការត្រួតពិនិត្យធនាគារពាណិជ្ជដល់ទីកន្លែង ។ លើសពីនោះទៀត ក្នុងអំឡុងបេសកកម្មលើកទី១ តំណាងបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានធ្វើបទបង្ហាញមួយចំនួនដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យធនាគារ និងការអនុវត្តគោលនយោបាយរូបិយវត្ថុនៅក្នុងប្រទេសដែលមានដុល្លារូបនីយកម្មខ្ពស់ ជូនមន្ត្រីធនាគារជាតិនៃកម្ពុជាដើម្បីជាចំណេះដឹងបន្ថែម ។

#### ១.២. ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី

បន្ទាប់ពីបានបញ្ចប់អនុកម្មវិធីទី១ នៃកម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទី២ ដែលជាកម្មវិធីឥណទានរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយធនាគារអភិវឌ្ឍន៍អាស៊ីលើឯកសារ "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" មក ធនាគារជាតិនៃកម្ពុជាដែលជាភ្នាក់ងារប្រតិបត្តិគម្រោង បានបន្តសហការជាមួយបណ្តាក្រសួងពាក់ព័ន្ធ និងធនាគារអភិវឌ្ឍន៍អាស៊ីអនុវត្តអនុកម្មវិធីទី ២ ទៀត ។

កំណែទម្រង់នៅក្នុងអនុកម្មវិធីទី២ មានគោលដៅលើកកម្ពស់ទំនុកចិត្តអន្តរការិយកម្មហិរញ្ញវត្ថុ រក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ ជំរុញអភិបាលកិច្ចល្អ និងលើកកម្ពស់ប្រសិទ្ធភាពការងារ ដែលក្នុងនោះក្រសោបនូវកិច្ចការសំខាន់ៗមួយចំនួនដូចតទៅ :

- អនុវត្តផែនការសកម្មភាពជាគន្លឹះក្នុងដំណាក់កាលទី១ របស់ផែនទីមគ្គុទ្ទេសក៍ស្តីពីប្រព័ន្ធទូទាត់និងផាត់ទាត់
- បោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារពាណិជ្ជដែលបានធ្វើសវនកម្មហើយ និងផ្សព្វផ្សាយប្រកាស បទប្បញ្ញត្តិប្រុងប្រយ័ត្នទាំងឡាយ តាមវេបសាយរបស់ធនាគារជាតិនៃកម្ពុជា
- បង្កើតប្រព័ន្ធកត់ត្រាសម្រាប់ចុះបញ្ជីនូវមូលប័ត្ររដ្ឋដែលត្រូវបានជួញដូរ និងបណ្តុះបណ្តាលបុគ្គលិកសម្រាប់បម្រើការងារនេះ
- ដឹកនាំការចុះអង្កេតលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- សិក្សា និងពិចារណាលើការកែលំអ ឬការធ្វើវិសោធនកម្មច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- រៀបចំអនុម័តអនុក្រឹត្យទាក់ទងនឹងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ជំរុញការអនុវត្តល្អសម្រាប់ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា និងរៀបចំឯកសារដេញថ្លៃសម្រាប់ពង្រឹងប្រព័ន្ធព័ត៌មានវិទ្យា
- បង្កើតឱ្យមានសូហ្វវែរ (software) និងហាតវែរ (hardware) បំពេញមុខងារសម្រាប់ប្រតិបត្តិការសំខាន់ៗរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈដំណើរការដាក់ឱ្យដេញថ្លៃមានលក្ខណៈប្រកួតប្រជែង
- ទ្រទ្រង់មណ្ឌលសិក្សាបច្ចេកទេសធនាគារ សំដៅលើកកម្ពស់ការបណ្តុះបណ្តាលផ្នែកជំនាញមីក្រូហិរញ្ញវត្ថុ ។

លើសពីនេះទៀត ក្រោមគម្រោងអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពីភតិសន្យាហិរញ្ញវត្ថុ ដែលអនុញ្ញាតឱ្យធនាគារពាណិជ្ជ និងធនាគារឯកទេសធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ក្នុងខណៈដែលសេចក្តីព្រាងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុកំពុងរងចាំការអនុម័តពីសភាជាតិ ។ ចំពោះការអភិវឌ្ឍប្រព័ន្ធចែករំលែកព័ត៌មានឥណទានវិញ បន្ទាប់ពីបានដាក់ឱ្យដំណើរការសាកល្បងមួយរយៈកន្លងមកឃើញថា នៅមានបញ្ហាប្រឈមមួយចំនួនទៀតដូចជា កម្រិតគុណភាពនៃរបាយការណ៍ពុំទាន់សុក្រឹត ភាពយឺតយ៉ាវក្នុងការប្រើប្រាស់ប្រព័ន្ធសុវត្ថិភាពទិន្នន័យជាដើម ។ល។ ដើម្បីដោះស្រាយបញ្ហានេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយបច្ចេកទេស រៀបចំកែសម្រួលប្រព័ន្ធឱ្យរលូន និងធ្វើការបណ្តុះបណ្តាលដល់បុគ្គលិកធនាគារជាតិនៃកម្ពុជាផងដែរ ។

## ១.៣. ទំនាក់ទំនងជាមួយអាស៊ាន

ក្នុងសមត្ថកិច្ចជាអាជ្ញាធររូបិយវត្ថុរបស់ប្រទេស ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តការចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន និងអាស៊ាន+៣ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការតំបន់ផ្នែកធនាគារនិងហិរញ្ញវត្ថុ ។ ក្នុងឆមាសទី១ ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានចូលរួមកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៤ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី១២ និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗទៀត ។ សហប្រតិបត្តិការហិរញ្ញវត្ថុក្នុងក្របខ័ណ្ឌអាស៊ានបានដំណើរការយ៉ាងរលូន ក្នុងគោលបំណងសម្រេចឱ្យបាននូវសមាហរណកម្មដ៏ខ្ពស់លើវិស័យធនាគារនិងហិរញ្ញវត្ថុក្នុងតំបន់ និងចូលរួមចំណែកបង្រួមគម្លាតសេដ្ឋកិច្ច និងអភិវឌ្ឍសេដ្ឋកិច្ចតំបន់ប្រកបដោយសមធម៌ ។ ក្នុងឆមាសនេះ សហប្រតិបត្តិការអាស៊ាន ១០ បានផ្តោតការយកចិត្តទុកដាក់លើបញ្ហាគោលនយោបាយសំខាន់ៗដូចជាការអភិវឌ្ឍ :

- ផែនទីមគ្គុទ្ទេសក៏សម្រាប់ធ្វើសមាហរណកម្មវិស័យហិរញ្ញវត្ថុ និងហិរញ្ញវត្ថុក្នុងតំបន់អាស៊ាន ឆ្ពោះទៅរកការអភិវឌ្ឍទីផ្សារទុន សេរីភាវូបនីយកម្មគណនីដើមទុន និងសេរីភាវូបនីយកម្មសេវាកម្មហិរញ្ញវត្ថុនៅក្នុងតំបន់
- ចក្ខុវិស័យសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC Blueprint) ឆ្ពោះទៅប្រែក្លាយតំបន់អាស៊ានដែលមានទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ ដោយការរំពឹងថា នៅឆ្នាំ២០១៥ អាស៊ាននឹងក្លាយទៅជាតំបន់មួយដែលមានចលនាទំនិញ សេវាកម្ម ការវិនិយោគ និងចលនាដើមទុនដោយសេរី
- យន្តការរចនាសម្ព័ន្ធឥណទានអាស៊ានដែលជាគំនិតផ្តួចផ្តើមមួយ ផ្តោតជាសំខាន់ទៅលើតួនាទីធនាគារកណ្តាលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចអាស៊ាន និង
- ការចូលរួមក្នុងដំណើរការតាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិញ្ញវត្ថុក្នុងអាស៊ាន (ASEAN Surveillance Process) ដែលជាយន្តការដ៏សំខាន់មួយសំដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការតាមដានសភាពការណ៍សេដ្ឋកិច្ច ហើយដូចនេះ នឹងបង្កើនលទ្ធភាពរារាំងការកើតមានឡើងនៃវិបត្តិ ។

សហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន+៣ ត្រូវបានចាត់ទុកថាជាយន្តការដ៏ល្អមួយ នៅចំពោះមុខទំនាក់ទំនងនិងការពាក់ព័ន្ធដ៏ច្រើនឡើងៗនៃបណ្តាសេដ្ឋកិច្ចក្នុងតំបន់អាស៊ីអាគ្នេយ៏ ដែលអាចជួយសម្រួលដល់ការពិគ្រោះយោបល់ ព្រមទាំងការពង្រឹងការជួយគ្នាទៅវិញទៅមកនៅពេលជួបប្រទះនឹងបញ្ហា ឬការលំបាកពាក់ព័ន្ធនឹងស្ថិរភាពវិស័យហិរញ្ញវត្ថុក្នុងតំបន់ ហើយដូចនេះ នឹងបង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងស្ថិរភាពវិស័យហិរញ្ញវត្ថុក្នុងតំបន់ ។

ក្នុងឆមាសនេះដែរ ធនាគារជាតិនៃកម្ពុជាបានបន្តចូលរួមជំរុញសកម្មភាពនៃសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន+៣ ដែលបានផ្តោតជាពិសេសលើមុខព្រួញ ដូចខាងក្រោម :

- ការងារក្រោមក្របខ័ណ្ឌ " គំនិតផ្តួចផ្តើមនៅឈៀងម៉ៃ " បានយកចិត្តទុកដាក់រៀបចំបង្កើតនូវយន្តការប្រកបដោយប្រសិទ្ធភាព និងតម្លាភាពមួយសំដៅជួយដោះស្រាយភាពលំបាកនៃកង្វះសាច់ប្រាក់ងាយស្រួលក្នុងតំបន់ ដែលនឹងអាចជួយបំពេញបន្ថែមចំពោះហិរញ្ញប្បទានផ្សេងៗពីសំណាក់គ្រឹះស្ថានហិរញ្ញវត្ថុពហុភាគីអន្តរជាតិនានា

- ការងារក្រោមក្របខ័ណ្ឌ " គំនិតផ្តួចផ្តើមទីផ្សារសញ្ញាប័ណ្ណអាស៊ី " មានគោលបំណងពង្រឹងប្រព័ន្ធហិរញ្ញវត្ថុក្នុងតំបន់ តាមរយៈការអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណអាស៊ីឱ្យកាន់តែមានភាពស៊ីជម្រៅ និងមានលក្ខណៈងាយក្លាយជាសាច់ប្រាក់ងាយស្រួល ហើយឆ្លងតាមនេះនឹងលើកកម្ពស់ការប្រើប្រាស់ប្រាក់សន្សំនៅតំបន់អាស៊ីសម្រាប់ការវិនិយោគនៅអាស៊ីឱ្យកាន់តែប្រសើរឡើង
- ចំពោះការអភិវឌ្ឍធនធានមនុស្ស សហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន+៣ បានយកចិត្តទុកដាក់ដល់ការផ្ទេរចំណេះដឹងនិងបទពិសោធន៍ល្អៗរបស់ប្រទេសក្នុងតំបន់ ពិសេសពីប្រទេស+៣ (ចិន ជប៉ុន កូរ៉េ) ចំពោះប្រទេសដែលមានការអភិវឌ្ឍយឺតជាង ។ ក្នុងបរិបទនេះ លទ្ធផលសំខាន់ចំពោះវិស័យធនាគារ និងហិរញ្ញវត្ថុ នៅកម្ពុជាគឺការបណ្តុះបណ្តាលផ្នែកតាមដាន និងវិភាគសេដ្ឋកិច្ច ការកសាងប្រព័ន្ធក្រើនរំលឹកជាមុនអំពីហានិភ័យជាយថាហេតុ និងបទពិសោធន៍អំពីការរៀបចំទីផ្សារទុន និងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធផ្សេងៗជាដើម ។

### ១.៤. ទំនាក់ទំនងជាមួយ SEACEN

ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានទៅចូលរួមសន្និសីទថ្នាក់ទេសាភិបាលលើកទី៤៣ ស្តីពីការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ស្ថិរភាពរូបិយវត្ថុ និងចីរភាពកំណើនសេដ្ឋកិច្ច និងកិច្ចប្រជុំលើកទី២៧ របស់ក្រុមប្រឹក្សាទេសាភិបាលនៃសមាគម SEACEN ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២០-២៣ ខែមីនា ឆ្នាំ២០០៨ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី ។ នៅក្នុងកិច្ចប្រជុំនេះ គឺបានពិភាក្សានិងសម្រេចលើការងារមួយចំនួនដូចខាងក្រោម :

១- ផ្តល់អាហារូបករណ៍ដល់ប្រទេសជាសមាជិក SEACEN ដែលមាន ផ.ស.ស ក្នុងមនុស្ស ១នាក់ ទាបជាង ១.៥០០ដុល្លារ ចំនួន ៧រូប ដោយផ្តល់ឱ្យក្នុងម្នាក់ៗចំនួន២.០០០ដុល្លារ សម្រាប់ឆ្នាំប្រតិបត្តិការ ២០០៨-២០០៩ ។ ចំពោះធនាគារជាតិនៃកម្ពុជា នាឆ្នាំប្រតិបត្តិការ២០០៨-២០០៩ នឹងទទួលបានអាហារូបករណ៍ចំនួន ៣រូប ។

២- សម្រេចឱ្យ SEACEN centre ចូលជាសមាជិករបស់ Irving Fisher Commitee ស្តីពីប្រព័ន្ធស្ថិតិធនាគារកណ្តាល ។

ទន្ទឹមនឹងនោះដែរ ធនាគារជាតិនៃកម្ពុជាបានទៅចូលរួមកិច្ចប្រជុំលើកទី ៦ របស់គណៈកម្មាធិការប្រតិបត្តិនៃសមាគម SEACEN (the 6th EXCO Meeting) និងសិក្ខាសាលាស្តីពីការកសាងជំនឿទុកចិត្តលើធនាគារកណ្តាលសម្រាប់អនុវត្តគោលនយោបាយរូបិយវត្ថុដែលមានប្រសិទ្ធភាព ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ២៤-២៦ ខែមករា ឆ្នាំ២០០៨ នៅខេត្តភូកេត ប្រទេសថៃ ។ ក្រៅពីនោះ ធនាគារជាតិនៃកម្ពុជាសហការជាមួយមជ្ឈមណ្ឌល SEACEN រៀបចំសិក្ខាសាលាស្តីពីការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង ដែលបានប្រព្រឹត្តិទៅនៅខេត្តសៀមរាប កាលពីថ្ងៃទី២៦-៣០ ខែឧសភា ឆ្នាំ២០០៨ ។

### ១.៥. ទំនាក់ទំនងជាមួយក្រុមអាស៊ីប៉ាស៊ីហ្វិក (APG)

ធនាគារជាតិនៃកម្ពុជាមានតួនាទីយ៉ាងសំខាន់ ក្នុងឋានៈជាអ្នកទំនាក់ទំនងចម្បងរវាង APG ជាមួយក្រសួង និងអង្គភាពពាក់ព័ន្ធនានានៅកម្ពុជា ជាពិសេសក្នុងការទទួលជំនួយបច្ចេកទេសពី APG លើការងារបណ្ដុះបណ្ដាល និង ការត្រៀមខ្លួនសម្រាប់បង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។ ដើម្បីឆ្លើយតបទៅនឹងតួនាទីខាងលើ នៅក្នុងឆមាសទី១ ឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាបានបញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលា ដែលរៀបចំដោយ APG កាលពីថ្ងៃទី១-៤ ខែមេសា ឆ្នាំ២០០៨ លើប្រធានបទស្ដីពីការសាកល្បងលើក្របខ័ណ្ឌការងារនៃការធ្វើផែនការអនុវត្តជាយុទ្ធសាស្ត្រ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ។

### ១.៦. ទំនាក់ទំនងជាមួយសមាគមឥណទានកសិកម្ម និងឥណទានជនបទអាស៊ីប៉ាស៊ីហ្វិក (APRACA)

ក្នុងទិសដៅពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងផ្លាស់ប្ដូរបទពិសោធន៍ បច្ចេកវិទ្យាទៅវិញទៅមក តាមរយៈការបណ្ដុះបណ្ដាលផ្នែកឥណទានកសិកម្មជនបទ និងការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងសកម្មភាពបណ្ដុះបណ្ដាលនានាដែលរៀបចំដោយ APRACA ដើម្បីរួមចំណែកបង្កើនសមត្ថភាពត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ជាក់ស្ដែង កាលពីថ្ងៃទី ២៤-២៩ ខែមីនា ឆ្នាំ ២០០៨ ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាបានចូលរួមមហាសន្និបាតប្រចាំឆ្នាំលើកទី១៦ និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិលើកទី៥៤ នៅប្រទេសវៀតណាម និងបានបញ្ជូនមន្ត្រីធនាគារជាតិនៃកម្ពុជាទៅធ្វើទស្សនកិច្ចសិក្សា ស្ដីពីការគ្រប់គ្រង និងប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ កាលពីថ្ងៃទី១៨-២៣ ខែកុម្ភៈ ឆ្នាំ២០០៨ នៅប្រទេសហ្វីលីពីនទៀតផង ។

## ២. ទំនាក់ទំនងទ្វេភាគី

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងទំនាក់ទំនងទ្វេភាគី ជាមួយបណ្ដាប្រទេសជាមិត្ត ទាំងនៅក្នុងតំបន់អាស៊ី ក៏ដូចជានៅអឺរ៉ុប អូស្ត្រាលី លើគោលការណ៍នៃសហប្រតិបត្តិការជំនាញដូចជា ការផ្លាស់ប្ដូរព័ត៌មាន និងការបណ្ដុះបណ្ដាលជាដើម ។

ប្រតិភូជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជាបន្តជួបប្រជុំជាមួយធនាគារកណ្ដាលថៃ ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការទ្វេភាគី កាលពីថ្ងៃទី២៥-២៧ ខែមេសា ឆ្នាំ២០០៨ នៅទីក្រុងប៉ាតាយ៉ា ប្រទេសថៃ ។ ក្រៅពីកម្មវត្ថុនៃសហប្រតិ-បត្តិការជាទូទៅ ដូចជាការផ្លាស់ប្ដូរព័ត៌មានស្ដីពីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភាគីទាំងពីរបានជំរុញឱ្យមានការសម្របសម្រួលប្រតិបត្តិការទូទាត់ពាណិជ្ជកម្មឆ្លងដែន ដោយប្រើរូបិយវត្ថុជាតិទាំងពីរតាមរយៈការចាត់ឱ្យមានធនាគារពាណិជ្ជចូលរួម ។

ប្រតិភូជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជាបន្តជួបប្រជុំជាមួយធនាគារកណ្ដាលថៃ ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការទ្វេភាគី កាលពីថ្ងៃទី២៥-២៧ ខែមេសា ឆ្នាំ២០០៨ នៅទីក្រុងប៉ាតាយ៉ា ប្រទេសថៃ ។ ក្រៅពីកម្មវត្ថុនៃសហប្រតិ-

បត្តិការជាទូទៅ ដូចជាការផ្លាស់ប្តូរព័ត៌មានស្តីពីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភាគីទាំងពីរបានជំរុញឱ្យមានការសម្រប សម្រួលប្រតិបត្តិការទូទាត់ពាណិជ្ជកម្មឆ្លងដែន ដោយប្រើរូបិយវត្ថុជាតិទាំងពីរតាមរយៈការចាត់ឱ្យមានធនាគារ ពាណិជ្ជចូលរួម ។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយធនាគាររដ្ឋវៀតណាម ប្រតិភូជាន់ខ្ពស់ធនាគារជាតិនៃ កម្ពុជា ដឹកនាំដោយឯកឧត្តមទេសាភិបាល បានអញ្ជើញទៅធ្វើទស្សនកិច្ចនៅសាខាធនាគាររដ្ឋវៀតណាម ខេត្ត ប៊ិញ ធ្វន់ និងខេត្ត តៃ និញ ប្រទេសវៀតណាម កាលពីថ្ងៃទី៤-៦ ខែមេសា ឆ្នាំ២០០៨ ។ ក្នុងដំណើរទស្សនកិច្ចនេះ ឯកឧត្តមទេសាភិបាលធនាគារជាតិនៃកម្ពុជាបានជួបជាមួយឯកឧត្តមទេសាភិបាលធនាគាររដ្ឋវៀតណាម ដើម្បី ពិភាក្សាផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក លើការងារគ្រប់គ្រងសាខា ។

ម្យ៉ាងវិញទៀត កិច្ចសហប្រតិបត្តិការរវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលលុចហ្សំបួរ ត្រូវបាន ពង្រឹងថែមទៀត ដោយធនាគារលុចហ្សំបួរបានទទួលយកមន្ត្រីធនាគារជាតិនៃកម្ពុជាទៅបណ្តុះបណ្តាលអំពីផ្នែក សវនកម្ម និងបានផ្តល់អាហារូបករណ៍ឧត្តមសិក្សាដល់មន្ត្រីធនាគារជាតិនៃកម្ពុជា ។

# សន្និដ្ឋាន

សេដ្ឋកិច្ចប្រទេសកម្ពុជាត្រូវបានរំពឹងថា នឹងបន្តកើនឡើងក្នុងសន្ទុះមួយរឹងមាំទៅឡើយក្នុងឆ្នាំ២០០៨ នេះ ទោះបីជាមានផលប៉ះពាល់មួយចំនួនពីកត្តាក្រៅប្រទេសក្តី ។ ទន្ទឹមនោះ បម្រែបម្រួលនៃបរិដ្ឋានសេដ្ឋកិច្ចពិភពលោក ជាមេរៀនជំរុញឱ្យកម្ពុជាខិតខំថែមទៀតក្នុងការពង្រឹង និងពង្រីកមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួន ។ ក្រៅពីការប្រឹងប្រែង ជាបន្តបន្ទាប់ដើម្បីបង្កើនផលិតភាព និងកម្រិតប្រកួតប្រជែងលើវិស័យកាត់ដេរ ដែលជាកត្តាសំខាន់ដើម្បីជំរុញកំណើន សេដ្ឋកិច្ចថែមទៀតក៏ដោយ ក៏រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់ជាបន្ថែមទៀតទៅលើវិស័យកសិកម្ម ការកសាង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការធ្វើពិពិធកម្មមុខទំនិញនាំចេញ និងការជំរុញផលិតកម្មក្នុងស្រុក សំដៅកាត់បន្ថយកម្រិត ពឹងផ្អែកលើការនាំចូលទំនិញពីក្រៅប្រទេស ដែលបច្ចុប្បន្នជាកត្តាមួយនៃការឡើងថ្លៃទំនិញក្នុងប្រទេសដែរ ។

ការទប់ស្កាត់សម្ពាធអតិផរណាដ៏ខ្ពស់នាពេលថ្មីៗនេះ បានស្តែងឱ្យឃើញនូវភាពចាំបាច់នៃការចូលរួមដ៏សកម្ម រវាងស្ថាប័នពាក់ព័ន្ធទាំងឡាយ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនៃប្រមុខរាជរដ្ឋាភិបាលកម្ពុជា ។ វិធានការ ចំពោះមុខជាកញ្ចប់សម្រាប់តទល់នឹងអតិផរណាត្រូវបានទទួលការស្វាគមន៍ពីសំណាក់មជ្ឈដ្ឋានអន្តរជាតិ ខណៈវិធាន ការរយៈកាលមធ្យមនិងវែង នឹងត្រូវអនុវត្តជាបន្តបន្ទាប់សំដៅបង្កើនការផ្គត់ផ្គង់ទំនិញ ក៏ដូចជាដើម្បីទប់ស្កាត់ កំណើនដ៏លឿននៃតម្រូវការ ។ នៅក្នុងបរិបទនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការរូបិយវត្ថុយ៉ាង ប្រុងប្រយ័ត្ន និងប្រកាន់របបប្តូរប្រាក់សមស្របដែលមានលក្ខណៈទន់ភ្លន់ទៅតាមសភាពការណ៍ទីផ្សារ ហើយខិតខំ រក្សាសង្គតិភាពជាមួយនយោបាយសារពើពន្ធដែលមានទិសដៅទ្រទង់ដល់គោលដៅនយោបាយរូបិយវត្ថុផងដែរ ។

ការអនុវត្តគោលនយោបាយដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ បានបង្ហាញនូវផ្លែផ្កាជាហូរហែរទៅតាមលំដាប់លំដោយនៃសកម្មភាពដែលបានអនុវត្ត។ ទំនុកចិត្តលើប្រព័ន្ធ ធនាគារ ព្រមទាំងប្រសិទ្ធភាពនៃប្រតិបត្តិការធនាគារមានភាពប្រសើរឡើងជាលំដាប់ ។ គ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុដែលមានស្រាប់ ព្រមទាំងគ្រឹះស្ថានដែលទើបបានទទួលអាជ្ញាប័ណ្ណថ្មី កំពុងស្ថិតក្នុងស្ថិរភាពមួយយ៉ាងល្អ និង មានដំណើរការរលូន ។ ទន្ទឹមនោះ ទ្រព្យសកម្មនៃប្រព័ន្ធធនាគារបានកើនឡើងគួរកត់សម្គាល់ ខណៈដែលឥណទាន ចំពោះវិស័យឯកជន និងប្រាក់បញ្ញើរបស់សាធារណជនមានការកើនឡើងថែមមួយកម្រិតទៀតដែរ ។

គណនេយ្យភាព តម្លាភាព ព្រមទាំងភាពរឹងមាំ របស់ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ គឺអាស្រ័យទៅលើការ ទទួលជោគជ័យក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ស្របតាមទិសដៅ ដែលបានកំណត់ ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជានៅតែបន្តការប្រុងប្រយ័ត្នជានិច្ចក្នុងការទទួលខុសត្រូវអនុវត្តគោល នយោបាយរូបិយវត្ថុដ៏សមស្រប រួមទាំងការពង្រឹងតួនាទីរបស់ខ្លួនជាអាជ្ញាធរត្រួតពិនិត្យ និងគ្រប់គ្រងប្រព័ន្ធទូទាត់ ដើម្បីធានាប្រសិទ្ធភាពខ្ពស់ក្នុងវិស័យហិរញ្ញវត្ថុ និងប្រព័ន្ធធនាគារ ។

# ខ. ទិសដៅការងារឆមាសទី២ ឆ្នាំ២០០៨

## ទិសដៅការងារឆមាសទី២ ឆ្នាំ២០០៨

នារយៈពេលថ្មីៗនេះ សមិទ្ធផលដ៏គួរឱ្យចាប់អារម្មណ៍ទាំងឡាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាកំណែទម្រង់រចនាសម្ព័ន្ធ វឌ្ឍនភាពនៃវិស័យធនាគារនិងហិរញ្ញវត្ថុ ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ គឺជាកត្តាដ៏សំខាន់ដើម្បីធានានូវទស្សនវិស័យត្រចះត្រចង់សម្រាប់ប្រទេសកម្ពុជានាអនាគតខាងមុខ ដើម្បីពង្រឹងមូលដ្ឋានគ្រឹះរបស់ប្រទេស សំដៅទប់ទល់នឹងផលប៉ះពាល់អវិជ្ជមាននានាពីក្រៅប្រទេស ។ នៅក្នុងបរិការណ៍នេះ និងស្ថិតក្រោមសម្ពាធនៃបញ្ហាប្រឈមនានាទាំងក្នុងនិងក្រៅប្រទេស នៅឆ្នាំ២០០៨ នេះ សេដ្ឋកិច្ចត្រូវបានគ្រោងថា នឹងមានកំណើនក្នុងកម្រិតប្រមាណ ៧,២% ឯអត្រាអតិផរណាប្រចាំឆ្នាំត្រូវបានរំពឹងថានឹងមានកម្រិតប្រមាណ ២០% ។ ប៉ុន្តែ គួរឱ្យកត់សម្គាល់ដែរថា កំណើនថ្លៃប្រេងនិងម្ហូបអាហារនៅតែជាបញ្ហាប្រឈមចំពោះការព្យាករខាងលើ ។ ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុនិងប្តូរប្រាក់ប្រកបដោយភាពប្រុងប្រយ័ត្ន និងទន់ភ្លន់ទៅតាមការវិវត្តជាក់ស្តែងនៃសេដ្ឋកិច្ច ព្រមទាំងបន្តយកចិត្តទុកដាក់រក្សាការស៊ីចង្វាក់គ្នាជាមួយ នឹងគោលនយោបាយសារពើពន្ធ សំដៅរក្សាចីរភាពនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ ធនាគារជាតិនៃកម្ពុជានឹងបន្តផ្តោតលើកំណែទម្រង់ចាំបាច់ផ្សេងៗជាអាទិភាព ដូចមានចែងក្នុង "ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" ។ ផ្អែកលើយុទ្ធសាស្រ្តរយៈកាលវែងនេះ និងយោងលទ្ធផលដែលសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានពិនិត្យឡើងវិញ និងកែតម្រូវទិសដៅទាំងឡាយ ព្រមទាំងកំណត់ទិសដៅឆមាសទី២ ឆ្នាំ២០០៨ លើផ្អែកសំខាន់ៗដូចខាងក្រោម :

### ១_ ការងាររូបិយវត្ថុ (បម្រែបម្រួលជាភាគរយប្រចាំឆ្នាំ)

| | |
|---|---|
| - រូបិយវត្ថុទូទៅ (M2) | ៣៨,១% |
| - រូបិយវត្ថុក្នុងចរាចរណ៍ | ២០% |
| - ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៤២,៥% |
| - ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា | - ៣៦,២% |
| - ឥណទានសុទ្ធចំពោះរដ្ឋាភិបាលពីវិស័យធនាគារ | - ៣៦,៩% |
| - ទុនបម្រុងផ្លូវការសុទ្ធ | ៣២,១% |

### ២_ ការងារប្តូរប្រាក់

- បន្តពង្រីកការគ្រប់គ្រងទុនបម្រុងអន្តរជាតិស្របតាមសភាពការណ៍ទីផ្សារពិភពលោក
- ពិនិត្យឡើងវិញនូវសេចក្តីព្រាងនៃប្រកាសស្តីអំពីការផ្តល់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតសម្រាប់សេវាប្តូររូបិយប័ណ្ណ

- ពិនិត្យឡើងវិញនូវសេចក្តីព្រាងប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណបញ្ជូនប្រាក់ ។
- តាមដានតម្លៃប្រាក់រៀល ដើម្បីបន្តធ្វើអន្តរាគមទៅលើទីផ្សារ ក្នុងការទិញឬលក់រូបិយប័ណ្ណ ក្នុងគោលបំណងធ្វើឱ្យមានស្ថិរភាពប្រាក់រៀល ។

## ៣. ការងារអភិវឌ្ឍប្រព័ន្ធទូទាត់

- កែលំអឡើងវិញនូវប្រព័ន្ធផាត់ទាត់បច្ចុប្បន្ន តាមរយៈការបង្កើតឱ្យមានលេខកូដស្តង់ដារនៅលើមូលប្បទានប័ត្រ ដើម្បីសម្រួលនិងបង្កើនប្រសិទ្ធភាពការផាត់ទាត់មូលប្បទានប័ត្រ
- ពិនិត្យលើការចេញសេចក្តីព្រាងប្រកាសស្តីពីមូលប្បទានប័ត្រស្តង់ដារ និងសេចក្តីណែនាំស្តីពីលក្ខណៈស្តង់ដារនៃមូលប្បទានប័ត្រ ព្រមទាំងសេចក្តីព្រាងប្រកាសស្តីពីការកំណត់លេខអត្តសញ្ញាណធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ពិនិត្យលទ្ធភាពលើការបង្កើតបណ្តាញផ្តល់ព័ត៌មានទិន្នន័យរវាងទីស្នាក់ការកណ្តាលធនាគារពាណិជ្ជនិងធនាគារជាតិនៃកម្ពុជា
- ត្រៀមរៀបចំសេចក្តីព្រាងប្រកាសដែលពាក់ព័ន្ធនឹងការទូទាត់ តាមរយៈការប្រើប្រាស់ឧបករណ៍ទូទាត់ថ្មីៗ
- បន្តអនុវត្តតាមផែនទីមគ្គុទ្ទេសក៏ (Road map) សម្រាប់ការអភិវឌ្ឍប្រព័ន្ធទូទាត់ជាតិដែលគ្រោងបញ្ចប់នៅឆ្នាំ២០១១ ដើម្បីជួយសម្រួលដល់ការផាត់ទាត់មូលប្បទានប័ត្រ និងឧបករណ៍ទូទាត់ថ្មីៗទៀត ដូចជាបញ្ជាទូទាត់ឥណទានជាដើម ។

## ៤. ការងារត្រួតពិនិត្យ

- ពង្រឹងការអនុវត្តច្បាប់ បទបញ្ជាប្រុងប្រយ័ត្ន
- បន្តអនុវត្តបណ្តាញកុំព្យូទ័រ COBRA ឱ្យបានពេញលេញ
- បន្តការអនុវត្តត្រួតពិនិត្យដល់ទីកន្លែងលើគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ តាមវិសាលភាពពេញលេញ និងតាមមុខសញ្ញា
- បន្តជំរះបញ្ជីធនាគារដែលបានបិទទ្វារ និងខិតខំប្រមែប្រមូលបំណុលដើម្បីទូទាត់សងប្រាក់បញ្ញើអតិថិជន
- រៀបចំបទបញ្ជា ប្រកាសថ្មី ឬធ្វើវិសោធនកម្មលើប្រកាសដែលមានស្រាប់តាមការចាំបាច់
- តាមដានការអនុវត្តការតម្លើងប្រាក់បម្រុងកាតព្វកិច្ចពី ៨% ទៅ ១៦% ។

## ៥. ការងារប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

- រៀបចំផែនការអនុវត្តច្បាប់ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- រៀបចំអនុក្រឹត្យ ប្រកាស និងបទប្បញ្ញត្តិ ដើម្បីអនុវត្តច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- រៀបចំរចនាសម្ព័ន្ធ និងកំណត់មុខងារ-ភារកិច្ចរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ
- រៀបចំនីតិវិធី បែបបទនៃការងារ អនុលោមតាមការកំណត់នៅក្នុងច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បណ្តុះបណ្តាលមន្ត្រីបុគ្គលិកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ អំពីការវិភាគរបាយការណ៍ប្រតិបត្តិការសង្ស័យ ។

## ៦. ការងារគណនេយ្យ

- បន្តអនុវត្តគម្រោងកំណែទម្រង់ការងារគណនេយ្យ និងកែសម្រួលកម្មវិធីគណនេយ្យក្នុងប្រព័ន្ធកុំព្យូទ័រដែលកំពុងប្រើប្រាស់ឱ្យកាន់តែល្អប្រសើរ
- បូកសរុប និងធ្វើការវិភាគរបាយការណ៍គណនេយ្យឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា ។

## ៧. ការងារប្រតិបត្តិការ

- ពង្រឹងនិងត្រួតពិនិត្យការអនុវត្តការងារផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ដើម្បីធានាគុណភាពទូទាត់ក្នុងប្រព័ន្ធធនាគារទាំងមូល
- បង្កើនកិច្ចសហការជាមួយនាយកដ្ឋានពន្ធដារ ទីចាត់ការគយនិងរដ្ឋាករ រតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រតិបត្តិការគ្រប់គ្រងគណនីតាមប្រព័ន្ធកុំព្យូទ័រ
- ពង្រឹងសុវត្ថិភាពការថតចម្លងទិន្នន័យចូល Flash សំរាប់ការងារសភាផាត់ទាត់ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធការពារវីរុសធានាសុវត្ថិភាពក្នុងប្រព័ន្ធ ។

## ៨. ការងារបោះផ្សាយ និងឃ្លាំងបេឡា

- បន្តពង្រឹងការងារបម្រើអតិថិជនក្នុងការបើក-បង់ប្រាក់នៅបញ្ជរបេឡា និងគណនេយ្យជំនួយឱ្យបានលឿន និងកាន់តែប្រសើរឡើង ដោយការពង្រឹងនូវសីលធម៌ និងឥរិយាបទល្អរបស់មន្ត្រីបុគ្គលិកដែលទាក់ទងផ្ទាល់ជាមួយអតិថិជន

- បន្តចុះត្រួតពិនិត្យសាច់ប្រាក់ ណែនាំអំពីការងារគ្រប់គ្រងសាច់ប្រាក់ ការថែរក្សាការពារឃ្លាំងប្រាក់ ព្រមទាំងតាមដានជាប្រចាំនូវសមតុល្យសាច់ប្រាក់ និងតម្រូវការសាច់ប្រាក់ពីសាខាធនាគារជាតិនៃកម្ពុជា
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរាំងខ្ទប់ចរាចរណ៍ប្រាក់ក្លែងក្លាយ ទាំងនៅស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជា
- ពង្រឹងការងាររាប់ស្រាល់ជ្រើស ការងារកាត់កំទេច និងដុតបំផ្លាញចោលក្រដាសប្រាក់ចាស់ ទក់ រហែក ស្របតាមសេចក្តីប្រកាស និងសេចក្តីណែនាំដែលបានកំណត់
- បង្កើនការប្រមូលក្រដាសប្រាក់ចាស់ៗពីចរាចរណ៍ ដោយបញ្ចេញក្រដាសប្រាក់ថ្មីសម្រាប់ដូរតាមប្រភេទ ឱ្យបានសមស្របទៅនឹងចរាចរណ៍លើទីផ្សារ
- ពង្រឹងការងារដឹកជញ្ជូនធនប័ត្រ ។

## ៩_ ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

- ចុះធ្វើសវនកម្មនៅនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់
  និងនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំ តាកែវ ស្វាយរៀង និងកំពង់ចាម
- បន្តចុះឆ្នក់ធ្វើអធិការកិច្ចនៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជាឱ្យបានតាមចំនួនគ្រោងទុក ។

## ១០_ ការបណ្តុះបណ្តាល

- បន្តពង្រឹងគុណភាពមណ្ឌលសិក្សា តាមរយៈការពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិក សាស្ត្រាចារ្យ និងវិន័យដល់និស្សិតជាប្រចាំ
- បន្តរៀបចំស្រាវជ្រាវកម្មវិធីសិក្សា (ធ្វើទំនើបកម្មសៀវភៅតាមមុខវិជ្ជា)
- រៀបចំឱ្យមានបទឧទ្ទេសនាមអំពីប្រធានបទថ្មីៗដែលទាក់ទងនឹងការងារធនាគារ
- រៀបចំការប្រឡងជ្រើសរើសនិស្សិតថ្មី ចូលរៀនជំនាន់ទី១៨ សម្រាប់ឆ្នាំសិក្សា ២០០៨-២០០៩ ។

✧✧✧✧✧✧✧✧

# ឧបសម្ព័ន្ធ

# តារាង៣ : ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ

| រូបិយប័ណ្ណ | ២០០៧ | | | | | | | ២០០៨ | | | | | | បំរែបំរួល% មិថុនា-០៨ /មិថុនា-០៧ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | |
| អេសដេអែរ | ៦.១៨៨ | ៦.២៤៧ | ៦.២៥១ | ៦.៣៤០ | ៦.៣៩៩ | ៦.៣៦៩ | ៦.៣១៩ | ៦.៣៦៧ | ៦.៤០២ | ៦.៥៨២ | ៦.៥២១ | ៦.៥៣៦ | ៦.៦៧៦ | ៧.៨៩% |
| **អាស៊ី** | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ៣.៤៥៩ | ៣.៥០៧ | ៣.៣៣០ | ៣.៥៩០ | ៣.៧៣១ | ៣.៥៤៣ | ៣.៥១៨ | ៣.៥៥៧ | ៣.៧៧៣ | ៣.៦៥៤ | ៣.៧២៦ | ៣.៨៤៤ | ៣.៩៣៨ | ១៣.៨៥% |
| ដុល្លារ-ហុងកុង | ៥២២ | ៥២១ | ៥២៣ | ៥២៥ | ៥២២ | ៥១៤ | ៥១៣ | ៥១២ | ៥១៣ | ៥១៣ | ៥១៣ | ៥១៥ | ៥២៤ | ០.៣៨% |
| យ៉េន-ជប៉ុន | ៣៣.១៤ | ៣៤.២៥ | ៣៥.២២ | ៣៥.២៦ | ៣៥.៣១ | ៣៦.៣៦ | ៣៥.៦៣ | ៣៧.៤៩ | ៣៨.០៥ | ៣៩.៩៤ | ៣៨.៤២ | ៣៨.០៥ | ៣៨.៤៧ | ១៦.០៧% |
| វ៉ុន-កូរ៉េ | ៤.៤០ | ៤.៤៣ | ៤.៣៤ | ៤.៤៤ | ៤.៤៥ | ៤.៣១ | ៤.២៧ | ៤.២៣ | ៤.២៦ | ៤.៣៣ | ៣.៩៨ | ៣.៩២ | ៣.៩២ | -១០.៩១% |
| ដុល្លារ-ញ៉ូស៊ីឡែន | ៣.១៣៨ | ៣.១៤៣ | ២.៨៦១ | ៣.០៧៧ | ៣.១១៩ | ៣.០៨៨ | ៣.១០៣ | ៣.១២៣ | ៣.២៤៧ | ៣.១៦៣ | ៣.០៩២ | ៣.១៣៨ | ៣.១២០ | -០.៥៧% |
| ដុល្លារ-តៃវ៉ាន់ | ១២៤ | ១២៤ | ១២៣ | ១២៤ | ១២៥ | ១២៤ | ១២៣ | ១២៤ | ១២៩ | ១៣១ | ១៣១ | ១៣២ | ១៣៥ | ៨.៨៧% |
| **អាស៊ាន** | | | | | | | | | | | | | | |
| រូពី-ឥណ្ឌូណេស៊ី | ០.៤៤៩ | ០.៤៤៣ | ០.៤៣៣ | ០.៤៤៦ | ០.៤៤៤ | ០.៤២៦ | ០.៤២៥ | ០.៤២៩ | ០.៤៣៩ | ០.៤៣២ | ០.៤៣៣ | ០.៤៣២ | ០.៤៤៤ | -១.១១% |
| រីងហ្គីត-ម៉ាឡេស៊ី | ១.១៨១ | ១.១៨០ | ១.១៦៥ | ១.១៩៣ | ១.២១១ | ១.១៨៩ | ១.២០៧ | ១.២៣៦ | ១.២៥១ | ១.២៥២ | ១.២៦៧ | ១.២៣៨ | ១.២៥៣ | ៦.១០% |
| ប៉េសូ-ហ្វីលីពីន | ៨៨.០៥ | ៨៩.៦០ | ៨៧.០៩ | ៩០.១១ | ៩២.៣៦ | ៩៤.០៥ | ៩៦.៨៣ | ៩៨.០៦ | ៩៨.៧៩ | ៩៥.៤១ | ៩៤.៧២ | ៩១.៦២ | ៩១.៣០ | ៣.៦៩% |
| ដុល្លារ-សាំងហ្គាពួរ | ២.៦៦៣ | ២.៦៩៧ | ២.៦៧៨ | ២.៧៣៥ | ២.៧៨៦ | ២.៧៦៨ | ២.៧៦៨ | ២.៨១៦ | ២.៨៦៦ | ២.៨៩២ | ២.៩៣៦ | ២.៩៤៣ | ៣.០០៨ | ១២.៩៦% |
| បាត-ថៃ | ១២៨ | ១៣៨ | ១២៤ | ១២៨ | ១២៧ | ១៣០ | ១៣១ | ១២៧ | ១៣៥ | ១២៧ | ១២៦ | ១២៤ | ១២២ | -៤.៦៩% |
| ដុង-វៀតណាម | ០.២៥៣ | ០.២៥២ | ០.២៥១ | ០.២៥៣ | ០.២៥២ | ០.២៤៩ | ០.២៤៩ | ០.២៥០ | ០.២៥០ | ០.២៤៨ | ០.២៤៨ | ០.២៤៨ | ០.២៤៣ | -៣.៩៥% |
| **អឺរ៉ុប** | | | | | | | | | | | | | | |
| អឺរ៉ូ | ៥.៤៨៧ | ៥.៥៩២ | ៥.៥៧៥ | ៥.៧៦៧ | ៥.៨៣៣ | ៥.៩១១ | ៥.៨៩៣ | ៥.៩៣៣ | ៦.៦០២ | ៦.២៩៨ | ៦.២២៣ | ៦.២៤១ | ៦.៤៦២ | ១៧.៧៧% |
| **ផ្សេងៗ** | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៨.១៧២ | ៨.២៧៩ | ៨.២១៤ | ៨.២៦២ | ៨.៣៤០ | ៨.២៦៩ | ៧.៩៨៦ | ៧.៩៣៨ | ៧.៩៣៩ | ៧.៩៦៧ | ៧.៨៦៣ | ៧.៩៣៩ | ៨.១៦០ | -០.១៥% |

# តារាង ៤ : ស្ថានភាពរូបិយវត្ថុ

(គិតជាលានរៀល)

| | ធ្នូ_២០០៧ | មករា_០៨ | កុម្ភៈ_០៨ | មិនា_០៨ | មេសា_០៨ | ឧសភា_០៨ | មិថុនា_០៨ |
|---|---|---|---|---|---|---|---|
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១០.៧៣៤.៧០៣** | **១១.០៧០.៨១៥** | **១១.១៧៦.១៣៣** | **១០.៩៥០.៨៦៩** | **១១.២៧៤.១៨៤** | **១១.៤៩២.៩៩៤** | **១១.៣៩២.៦០០** |
| ទ្រព្យសកម្មបរទេស | ១១.៨៩០.៣០៣ | ១២.៣៧៥.៦១៦ | ១២.៥១០.៣៦៦ | ១២.៣០២.១៧២ | ១៣.១៩៤.០៤០ | ១៣.១៦៩.៧៩៧ | ១៣.០៥៦.៧៧៣ |
| ទ្រព្យអកម្មបរទេស | -១.១៥៥.៦០០ | -១.៣០៤.៨០១ | -១.៣៣៤.២៣៣ | -១.៣៥១.៣០៣ | -១.៩១៩.៨៥៥ | -១.៦៧៦.៨០៤ | -១.៧៤៤.១៧៣ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៥៧៥.៩៧៧** | **៧០៨.៨៦៤** | **៩៦៥.០៣៧** | **១.០៣៦.៣៧២** | **១.២៤៨.០៦៨** | **១.៣៣៩.៧៩៧** | **១.៣៤៥.២៥៦** |
| **ឥណទានក្នុងស្រុក** | **៤.៥៧០.០៥៣** | **៥.០៦៦.៧៩៣** | **៥.៤៣៧.៣៩០** | **៥.៦៤៩.៩៣៦** | **៥.៨៦១.៨៨៩** | **៦.០៥០.៩៦៨** | **៦.៥២៧.៣៣៣** |
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | **-១.៨១៥.៨៩៧** | **-១.៩៩៣.៧៣៦** | **-២.០៨៣.៧៣៧** | **-២.៤០០.៤២០** | **-២.៥៧៧.១៤៩** | **-២.៧០៤.៣៨៧** | **-២.៦៧៨.៤១៨** |
| ឥណទេយ្យរាជរដ្ឋាភិបាល | ២៩៦.៩៦០ | ២៩៧.៧១៨ | ២៩៥.៩១៣ | ២៩៦.៥៨២ | ២៨៣.៣០៩ | ២៨៣.២២៣ | ២៧០.៤៥៣ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | -២.១១២.៨៥៧ | -២.២៩១.៤៥៣ | -២.៣៧៩.៦៥១ | -២.៦៩៧.០០២ | -២.៨៦០.៤៥៨ | -២.៩៨៧.៦១០ | -២.៩៤៨.៨៧០ |
| **ឥណទានផ្នែកមិនមែនរាជរដ្ឋាភិបាល** | **៦.៣៨៥.៩៥០** | **៧.០១៥.៥២៨** | **៧.៥២១.១២៨** | **៨.០៥០.៣៥៦** | **៨.៤៣៩.០៣៨** | **៨.៧៥៥.៣៥៥** | **៩.២០៥.៧៥៦** |
| សហគ្រាសរដ្ឋ | ១.១៧៧ | ១.០៩៨ | ១.០១៧ | ៩៣៩ | ៨៥៨ | ៧៨១ | ៧០៩ |
| ផ្នែកឯកជន | ៦.៣៨៤.៧៧៣ | ៧.០១៤.៤៣០ | ៧.៥២០.១១១ | ៨.០៤៩.៤១២ | ៨.៤៣៨.១៨០ | ៨.៧៥៤.៥៧៣ | ៩.២០៥.០៤៧ |
| ក្នុងនោះ : រូបិយប័ណ្ណបរទេស | ៦.១៦១.២៩៦ | ៦.៧៧៦.០៣០ | ៧.២៦៨.១៤៧ | ៧.៨១៩.៩២៥ | ៨.២០៧.៧៣៤ | ៨.៥២៣.៤៧៤ | ៨.៩៤៥.៣៤៦ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-៣.៩៩៤.០៧៦** | **-៤.៣៤២.៩២៩** | **-៤.៤៧២.៣៥៣** | **-៤.៥១៣.៥៥៩** | **-៤.៦១៣.៨២១** | **-៤.៧១១.១៧១** | **-៥.១៨២.០៧៧** |
| ប្រាក់បញ្ញើហាមឃាត់ | -២៥៤.៩៩៦ | -២៤៧.៦៩០ | -២១៧.៣៨៦ | -២៩៨.០៨៣ | -២៣៨.៤០៦ | -២៤៦.២១៥ | -២៨៣.០៥៩ |
| មូលធននិងធនបម្រុង | -៤.៣១១.៨៣៥ | -៤.៦៦១.៦១៩ | -៤.៨០២.៤០៨ | -៤.៨០៥.៩៧៥ | -៥.០០៤.២៤៤ | -៥.២០៧.៩៩៥ | -៥.៤៥៨.២៤៧ |
| ផ្សេងៗ | ៥៧២.៣៥៥ | ៥៦៦.៣៨០ | ៥៤៧.៤៤១ | ៥៩០.៤៩៨ | ៦២៨.៨២៩ | ៧៤៣.០៤០ | ៥៥៩.២២៨ |
| **រូបិយវត្ថុធូរទៅ (M2)** | **១១.៣១០.៦៨១** | **១១.៧៨៩.៦៧៩** | **១២.១៤១.១៧០** | **១២.០៤៧.២៤១** | **១២.៥២២.២៥៣** | **១២.៨៣២.៧៩១** | **១២.៦៩៧.៨៥៦** |
| **រូបិយវត្ថុ (M1)** | ២.០៥២.០០៨ | ២.១៤៣.៤០៨ | ២.២១២.៩២៨ | ២.៣៨៩.១១៧ | ២.៥២៤.៦៨៣ | ២.៤៤០.៩២២ | ២.៤៦៦.៨៨៣ |
| រូបិយវត្ថុក្រៅធនាគារ | ១.៩៨៩.៧៣៧ | ២.០៨១.៩៨៨ | ២.១៥៨.១៣០ | ២.៣២៣.៩៧៩ | ២.៤៤៧.៧១៦ | ២.៣៦២.០៥៤ | ២.៣៤៨.៧៣៩ |
| ប្រាក់បញ្ញើចរន្ត | ៦២.២៧១ | ៦១.៤២០ | ៥៤.៧៩៨ | ៦៥.១៣៨ | ៧៦.៩៦៧ | ៧៨.៨៦៨ | ១១៨.១៤៤ |
| **រូបិយវត្ថុផ្សេងៗ** | **៩.២៥៨.៦៧៣** | **៩.៦៤៦.២៧១** | **៩.៩២៨.២៤២** | **៩.៦៥៨.១២៤** | **៩.៩៩៧.៥៦៩** | **១០.៣៩១.៨៦៩** | **១០.២៣០.៩៧៣** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ១២១.០២៣ | ១១៥.៤៥៣ | ១១៨.៧០២ | ១២៥.៨៦៦ | ១៤១.១៩៨ | ១៤៥.៦៣១ | ១៤៩.៦៦៧ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៩.១៣៧.៦៥០ | ៩.៥៣០.៨១៨ | ៩.៨០៩.៥៤១ | ៩.៥៣២.២៥៨ | ៩.៨៥៦.៣៧១ | ១០.២៤៦.២៣៨ | ១០.០៨១.៣០៧ |

# តារាង ៥ : ស្ថានភាពរូបិយវត្ថុ

(បម្រែបម្រួលប្រចាំខែជាភាគរយ)

| | ធ្នូ.២០០៧ | មករា.០៨ | កុម្ភៈ.០៨ | មិនា.០៨ | មេសា.០៨ | ឧសភា.០៨ | មិថុនា.០៨ |
|---|---|---|---|---|---|---|---|
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១.៨០** | **៣.១៣** | **០.៩៥** | **-២.៣៨** | **៣.៣៣** | **១.៩៤** | **-១.២២** |
| ទ្រព្យសកម្មបរទេស | ៣.១៨ | ៤.០៨ | ១.០៩ | -១.៦៦ | ៧.២៥ | -០.១៨ | -០.៥៥ |
| ទ្រព្យអកម្មបរទេស | ១៨.០៧ | ១២.៩១ | ២.២៥ | ៤.២៨ | ៣៧.៩៩ | -១២.៦៣ | ៤.០២ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **២២៣.០១** | **២៤.៨៣** | **៣៤.២៤** | **១៧.៧៥** | **៩.៨២** | **៧.៣៤** | **០.៤១** |
| **ឥណទានក្នុងស្រុក** | **១១.៧០** | **១០.៧៦** | **៧.៤២** | **៣.៩១** | **៣.៧៥** | **៣.២២** | **៧.៨៧** |
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | **០.៤០** | **៧.៥៩** | **៦.៦៥** | **១៥.២០** | **៧.៣៦** | **៤.៩៤** | **-០.៩៦** |
| ឥណទេយ្យរាជរដ្ឋាភិបាល | -០.១០ | ០.២៦ | -០.៦០ | ០.២៣ | -៤.៤៨ | -០.០៣ | -៤.៥១ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | ០.៣៣ | ៦.៥៦ | -០.៦០ | ១៣.៣៤ | ៦.០៦ | ៤.៤៤ | -១.៣០ |
| **ឥណទានផ្នែកមិនមែនរាជរដ្ឋាភិបាល** | **៨.២៤** | **៩.៨៦** | **៥.៦៩** | **៧.០៤** | **៤.៨៣** | **៣.៧៤** | **៥.១៤** |
| សហគ្រាសរដ្ឋ | -៦.៣៦ | -៦.៧១ | ៧.២១ | -៧.៦៧ | -៨.៦៣ | -៨.៩៧ | -៩.២២ |
| ផ្នែកឯកជន | ៨.២៤ | ៩.៨៦ | -៦.៩០ | ៧.០៤ | ៤.៨៣ | ៣.៧៥ | ៥.១៥ |
| ក្នុងនោះ : រូបិយប័ណ្ណបរទេស | ៨.៥៥ | ៩.៩៨ | ២.៩៨ | ៧.៥៩ | ៤.៩៦ | ៣.៨៥ | ៤.៩៥ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **២.០៧** | **៨.៧៣** | **-១២.២៣** | **-២០០.៩២** | **២.២២** | **២.១១** | **៩.៩៩** |
| ប្រាក់បញ្ញើហាមឃាត់ | ៣២.៨២ | -២.៧១ | -២០៣.០២ | ៣៧.១២ | -២០.០២ | ៣.២៧ | ១៤.៩៦ |
| មូលធននិងធនបម្រុង | ២.៥៤ | ៨.១១ | -៣.៣៤ | ០.០៧ | ៤.១៣ | ៤.០៧ | ៤.៨០ |
| ផ្សេងៗ | ១៨.៣៤ | -១.០៤ | ២.៩៨ | ៧.៨៧ | ៦.៤៩ | ១៨.១៦ | -២៤.៧៤ |
| **រូបិយវត្ថុទូទៅ (M2)** | **៥.៤៧** | **៤.២៣** | **-១២.២៣** | **-០.៧៧** | **២៤.៥៩** | **២.៤៨** | **-១.០៥** |
| **រូបិយវត្ថុ (M1)** | ៨.៣៣ | ៤.៤៥ | ៣.២៤ | ៧.៩៦ | ៥.៦៧ | -៣.៣២ | ១.០៦ |
| រូបិយវត្ថុក្រៅធនាគារ | ៨.១៦ | ៤.៦៤ | ៣.៦៦ | ៧.៦៨ | ៥.៣២ | -៣.៥០ | -០.៥៦ |
| ប្រាក់បញ្ញើចរន្ត | ១៤.១០ | -១.៣៧ | -១០.៨០ | ១៨.៨៧ | ១៨.១៦ | ២.៤៧ | ៤៩.៨០ |
| **រូបិយវត្ថុផ្សេងៗ** | **៤.៨៦** | **៤.១៩** | **២.៩២** | **-២.៧២** | **៣.៥១** | **៣.៩៤** | **-១.៥៥** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ១០.៩៥ | -៤.៦០ | ២.៨១ | ៦.០៤ | ១២.១៨ | ៣.១៤ | ២.៧៧ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៤.៧៨ | ៤.៣០ | ២.៩២ | -២.៨៣ | ៣.៤០ | ៣.៩៥ | -១.៦១ |

# តារាង ៦ : តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា

| | ធ្នូ-២០០៧ | មករា-០៨ | កុម្ភៈ-០៨ | មិនា-០៨ | មេសា-០៨ | ឧសភា-០៨ | មិថុនា-០៨ |
|---|---|---|---|---|---|---|---|
| | (គិតជាលានរៀល ) | | | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | ៨.៥៧៩.១១៩ | ៩.៦៧៧.៣៩៦ | ៩.៧១៧.៣០៧ | ៩.៧០៥.៦៦៧ | ១០.១៧៥.៩៣៦ | ១០.៥៤៣.១១១ | ១០.៧៨២.៥១០ |
| ទ្រព្យសកម្មបរទេស | ៨.៥៧៩.១២០ | ៩.៦៧៧.៣៩៧ | ៩.៧១៧.៣០៧ | ៩.៧០៥.៦៦៧ | ១០.១៧៥.៩៣៦ | ១០.៥៤៣.១១១ | ១០.៧៨២.៥១០ |
| ទ្រព្យអកម្មបរទេស | ០ | ០ | ០ | ០ | ០ | ០ | ០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | -៣.៥៦០.៩២៩ | -៣.៨៤២.០៥៩ | -៤.០១៥.០៥៣ | -៤.៣០៩.០៧៥ | -៤.៣៣៥.៥៩៩ | -៤.៥១៥.៣៧០ | -៤.៧០៦.៥៣៨ |
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | -១.៦៣១.៩៩៧ | -១.៧៧០.៩៧៩ | -១.៦៧៦.៧៣៥ | -២.១៨៧.២៨១ | -២.៣៥៧.០០៤ | -២.៤៦៥.១៣៨ | -២.៤៣៤.៥៨៧ |
| ឥណទេយ្យរាជរដ្ឋាភិបាល | ២៥៦.៧៦០ | ២៥៧.៥១៨ | ២៥៥.៧១៣ | ២៥៦.៣៨២ | ២៨៣.១០៥ | ២៨៣.០២៣ | ២៧០.២៥៣ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | ១.៨២៨.៧៥៦ | ២.០៦៨.៤៥៧ | ១.៩៣២.៤៤៨ | ២.៤៤៣.៦៦៣ | ២.៦៣០.១១៣ | ២.៧៤៨.១៦១ | ២.៧០៤.៨៤០ |
| **ឥណទានទំពោះធនាគារពាណិជ្ជ** | -១៥១.៤៥៦ | -១៤០.១០៨ | -១០៨.៦៣២ | -១៨៣.៣៨៦ | -១៣៥.៧៤៨ | -១៤០.២៧៨ | -១៧១.៧៦៨ |
| **ឥណទានទំពោះផ្នែកឯកជន** | ២.០៤៥ | ២.០៤១ | ២.០៣០ | ២.០២៩ | ១.៩៥៥ | ១.៩៥៩ | ១.៩៦៦ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | -១.៧៧៩.៤៨៦ | -១.៩៣៣.០១៤ | -២.០៣១.៧១៦ | -១.៩៤០.៤៣៧ | -១.៨៥៤.៨០៥ | -១.៩១១.៩១៣ | -២.១០២.១៥០ |
| **រូបិយវត្ថុបម្រុង** (Reserve Money) | ៥.០១៨.១៩០ | ៥.៨៣៥.៣៣៧ | ៥.៧០២.២៥៤ | ៥.៣៩៦.៤៩២ | ៥.៨៤០.៣៣៧ | ៦.០២៧.៧៤១ | ៦.០៧៥.៩៧១ |
| រូបិយវត្ថុក្រៅធនាគារ | ១.៩៨៥.៧៣៧ | ២.០៨១.៩៨៨ | ២.១៥៨.១៣០ | ២.៣២៣.៩៧៩ | ២.៤៤៧.៧១៦ | ២.៣៦២.០៥៤ | ២.៣៤៨.៧៣៩ |
| បេឡាធនាគារពាណិជ្ជ | ៤៧.១៧៩ | ៣៨.៨៤៤ | ៥១.៤២៤ | ៤៥.១៤០ | ៥២.៣៧១ | ៦២.៥៣០ | ៦៧.៣៧០ |
| **ប្រាក់បញ្ញើធនាគារ** | ២.៩៦៨.៤៦៦ | ៣.៦៩៧.៨៦៩ | ៣.៤៨២.២៤៥ | ៣.០០៦.៨៩២ | ៣.៣២៥.៤២៤ | ៣.៩៨៨.៩៣៤ | ៣.៦២៩.១៦២ |
| ប្រាក់បម្រុងកាតព្វកិច្ច | ៧៧៧.៦៦០ | ៧៨៦.០៣១ | ៨៤៣.៧៨៨ | ៨៥៨.៥០៧ | ៨៧៥.១៩៣ | ៩៧៨.០៥៨ | ១.១០៨.៥៨៩ |
| ប្រាក់បញ្ញើផ្សេងៗ | ២.១៩០.៨០៦ | ២.៩០១.៨៣៨ | ២.៦៣៨.៤៥៧ | ២.១៤៧.៩៨៤ | ២.៤៥០.៣៣១ | ២.៦១០.៨៣៦ | ២.៥២០.៥៧២ |
| **ផ្សេងៗ** | ១២.៨០៨ | ១៦.៦៣៦ | ១០.៤៥៤ | ២០.៥៨១ | ១៤.៧២៦ | ១៤.៦២៣ | ៣០.៧០០ |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | ៥.៧៨ | ១២.៨០ | ០.៤១ | -០.២០ | ៤.៨៥ | ៣.៦១ | ២.២៧ |
| ទ្រព្យសកម្មបរទេស | ៥.៧៨ | ១២.៨០ | ០.៤១ | -០.២០ | ៤.៨៥ | ៣.៦១ | ២.២៧ |
| ទ្រព្យអកម្មបរទេស | ០ | ០ | ០ | ០ | ០ | ០ | ០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | ៤.៣០ | ៧.៨៩ | ៤.៥០ | ៧.៣២ | ០.៦២ | ៤.១៥ | ៤.២៣ |
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | ១.៤៩ | ៨.៥២ | ៥.៩៧ | ១៦.៥៥ | ៧.៣០ | ៥.០៣ | -១.២៤ |
| ឥណទេយ្យរាជរដ្ឋាភិបាល | -០.០៨ | ០.២៦ | -០.៦០ | ០.២៣ | -៤.៤៧ | -០.០៣ | -៤.៥១ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | ១.២៤ | ៧.២៥ | ៥.០៣ | ១៤.៣២ | ៥.៨៩ | ៤.៤៩ | -១.៥៧ |
| **ឥណទានទំពោះធនាគារពាណិជ្ជ** | ៦១.១៧ | -៧.៥១ | -២២.៤៧ | ៦៨.៨១ | -២៥.៩៨ | ៣.៣៤ | ២២.៤៥ |
| **ឥណទានទំពោះផ្នែកឯកជន** | -០.១៥ | -០.២០ | -០.៥៤ | -០.០៥ | -៤.១៩ | ០ | ០.៣៦ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | ៣.៨២ | ៨.៦៣ | ៥.១១ | -៤.៤៩ | -៤.៤១ | ៣.០៨ | ៩.៥៥ |
| **រូបិយវត្ថុបម្រុង** (Reserve Money) | ៦.៨៥ | ១៦.២៨ | -២.២៨ | -៥.៣៦ | ៨.២២ | ៣.២១ | ០.៨០ |
| រូបិយវត្ថុក្រៅធនាគារ | ៨.១៦ | ៤.៦៤ | ៣.៦៦ | ៧.៦៨ | ៥.៣២ | -៣.៥០ | -០.៥៦ |
| បេឡាធនាគារពាណិជ្ជ | ១៥.៤១ | -១៧.៦៧ | ៣២.៣៩ | -១២.២១ | ១៦.០២ | ១៩.៤០ | ៧.៧៤ |
| **ប្រាក់បញ្ញើធនាគារ** | ៥.៧៨ | ២៤.៥៧ | -៥.៨៣ | -១៣.៦៥ | ១០.៦០ | ៧.៥៦ | ១.១៣ |
| ប្រាក់បម្រុងកាតព្វកិច្ច | ៨.៣៤ | ២.៣៦ | ៦.០០ | ១.៧៩ | ១.៨០ | ១១.៧៦ | ១៣.៣៤ |
| ប្រាក់បញ្ញើផ្សេងៗ | ៤.៨៧ | ៣២.៤៥ | -៩.០៨ | -១៨.៥៨ | ១៤.០៨ | ៦.៥៣ | -៣.៤៤ |
| **ផ្សេងៗ** | ៣៤.៣០ | ២៩.៨៩ | -៣៧.១៦ | ៩៦.៨៧ | -២៨.៤៩ | -០.៧០ | ១០៩.៥៤ |

# តារាង ៧ : តារាងគណនីវិភាគធនាគារពាណិជ្ជ

| | ធ្នូ-២០០៧ | មករា-០៨ | កុម្ភៈ-០៨ | មិនា-០៨ | មេសា-០៨ | ឧសភា-០៨ | មិថុនា-០៨ |
|---|---|---|---|---|---|---|---|
| | (គិតជាលានរៀល ) | | | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **២.១៥៥.៥៨៤** | **១.៣៩៣.៤២០** | **១.៤៥៨.៨២៦** | **១.២០៥.២០៣** | **១.០៩៨.២៤៨** | **៩៤៩.៨៨៣** | **៥៧០.០៩០** |
| ទ្រព្យសកម្មបរទេស | ៣.៣១១.១៨៤ | ២.៦៩៨.២២០ | ២.៧៩៣.០៥៩ | ២.៥៥៦.៥០៥ | ៣.០១៨.១០៤ | ២.៦២៦.៦៨៦ | ២.៣១៤.២៦៣ |
| ទ្រព្យអកម្មបរទេស | -១.១៥៥.៦០០ | -១.៣០៤.៨០១ | -១.៣៣៤.២៣៣ | -១.៣៥១.៣០២ | -១.៩១៩.៨៥៦ | -១.៦៧៦.៨០៤ | -១.៧៤៤.១៧៣ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៤.០២០.២៧៨** | **៤.៤៨៤.២០៥** | **៤.៨៩២.៤២៥** | **៥.៣២៦.៥១៥** | **៥.៤៨០.៨២៦** | **៥.៦៦៤.៦៨០** | **៦.០៣០.៦៣១** |
| **ឥណទានក្នុងស្រុកសុទ្ធ** | **៦.១៦០.០០៤** | **៦.៧៨៦.៥១៧** | **៧.២៦៣.៨៩៦** | **៧.៧៩០.៩៤៦** | **៨.១៥៨.៧០៧** | **៨.៤៦៦.១៤៦** | **៨.៩១១.៧៣៩** |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | -១៨៣.៩០០ | -១៨២.៧៥៧ | -២០៧.០០២ | -២១៣.១៣៩ | -២៣០.១៤៤ | -២៣៩.២៤៩ | -២៤៣.៨៣១ |
| ឥណទានចំពោះសហគ្រាសរដ្ឋ | ១.១៧៧ | ១.០៥៨ | ១.០១៧ | ៩៣៩ | ៨៥៨ | ៧៨១ | ៧០៩ |
| ឥណទានចំពោះផ្នែកឯកជន | ៦.៣៨២.៧២៨ | ៧.០១២.៣៨៩ | ៧.៥១៨.០៨១ | ៨.០៤៧.៣៨៤ | ៨.៤៣៦.២២១ | ៨.៧៥២.៦១៤ | ៩.២០៣.០៧៥ |
| ឥណទានសុទ្ធចំពោះធនាគារជាតិនៃកម្ពុជា | -៤០.០០០ | -៤៤.២១៣ | -៤៨.២០០ | -៤៤.២៣៨ | -៤៨.២២៨ | -៤៨.០០០ | -៤៨.២១៥ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-២.១៣៩.៧២៦** | **-២.៣០២.៣១២** | **-២.៣៧១.៤៧០** | **-២.៤៦៤.៤៣១** | **-២.៦៧៧.៨៨២** | **-២.៨០១.៤៦៦** | **-២.៨៨១.១០៨** |
| **ទុនបម្រុង** | **៣.១៣២.២៧៣** | **៣.៨១៣.៤៣០** | **៣.៦២១.៣៣៤** | **៣.១៧០.៩៦៣** | **៣.៤៨០.៧៣៦** | **៣.៨៤១.៥៥១** | **៣.៧១៧.៦៩៦** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | ៤៧.១៧៩ | ៣៨.៨៤៤ | ៥១.៤២៤ | ៤៥.១៤០ | ៥២.៣៧១ | ៦២.៥៣០ | ៦៧.៣៧០ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | ៣.០៨៥.០៩៤ | ៣.៧៧៤.៥៨៦ | ៣.៥៦៩.៩១០ | ៣.១២៥.៨២៣ | ៣.៤២៨.៣៦៥ | ៣.៧៧៩.០២១ | ៣.៦៥០.៣២៥ |
| **ប្រាក់បញ្ញើ (ទ្រព្យអកម្មក្នុងស្រុក)** | **៩.៣០៨.១៣៥** | **៩.៦៩១.០៥៥** | **៩.៩៧២.៥៨៦** | **៩.៧០២.៦៨១** | **១០.០៥៩.៨១០** | **១០.៤៥៦.១១៣** | **១០.៣១៨.៤១៧** |
| ប្រាក់បញ្ញើចរន្ត | ៤៩.៤៦២ | ៤៤.៧៨៤ | ៤៤.៣៨៣ | ៤៤.៥៥៧ | ៦២.២៨១ | ៦៤.២៤៥ | ៨៧.៤៤៤ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១២១.០២៣ | ១១៥.៤៥៣ | ១១៨.៧០២ | ១២៥.៨៦៦ | ១៤១.១៩៨ | ១៤៥.៦៣១ | ១៤៩.៦៦៧ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៩.១៣៧.៦៥០ | ៩.៥៣០.៨១៨ | ៩.៨០៩.៥៤១ | ៩.៥៣២.២៥៨ | ៩.៨៥៦.៣៧១ | ១០.២៤៦.២៣៨ | ១០.០៨១.៣០៧ |
| **ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប** | ១៣.៤៤២.៤៣៦ | ១៤.៣១៦.៨៧៦ | ១៤.៧៤៥.៦៧៦ | ១៤.៦៨៩.២៨៧ | ១៥.៨៦៣.៧៣៩ | ១៦.២០៧.៦៧២ | ១៦.២៥០.១៨៣ |
| | (បំរែបំរួលប្រចាំខែជាភាគរយ ) | | | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **-១១.៤៨** | **-៣៥.៣៦** | **៤.៦៩** | **-១៧.៣៨** | **-៨.៨៨** | **-១៣.៥១** | **-៣៩.៩៨** |
| ទ្រព្យសកម្មបរទេស | -៣.០១ | -១៨.៥១ | ៣.៥១ | -៧.០៤ | ១៦.២៤ | -១២.៩៧ | -១១.៨៥ |
| ទ្រព្យអកម្មបរទេស | ១៨.០៧ | ១២.៩១ | ២.២៦ | ៤.២៨ | ៣៧.៥៥ | -១២.៦៦ | ៤.០២ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **១៤.៨៦** | **១១.៥៤** | **៩.១០** | **៨.៨៨** | **២.៨៩** | **៣.៣៥** | **៦.៤៦** |
| **ឥណទានក្នុងស្រុក** | **៨.៨៩** | **១០.១៧** | **៧.០៣** | **៧.២៦** | **៤.៧២** | **៣.៧៧** | **៥.២៦** |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | ២៥.៦១ | -០.៦២ | ១៣.២៧ | ២.៩៦ | ៧.៩៨ | ៣.៩៦ | ១.៩២ |
| ឥណទានចំពោះសហគ្រាសរដ្ឋ | -៦.៣៦ | -៦.៧១ | -៧.៣៨ | -៧.៦៧ | -៨.៦៣ | -៨.៩៧ | -៩.២២ |
| ឥណទានចំពោះផ្នែកឯកជន | ៨.២៤ | ៩.៨៧ | ៧.២១ | ៧.០៤ | ៤.៨៣ | ៣.៧៥ | ៥.១៥ |
| ឥណទានសុទ្ធចំពោះធនាគារជាតិនៃកម្ពុជា | -០.៤៩ | ១០.៥៣ | ៩.០២ | -៨.២២ | ៩.០២ | -០.៤៧ | ០.៤៥ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-០.៨០** | **៧.៦០** | **៣.០០** | **៣.៩១** | **៨.៦៦** | **៤.៦១** | **២.៨៤** |
| **ទុនបម្រុង** | **៦.៥៧** | **២១.៧៥** | **-៥.០៤** | **-១២.៤៤** | **៩.៧៧** | **១០.៣៧** | **-៣.២២** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | ១៥.៤១ | -១៧.៦៧ | ៣២.៣៨ | -១២.២២ | ១៦.០២ | ១៩.៤០ | ៧.៧៤ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | ៦.៤៤ | ២២.៣៥ | -៥.៤២ | -១២.៤៤ | ៩.៦៨ | ១០.២៣ | -៣.៤១ |
| **ប្រាក់បញ្ញើ (ទ្រព្យអកម្មក្នុងស្រុក)** | **៤.៨៩** | **៤.១១** | **២.៩០** | **-២.៧១** | **៣.៦៨** | **៣.៩៤** | **-១.៣២** |
| ប្រាក់បញ្ញើចរន្ត | ១០.៩៣ | -១០.៣៦ | -០.៩៨ | ០.៤៨ | ៣៩.៦៨ | ៣.២២ | ៣៦.១១ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១០.៩៥ | -៤.៦០ | ២.៨១ | ៦.០៤ | ១២.១៨ | ៣.១៤ | ២.៧៧ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៤.៧៨ | -២៩.៦២ | ២.៩២ | -២.៨៣ | ៣.៤០ | ៣.៩៥ | -១.៦១ |
| **ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប** | **៤.៧២** | **៥.៧២** | **២.៩៩** | **-០.៣៨** | **៧.៩៩** | **២.១៧** | **០.២៦** |

## តារាង ៨ : ឥណទានចំណាត់ថ្នាក់តាមមុខរបរ

(មិនគិតបញ្ចូលសាខាខេត្តរបស់ធនាគារជាតិនៃកម្ពុជា)

(ឯកតា : លានរៀល)

| | ធ្នូ.២០០៧ | មករា.០៨ | កុម្ភៈ.០៨ | មិនា.០៨ | មេសា.០៨ | ឧសភា.០៨ | មិថុនា.០៨ |
|---|---|---|---|---|---|---|---|
| កសិកម្ម | ៣០៥.២៤៥ | ៣២២.៧៦០ | ៣៥៨.២៤៩ | ៤០១.១៦០ | ៤៣៧.៧៧៦ | ៤៩២.១៩៦ | ៥៣៥.៨៤៩ |
| កម្មន្តសាលកម្ម | ៦២៥.៥៨៥ | ៦២០.៣៩០ | ៦៥៣.០១៦ | ៦៧៤.៧៦៥ | ៧២៧.៣៦១ | ៧៣៦.០០១ | ៧៩៨.៧៧០ |
| សំណង់ | ៦៤០.៦៨៥ | ៦១៥.៥៤៥ | ៦៧៥.២៧៩ | ៧២២.៤៦២ | ៧២៣.៨៣៣ | ៧៩៤.៩៧៧ | ៦២៩.៨៣៨ |
| លក់ដុំ និង លក់រាយ | ១.៣៧១.០៧៧ | ១.៥៦៨.៩៤៤ | ១.៦៨៣.២៥៣ | ១.៨៤៩.៥៦២ | ១.៩៦៥.០៣០ | ២.០៣៦.៩៤២ | ២.២០៦.៣៧២ |
| នាំចេញ | ១៣.៧២៨ | ១៦.៨៣០ | ១៦.៤៤៤ | ២៨.៥១៨ | ១៤.៣០១ | ១២.៥៧៣ | ២០.៩៦៥ |
| នាំចូល | ២២៩.៦៦៣ | ២៥១.៤២៧ | ២៦២.៤៤១ | ២៦២.១៨៥ | ២៥៥.៩៦២ | ៣២២.៧១០ | ៣៤២.៨៥៤ |
| ហិរញ្ញវត្ថុ | ៣៦.៤៥៥ | ៤៤.៨៤៣ | ៤៦.៩៨៥ | ៥៣.២៦៤ | ៥៣.៤០៧ | ៤៩.៦២៤ | ៥០.៣០០ |
| អចលនវត្ថុ និង ការប្រើប្រាស់សាធារណៈ | ៤៩៥.៤៤៧ | ៥៩២.៨៤១ | ៦៥៦.៥៣៥ | ៧៤៧.៨១៧ | ៧៩២.៥១៣ | ៧៣៩.០១៣ | ៦៣៦.០៥៥ |
| សេវាកម្ម | ១.៨០២.៣៥០ | ១.៩៦៨.៩៦៤ | ២.០៦៧.២៨៨ | ២.១៣២.៤២៤ | ២.២៦១.៨៦១ | ២.៣២២.៩៩៩ | ២.៦១៦.៦៥៨ |
| ផ្សេងៗ | ៧៣៩.៤២២ | ៨៨៤.០៨១ | ៩៧១.១០២ | ១.០៥១.៣១៩ | ១.០៧៨.៥៧១ | ១.១៣៩.៣០៥ | ១.២២១.១៦៩ |
| **សរុប** | **៦.២៥៩.៦៩៧** | **៦.៨៨៦.៦២៥** | **៧.៣៩០.៥៩២** | **៧.៩២៣.៤៧៦** | **៨.៣១០.៦១៥** | **៨.៦០៦.៣៤០** | **៩.០៥៨.៨៣១** |

## តារាង ៩ : សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ

(មិនគិតបញ្ចូលសាខាខេត្តរបស់ធនាគារជាតិនៃកម្ពុជា)

(ឯកតា : លានរៀល)

| | ធ្នូ.២០០៧ | មករា.០៨ | កុម្ភៈ.០៨ | មិនា.០៨ | មេសា.០៨ | ឧសភា.០៨ | មិថុនា.០៨ |
|---|---|---|---|---|---|---|---|
| **ប្រាក់បញ្ញើជារៀល** | | | | | | | |
| ប្រាក់បញ្ញើចរន្ត | ៥៣.៥៦០ | ៤៧.៨៣២ | ៤៨.៦១៤ | ៤៩.៦០២ | ៦៥.៥៥៣ | ៦២.១៨៥ | ៩៤.៩២២ |
| ប្រាក់បញ្ញើសន្សំ | ១៣៥.០៨៧ | ១៣៤.៣២៥ | ១៣៥.៥៧៨ | ១៣៨.១០៣ | ១៤៧.៣៦៩ | ១៥៤.៤៥៩ | ១៥៨.៦៧៦ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៤៩.៦៤៩ | ៤៤.៨៧០ | ៤៧.២៥៤ | ៥៦.៤៦៤ | ៥២.៣០៧ | ៥៣.៨៤៧ | ៥៨.៧៣០ |
| ប្រាក់បញ្ញើផ្សេងៗ | ១.២២១ | ៩៦៣ | ១.១៧២ | ១.២៣២ | ១.៣០៣ | ១.១០២ | ១.៧៣៨ |
| សរុប | **២៣៩.៥១៧** | **២២៧.៩៩០** | **២៣២.៦១៨** | **២៤៥.៤០២** | **២៦៦.៥៣១** | **២៧១.៥៩៣** | **៣១៤.០៦៧** |
| **ប្រាក់បញ្ញើជារូបិយប័ណ្ណ** | | | | | | | |
| ប្រាក់បញ្ញើចរន្ត | ២.៣១២.៧៤២ | ២.៥៥៦.២២២ | ២.៥២៤.៦៣៦ | ២.៤៣១.៥២៤ | ២.៦៤០.៤៤៧ | ២.៩២២.៦៣១ | ២.៦៤៤.៤១០ |
| ប្រាក់បញ្ញើសន្សំ | ៤.៥១៨.២៥៧ | ៤.៣៨០.០៥៤ | ៤.៦៤៧.៦៩៣ | ៤.៥៤២.២៤៦ | ៤.៦០១.១៨៨ | ៤.៥៣៥.២៩២ | ៤.៣៩៨.៣៩៣ |
| ប្រាក់បញ្ញើមានកាលកំណត់ | ២.៧៦៣.០៦១ | ២.៩៩២.៣៤៧ | ៣.១០៩.២៤១ | ៣.០៤៨.៣៧៦ | ៣.១៣០.៧៤៤ | ៣.២៥៣.៦៥៨ | ៣.៤៩៤.៦៤៦ |
| ប្រាក់បញ្ញើផ្សេងៗ | ៨៨.៨៩៤ | ៨២.២៥៦ | ៦៥.៦៦២ | ៦៨.១៦០ | ៦២.៣០១ | ៧០.១២៣ | ៨៦.៧១៥ |
| សរុប | **៩.៦៨២.៩៥៥** | **១០.០១០.៨៧៩** | **១០.៣៤៧.២៣១** | **១០.០៩០.៣០៧** | **១០.៤៣៤.៦៨១** | **១០.៧៨១.៦៦៤** | **១០.៦២៤.១៦៤** |
| សរុបរួម | **៩.៩២២.៤៧២** | **១០.២៣៨.៨៧០** | **១០.៥៧៩.៨៤៩** | **១០.៣៣៥.៧០៩** | **១០.៧០១.២១២** | **១១.០៥៣.២៥៦** | **១០.៩៣៨.២៣១** |

# ជញ្ជីងទូទាត់ប្រទេសកម្ពុជា
## ឆ្នាំ២០០៥ ដល់ ឆមាសទី១-២០០៨

(គិតជាលានដុល្លារអាមេរិក)

| | ២០០៥ | ២០០៦ | ២០០៧ | | ២០០៨[ព] |
|---|---|---|---|---|---|
| | | ឆមាសទី១ | ឆមាសទី២ | ឆមាសទី១ | |
| **ជញ្ជីងពាណិជ្ជកម្ម** | **-១.០១៧,៦** | **-១.០៥៥,៦** | **-៥៤៦,៧** | **-៧៨៨,០** | **-៥៧៨,១** |
| នាំចេញ (FOB) | ២.៩១០,៣ | ៣.៦៩៣,៧ | ២.០៥១,៤ | ២.០៣៧,៧ | ២.៤៨៤,០ |
| នាំចេញផលិតផលក្នុងស្រុក | ២.៧៧២.៨ | ៣.៥៣៧.៨ | ១.៩៦៣.០ | ១.៩១០.៩ | ២.៣៥៥.៣ |
| នាំចេញតាមប្រព័ន្ធ GSP (រាប់បញ្ចូល សំលៀកបំពាក់) | ២.២៦០.៧ | ២.៧២៧.៣ | ១.៣៧០.០ | ១.៥៧២.៣ | ១.៥៥៣.៣ |
| នាំចេញផលិតផលក្នុងស្រុកផ្សេងៗ | ៥១២.២ | ៨១០.៥ | ៥៩៣.០ | ៣៣៨.៧ | ៨០២.០ |
| នាំចេញបន្ត | ១៣៧.៤ | ១៥៥.៨ | ៨៨.៤ | ១២៦.៨ | ១២៨.៧ |
| នាំចូល (FOB) | -៣.៩២៧,៨ | -៤.៧៤៩,២ | -២.៥៩៨,០ | -២.៨២៥,៦ | -៣.០៦២,១ |
| នាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុក | -៣.៨១១.៧ | -៤.៦១៤.៦ | -២.៥២២.៥ | -២.៧១៩.៧ | -២.៩៥៥.៥ |
| សំលៀកបំពាក់ | -១.១០២.៣ | -១.២៩៧.៧ | -៦៤២.៤ | -៧៣៤.២ | -៧២៥.៩ |
| ប្រេងឥន្ធនៈ | -៨៤១.៦ | -១.១២៣.៤ | -៧០០.១ | -៦៤៧.៦ | -៧៩៣.៣ |
| នាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុកផ្សេងៗ | -១.៨៦៧.៨ | -២.១៩៣.៥ | -១.១៨០.០ | -១.៣៣៨.០ | -១.៤៣៦.៣ |
| នាំចូលសម្រាប់នាំចេញបន្ត | -១១៦.១ | -១៣៤.៦ | -៧៥.៦ | -១០៥.៩ | -១០៦.៦ |
| **សេវា (សុទ្ធ)** | **៤៧១,១** | **៥០៤,២** | **៣១៨,៣** | **៣២៦,១** | **៣៨៤,៧** |
| ចំណូល | ១.១១៨,១ | ១.២៩៦,៣ | ៧៦៦,២ | ៧៨១,៣ | ៨៨៩,០ |
| សេវាដឹកជញ្ជូន | ១២៦.៩ | ១៦៦.៨ | ១០៤.១ | ១០៥.៦ | ១២១.៨ |
| សេវាធ្វើដំណើរ | ៨៣៩.៥ | ៩៦៣.២ | ៥៥៥.៤ | ៥៧៩.៥ | ៦៦០.៦ |
| សេវាផ្សេងៗ | ១៥១.៦ | ១៦៦.៣ | ១០៦.៧ | ៩៦.៣ | ១០៦.៦ |
| ចំណាយ | -៦៤៧,១ | -៧៩២,១ | -៤៤៧,៩ | -៤៥៥,២ | -៥០៤,៣ |
| សេវាដឹកជញ្ជូន | -៣៦០.៣ | -៤៣៨.៣ | -២៤៥.៧ | -២៦៤.៥ | -២៨៩.២ |
| សេវាធ្វើដំណើរ | -៩៦.៩ | -១២២.២ | -៦៥.៣ | -៥៧.៤ | -៦៣.២ |
| សេវាផ្សេងៗ | -១៨៩.៩ | -២៣១.៧ | -១៣៦.៩ | -១៣៣.៣ | -១៥២.០ |
| **ប្រាក់ចំណូល (សុទ្ធ)** | **-២៥៤,០** | **-២៩០,៤** | **-១៥៨,៥** | **-២០១,៥** | **-១៩៥,៩** |
| ចំណូល | ៦៧,៧ | ៩០,០ | ៥២,៤ | ៥៩,៦ | ៥៦,៣ |
| ចំណាយ | -៣២១,៨ | -៣៨០,៤ | -២១០,៩ | -២៦១,១ | -២៥២,២ |
| **បង្វែរឯកជន (សុទ្ធ)** | **២០៩,៣** | **៣១៥,១** | **២០០,៣** | **១៨០,៤** | **១៨២,១** |
| **សមតុល្យគណនីចរន្ត** (មិនរាប់បញ្ចូលបង្វែរផ្លូវការ) | -៥៩១,៣ | -៥២៦,៧ | -១៨៦,៦ | -៤៨៣,០ | -២០៧,២ |
| **បង្វែរផ្លូវការ** | **៣២៥,៧** | **៤៤៩,១** | **២០៨,០** | **២០៨,០** | **២១៥,៧** |
| ចំណូល | ៣២៦,០ | ៤៤៩,៤ | ២០៨,១ | ២០៨,១ | ២១៥,៨ |
| ក្នុងនោះ : ជំនួយទ្រទ្រង់ថវិកា | ២.៧ | ៧.០ | ១០.៧ | ១០.៧ | ១២.៨ |
| ជំនួយជាស្បៀងអាហារ | ១៧.១ | ២០.១ | ១៤.៧ | ១៤.៧ | ១៥.៧ |
| ជំនួយតាមគម្រោង | ១៦៣.៤ | ២៥៤.៥ | ៩៣.៣ | ៩៣.៣ | ៩៧.៦ |
| ជំនួយបច្ចេកទេស | ១៤២.៨ | ១៦៧.៨ | ៨៩.៥ | ៨៩.៥ | ៨៩.៨ |
| ចំណាយ | -០,៣ | -០,៣ | -០,១ | -០,១ | -០,១ |
| **សមតុល្យគណនីចរន្ត និងបង្វែរដើមទុន** | -២៦៥,៦ | -៧៧,៦ | ២១,៤ | -២៧៥,០ | ៨,៥ |
| **គណនីហិរញ្ញវត្ថុ** | ៣៣៤,៩ | ៣២២,០ | ១៣៧,៤ | ៥៣៤,២ | ២៦១,៧ |
| **ឥណទានផ្លូវការ** (មិនរាប់បញ្ចូល IMF) សុទ្ធ* | **១៤៤,០** | **១៤០,៩** | **៦៦,៦** | **៥៣,១** | **៨២,២** |
| ដកប្រាក់ | ១៥៣,៣ | ១៤៩,៩ | ៦៨,៥ | ៦០,០ | ៨៧,០ |
| ទូទាត់ | -៩,៣ | -៩,០ | -១,៩ | -៧,០ | -៤,៨ |
| **វិនិយោគមិនផ្លូវការ** | **១៩០,៩** | **១៨១,១** | **៧០,៩** | **៤៨១,១** | **១៧៩,៦** |
| វិនិយោគផ្ទាល់ (សុទ្ធ)* | ៣៧៤,៩ | ៤៧៤,៨ | ៣៧៧,៨ | ៤៨៨,៣ | ៣៦៧,៨ |
| វិនិយោគលើឥណប័ត្រ (សុទ្ធ)* | -៧,២ | -១២,១ | -៦,១ | -៦,៣ | -៦,៤ |
| វិនិយោគផ្សេងទៀត (សុទ្ធ)* | -១៧៦,៨ | -២៨១,៦ | -៣០០,៩ | -០,៩ | -១៨១,៨ |
| **កំហុស និង រំលង** | **៥,១** | **-៤២,៦** | **-៨,១** | **៣,៣** | **-១៧,៦** |
| **សមតុល្យរួម** | ៧៤,៤ | ២០១,៩ | ១៥០,៧ | ២៦២,៦ | ២៥២,៧ |
| **ហិរញ្ញប្បទាន** | -៧៤,៤ | -២០១,៩ | -១៥០,៧ | -២៦២,៦ | -២៥២,៧ |
| **ទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិ** * | **-៨៧,១** | **-២២០,៧** | **-១៥៣,៨** | **-២៧២,២** | **-២៥៥,៧** |
| បម្រែបម្រួលទ្រព្យសកម្មជាទុនបម្រុង | -៧៨.៤ | -១៣៨.៦ | -១៥៣.៨ | -២៧២.២ | -២៥៥.៧ |
| ការប្រើប្រាស់ឥណទានរបស់ IMF | -៨.៨ | -៨២.១ | 0.0 | 0.0 | 0.0 |
| **ហិរញ្ញប្បទានពិសេស** | **១២,៨** | **១៨,៨** | **៣,១** | **៩,៧** | **៣,១** |

* តម្លៃវិជ្ជមានតំណាងអោយកំណើនទ្រព្យអកម្មបរទេស ឬថយចុះទ្រព្យសកម្មបរទេស និងតម្លៃអវិជ្ជមានតំណាងអោយកំណើនទ្រព្យសកម្មបរទេស ឬការថយចុះទ្រព្យអកម្មបរទេស

ប្រភព : ទិន្នន័យត្រូវបានផ្តល់ដោយអាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិ

កំណត់សំគាល់ : - ទិន្នន័យបណ្តោះអាសន្នសំរាប់ឆ្នាំ២០០៥-២០០៧ (ទិន្នន័យទាំងនេះអាចនឹងកែលំអឡើងវិញក្នុងពេលអនាគត)

- ព = ព្យាករណ៍ទិន្នន័យសម្រាប់ឆមាសទី១ ឆ្នាំ២០០៨